សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណាបញ្ចប់ការសិក្សា**

# ប្រៀបធៀប
# ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង
# ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ស្រាវជ្រាវ ពីថ្ងៃទី ០២ ខែ មិថុនា ដល់ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១៧


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ លោក. **ហូ ណារ៉ុម**
លោក. **គាន់ សុខលី**

សាស្ត្រាចារ្យណែនាំ
លោកសាស្ត្រាចារ្យ **គង់ សាផន**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ
ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# អារម្ភកថា

ឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររយៈពេល ៤ ឆ្នាំកន្លងមកនេះ មុខវិជ្ជាដែលយើងគិតថាស្រលាញ់ ចូលចិត្តនិងសាកសមបំផុត លើកយកមកស្រាវជ្រាវ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ គឺមុខវិជ្ជា នីតិក្រុមហ៊ុន ។ មុខវិជ្ជានេះវា ពិតជាមានសារៈសំខាន់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុន ។ ដូច្នេះ ទើបពួកយើងសម្រេចចិត្តថា ធ្វើការប្រៀបធៀប រវាងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ។

តាមរយៈប្រធានបទខាងលើ អាចជាគន្លឹះខ្លះៗ ដល់អ្នកដែលមានបំណង ចង់បង្កើតក្រុមហ៊ុនពាណិជ្ជកម្មខ្នាតតូចដែលមានការទទួលខុសត្រូវមានកម្រិត អាចធ្វើការសម្រេចដ៏ត្រឹមត្រូវមួយថាខ្លួនគួរជ្រើសរើសក្រុមហ៊ុនប្រភេទណាមួយ ដើម្បីប្រកបអាជីវកម្មអោយសាកសមនឹងសមត្ថភាពរបស់ខ្លួន រួមទាំងដើមទុន និងជាពិសេសរួមចំណែកជួយដល់ការសិក្សារបស់និស្សិតផងដែរ ។

យើងខ្ញុំរីករាយស្វាគមន៍ រាល់ការកែរលម្អ ស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និងមជ្ឈដ្ឋានអ្នកសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍស្នាដៃស្រាវជ្រាវនេះ អោយកាន់តែល្អប្រសើរឡើង ចំពោះការភ្លាំងភ្លាត់ខ្វះចន្លោះ ទាំងផ្នែកអត្ថន័យខ្លឹមសារ និងផ្នែកអក្ខរាវិរុទ្ធក្តីដោយប្រការណាមួយ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ហូ ណារ៉ុម និងឈ្មោះ កាន់ សុខលី ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៧ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសូមសម្តែងនូវការដឹងគុណ កត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណទាំងឡាយដូចជា៖

- លោកឪពុក ព្រំ ធីវុទ្ធ អ្នកម្តាយ ឈូក រុក្ខា និងលោកឪពុក កាន់ ឡាយ អ្នកម្តាយ ឡាយ ង៉ែ ដែលបានបង្កើត និងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ពេញវ័យ រួមទាំងការបណ្តុះបណ្តាលផ្នត់គំនិតឲ្យក្លាយជាមនុស្សល្អម្នាក់ក្នុងសង្គម ហើយក៏ជាកំលាំងចិត្តដ៏មហិមាដែលធ្វើឲ្យពួកយើងមានការតាំងចិត្តខ្ពង់ ក្រោកឈរម្តងហើយម្តងទៀតដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រនៅសកលវិទ្យាល័យនេះរហូតដល់ចប់។ ទឹកចិត្ត សេចក្តីមេត្តាធម៌ និងការខិតខំរបស់អ្នកទាំងអស់គ្នា យើងខ្ញុំទាំងពីរនាក់គ្មានថ្ងៃអាចបំភ្លេចបានឡើយ ហើយយើងខ្ញុំទាំងពីរសន្យាថានិងសងគុណអ្នកទាំងទ្វេមិនឲ្យអ្នកទាំងអស់គ្នាពិបានចិត្តឡើយ។
- ឯកឧត្តម លុយ ចណ្ណា សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានអនុញ្ញាតឲ្យយើងទាំងពីរបានចូលរៀន និងថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិក សាកលវិទ្យាល័យទាំងអស់ដែលតែងតែជួយសម្រួលគ្រប់កិច្ចការរដ្ឋបាលក្នុងរយៈពេល ៤ឆ្នាំកន្លងមកនេះ។
- លោកសាស្ត្រាចារ្យ គង់ សាផន ជាពិសេសដែលជាសាស្ត្រាចារ្យណែនាំជួយសម្រួលដល់កិច្ចការស្រាវជ្រាវមួយនេះរហូតបានចេញជារូបរាងឡើង និងជាអ្នកផ្តល់ពុទ្ធិដល់យើងទាំងពីរនាក់ទាំងមុខវិជ្ជានីតិពាណិជ្ជកម្មក្តី និងនីតិក្រុមហ៊ុនក្តី។

យើងទាំងពីរនាក់គ្មានអ្វីសងគុណក្រៅពីម្រាមដៃដប់សំពះអគុណ និងសូមជូនពរអ្នកទាំងអស់ឲ្យជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ឡើយ។ ហើយយើងទាំងពីរនាក់សូមសន្យាថាទៅថ្ងៃអនាគតយើងនឹងធ្វើជាបុគ្គលល្អក្នុងសង្គម និងជាសរសរទ្រូងនៃប្រទេសជាតិមិនឲ្យអ្នកទាំងអស់គ្នាអស់សង្ឃឹមឡើយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី ១
## ការបង្កើតក្រុមហ៊ុនក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជន ទទួលខុសត្រូវមានកម្រិត

**ផ្នែកទី ១៖ លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុន** ........ ៣

**កថាភាគទី ១៖ លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** ........ ៣

១. លក្ខខណ្ឌគ្រឹះ ........ ៤

១.១. ការបង្ហាញឆន្ទៈ និងវិការៈនៃកិច្ចសន្យា ........ ៤

១.២. សមត្ថភាពរបស់សមាជិក ........ ៥

២. លក្ខខណ្ឌទម្រង់ ........ ៦

២.១. កិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានក្រិត ........ ៦

២.២. ការចុះបញ្ជី និងការផ្សព្វផ្សាយជាសាធារណៈ ........ ៧

**កថាភាគទី ២៖ លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** ........ ៨

១. លក្ខខណ្ឌគ្រឹះ ........ ៨

១.១. ការបង្ហាញឆន្ទៈ និង វិការៈនៃការបង្ហាញឆន្ទៈ ........ ៨

១.២. សមត្ថភាពរបស់សមាជិក ........ ៩

២. លក្ខខណ្ឌទម្រង់ ........ ១០

២.១.លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ........ ១០

២.២. ការចុះបញ្ជី និងការផ្សព្វផ្សាយជាសាធារណៈ ........ ១២

**ផ្នែកទី ២៖ សិទ្ធិ និងភារកិច្ចរបស់សមាជិកហ៊ុន** ........ ១២

**កថាភាគទី ១៖ សិទ្ធិរបស់សមាជិកហ៊ុន** ........ ១២

១. សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅ ........ ១២

១.១. សិទ្ធចូលរួមកិច្ចការក្រុមហ៊ុន ........ ១២

១.២. សិទ្ធិទទួលបានព័ត៌មាន និងពិគ្រោះយោបល់ ........ ១៣

១.៣. សិទ្ធិលើផលប្រយោជន៍ ............ ១៣
១.៤. សិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិក្រុមហ៊ុន ............ ១៤
២. សិទ្ធិរបស់សហកម្មសិទ្ធិករមានកម្រិត ............ ១៤
២.១. សិទ្ធិទទួលបានព័ត៌មាន និងពិគ្រោះយោបល់ ............ ១៥
២.២. សិទ្ធិចំពោះប្រាក់ចំណេញ ............ ១៥
២.៣. សិទ្ធិធ្វើអនុប្បទាន ............ ១៥
៣. សិទ្ធិរបស់សមាជិកហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ............ ១៦
៣.១. សិទ្ធិធ្វើអន្តរាគម និងទទួលបានព័ត៌មានក្រុមហ៊ុន ............ ១៦
៣.២. សិទ្ធិចំពោះប្រាក់ចំនេញ ............ ១៦
៣.៣. សិទ្ធិក្នុងការធ្វើអនុប្បទាន ............ ១៧
៣.៤. សិទ្ធិធ្វើសហប្រតិបត្តិការក្នុងក្រុមហ៊ុន ............ ១៨
**កថាភាគទី ២៖ ភាតព្វកិច្ចរបស់សមាជិកហ៊ុន** ............ ១៨
១. កាតព្វកិច្ចរបស់សហកម្មសិទ្ធិករទូទៅ ............ ១៨
១.១. កាតព្វកិច្ចទទួលខុសត្រូវចំពោះបំណុលគ្មានកម្រិត ............ ១៩
១.២. កាតព្វកិច្ចទទួលខុសត្រូវចំពោះបំណុលរបស់សហកម្មសិទ្ធិករមានកម្រិត ............ ១៩
២. កាតព្វកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត ............ ២០
២.១. កាតព្វកិច្ចបង់ភាគទុន ............ ២០
២.២. កាតព្វទទួលខុសត្រូវចំពោះបំណុល ............ ២០
៣. កាតព្វកិច្ចរបស់សមាជិកហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ............ ២១
៣.១. កាតព្វទទួលខុសត្រូវចំពោះបំណុលចំពោះបំណុល ............ ២១
៣.២. កាតព្វមិនប្រគួតប្រជែងក្នុងក្រុមហ៊ុន ............ ២១
**ផ្នែកទី ៣៖ ការប្រព្រឹត្តទៅនៃអង្គការគ្រប់គ្រងក្រុមហ៊ុន** ............ ២១
**កថាភាគទី ១៖ ការប្រព្រឹត្តទៅនៃអង្គការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** ............ ២២
១. អភិបាល ............ ២២
១.១. ការជ្រើសតាំង ............ ២២
១.២. អាណត្តិ និងការដកហូតដំណែង ............ ២២

១.៣. សិទ្ធិអំណាច និងការទទួលខុសត្រូវ ......... ២២
២. មហាសន្និបាត ......... ២៣
២.១. ការកោះប្រជុំ ......... ២៣
២.២. លក្ខខណ្ឌកូរ៉ុម និង របបនៃសេចក្ដីសម្រេច ......... ២៣
២.៣. កំណត់ហេតុ ......... ២៤
៣. សវនករ ......... ២៤
៣.១. ការតែងតាំង និងបញ្ចប់តួនាទី ......... ២៤
៣.២. តួនាទី និងការទទួលខុសត្រូវ ......... ២៥
**កថាភាគទី ២៖ ការប្រព្រឹត្តទៅនៃអង្គការគ្រប់គ្រងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** ......... ២៥
១. អភិបាល ......... ២៥
១.១. ការជ្រើសតាំង ......... ២៦
១.២. អាណត្តិ និងការដកហូតដំណែង ......... ២៦
១.៣. សិទ្ធិអំណាច និងការទទួលខុសត្រូវ ......... ២៧
២. មហាសន្និបាត ......... ២៧
២.១. ការកោះប្រជុំ ......... ២៨
២.២. របបនៃសេចក្ដីសម្រេច ......... ២៨
២.៣. កំណត់ហេតុ ......... ២៩
៣. សវនករ ......... ២៩
៣.១. ការតែងតាំង និងបញ្ចប់តួនាទី ......... ២៩
៣.២. តួនាទី និងការទទួលលខុសត្រូវ ......... ៣០
**ផ្នែកទី ៤៖ ការរំលាយក្រុមហ៊ុន** ......... ៣១
**កថាភាគទី ១៖ ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** ......... ៣១
១. មូលហេតុទូទៅនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ......... ៣១
២. មូលហេតុពិសេសនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ......... ៣១
**កថាភាគទី ២៖ ការរំលាយក្រុនហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** ......... ៣២
១. មូលហេតុនៃការរំលាយ ......... ៣២

២. ការជម្រះបញ្ជី ..... ៣២

## ជំពូកទី ២
## ការប្រៀបធៀបរវាងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

**ផ្នែកទី ១៖ លក្ខណៈដូចគ្នា** ..... ៣៤

**កថាភាគទី ១៖ ការបង្ហាញឆន្ទៈបង្កើតក្រុមហ៊ុន** ..... ៣៤

**កថាភាគទី ២៖ សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកហ៊ុន** ..... ៣៥

១. លក្ខណៈដូចគ្នានៃសិទ្ធិ របស់សមាជិកហ៊ុន ..... ៣៥

២. កាតព្វកិច្ចទទួលខុសត្រូវចំពោះក្រុមហ៊ុន និងបំណុល ..... ៣៥

**កថាភាគទី ៣៖ អង្គការគ្រប់គ្រងក្រុមហ៊ុន** ..... ៣៦

**កថាភាគទី ៤៖ ការបញ្ចប់ជីវិតក្រុមហ៊ុនដោយការព្រមព្រៀង និង អស់ថេរវេលា** ... ៣៦

**ផ្នែកទី ២៖ លក្ខណៈខុសគ្នា** ..... ៣៧

**កថាភាគទី ១៖ លក្ខណៈខុសគ្នានៃលក្ខខណ្ឌបង្កើតក្រុមហ៊ុន** ..... ៣៧

១. លក្ខខណ្ឌគ្រិះ ..... ៣៧

១.១. សមត្ថភាពរបស់សមាជិកហ៊ុន ..... ៣៧

១.២. វិការៈនៃការបង្ហាញឆន្ទៈ ..... ៣៨

២. លក្ខខណ្ឌទម្រង់ ..... ៣៨

២.១. កិច្ចសន្យា និង លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ..... ៣៩

២.២. ការកំណត់មូលធន និងការបោះចេញប័ណ្ណភាគហ៊ុន ..... ៣៩

**កថាភាគទី ២៖ ភាពខុសគ្នានៃសិទ្ធិធ្វើអនុប្បទាន និងការការទទួលខុសត្រូវ** ..... ៤០

១. សិទ្ធិធ្វើអនុប្បទាន និងការផ្ទេរផលប្រយោជន៍ ..... ៤០

២. ការទទួលខុសត្រូវគ្មានកម្រិតរបស់សហកម្មសិទ្ធិករទូទៅ ..... ៤០

**កថាភាគទី ៣៖ លក្ខណៈសម្បត្តិអភិបាល និងរបបនៃសេចក្ដីសម្រេចក្នុងមហាសន្និបាត** ..... ៤១

១. ការជ្រើសរើសអភិបាល និងការកំណត់អាណត្តិ ..... ៤១

២. របបនៃសេចក្ដីសម្រេចក្នុងមហាសន្និបាត ..... ៤១

**កថាភាគទី ៤៖ អាយុជីវិតក្រុមហ៊ុន និងការបាត់បង់សមាជិកភាពម្ចាស់ហ៊ុន** ..... ៤២

## លទ្ធផលនៃការស្រាវជ្រាវ

**ក. គុណសម្បត្តិនៃទម្រង់ក្រុមហ៊ុនទាំងពីរ**..........................................................................................៤៣
ក.១. គុណសម្បត្តិនៃទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ....................................................៤៣
ក.២. គុណសម្បត្តិនៃទម្រង់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត........................................ ៤៥
**ខ. គុណវិបត្តិនៃទម្រង់ក្រុមហ៊ុនទាំងពីរ** ....................................................................................... ៤៥
ខ.១. គុណវិបត្តិនៃទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត......................................................... ៤៤
ខ.២. គុណវិបត្តិនៃទម្រង់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ............................................ ៤៥
**សេចក្ដីសន្និដ្ឋាន**........................................................................................................................ ៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

គ្រប់បុគ្គលទាំងអស់តែងតែមានគំរោងគិតពីអនាគតរបស់ខ្លួន បុគ្គលភាគច្រើនគិតថាការធ្វើជាម្ចាស់លើខ្លួនឯងគឺងាយស្រួល គ្មានការគាប់សង្កត់ផ្លូវចិត្ត ផ្លូវកាយពីនរណាម្នាក់ រីឯបុគ្គលមួយចំនួនទៀតគិតថាការធ្វើការចាំយកតែប្រាក់ខែងាយស្រួលជាង និងមានសេរីភាព មិនស្មុកស្មាញទៅវិញ។ ការងារដែលធ្វើជាម្ចាស់លើខ្លួនឯងក្នុងន័យនេះ ចង់សំដៅលើការប្រកបកិច្ចការរកស៊ី និងធ្វើជំនួញពាណិជ្ជកម្ម។ ពាណិជ្ជករដែលគ្រប់គ្រងពាណិជ្ជកម្មត្រូវតែជាបុគ្គលដែលមាន ធនធាន ចំណេះដឹង និងសមត្ថភាពតាមផ្លូវច្បាប់ទើបមានសិទ្ធិប្រកបអាជីវកម្មស្របច្បាប់។

កាលណារូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយដែលទទួលបានលក្ខណៈសម្បត្តិស្របច្បាប់នោះ អាចសហការគ្នាដោយធ្វើការបណ្តាក់ទុនបង្កើតជាក្រុមហ៊ុន ក្នុងគោលដៅធ្វើប្រតិបត្តិការពាណិជ្ជកម្មដើម្បីស្វែងរកប្រាក់ចំណេញ។ ដូចដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ មាត្រា១ បានកំណត់ទម្រង់ក្រុមហ៊ុនជាពីរគឺក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន។ ដែលក្រុមសហកម្មសិទ្ធិមានពីរប្រភេទទៀតគឺក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រីឯក្រុមហ៊ុនមូលធនក៏បានចែកជាពីរដែរគឺក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ប៉ុន្តែមុននឹងទទួលបានបុគ្គលិកលក្ខណៈស្របច្បាប់ក្រុមហ៊ុននោះត្រូវអនុវត្តកិច្ចមួយចំនួនដែលច្បាប់បានកំណត់ដូចជា ការបង្កើតកិច្ចសន្យាក្រុមហ៊ុន ឬការបង្កើតលក្ខន្តិកៈក្រុមហ៊ុន ការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្ម ជាពិសេការទទួលបានបុគ្គលភាពគតិយុត្តក្រោយពេលបង្កើតក្រុមហ៊ុន។ ជាក់ស្តែងនៅប្រទេសកម្ពុជាយើងមានក្រុមហ៊ុនពាណិជ្ជកម្មជាច្រើនបានប្រមាណ ១០ ៩០៤ ក្រុមហ៊ុនបានចុះបញ្ជីសាឡើងវិញ និងមានក្រុមហ៊ុនថ្មីតំណាងការិយាល័យ និងសាខាក្រុមហ៊ុនបរទេស ចំនួន ២៩៣៧ ក្រុមហ៊ុន បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នេះបើយោងតាមរបាយការណ៍បូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០១៦ និង ទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ ២០១៧ នៃក្រសួងពាណិជ្ជកម្ម។ តែទោះបីជាយ៉ាងនេះក្តី ភាគច្រើននៃក្រុមហ៊ុនទាំងនោះជាក្រុមហ៊ុនមូលធន រីឯទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ គេអាចនិយាយបានថាស្ទើរតែមិនមាននៅប្រទេសកម្ពុជាទេ។ នេះជាបញ្ហាដែលចោទមួយគួរឲ្យកត់សម្គាល់ ហេតុអ្វីបានជាទម្រង់ក្រុមហ៊ុនមូលធនមានការពេញនិយមខ្លាំង ជាជាងទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ? ដោយសារតែបញ្ហានេះយើងខ្ញុំបានជ្រើសរើសក្រុមហ៊ុនពីរគឺ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលសុទ្ធតែជាប្រភេទក្រុមហ៊ុនពាណិជ្ជកម្មខ្នាតតូច និងមានការទទួលខុសត្រូវមានកម្រិត មកធ្វើការប្រៀបធៀប។ ការប្រៀបធៀបនេះគឺដើម្បីស្រាយចម្ងល់ តើ

ក្រុមហ៊ុនទាំងពីមានលក្ខណៈដូចគ្នា និងខុសគ្នាដូចម្ដេចខ្លះ? តើក្រុមហ៊ុនទាំងពីនេះមានលក្ខណៈពិសេស និងចំណុចខ្វះខាតអ្វីខ្លះ? តើប្រភេទក្រុមហ៊ុនណាមួយដែលបានផ្ដល់អត្ថប្រយោជន៍ច្រើនដល់អ្នកដែលបានបង្កើតវា ហើយប្រតិបត្តិពាណិជ្ជកម្មរបស់ខ្លួនបានរលូន?

ដើម្បីដោះស្រាយចម្ងល់ដែលបានចោទឡើងខាងលើ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និង វិភាគ លើឯកសារច្បាប់ និង បទដ្ឋានគតិយុត្ត និង ឯកសារដទៃដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ជាពិសេសច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដើម្បីធ្វើការបកស្រាយដោយដាក់ចេញនូវប្លង់គោលមួយដូចខាងក្រោម៖

ជំពូកទី១៖ ការបង្កើតក្រុមហ៊ុនក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ជំពូកទី២៖ ប្រៀបធៀបរវាងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។

តាមរយៈការបែងចែកប្លង់ខាងលើនេះ យើងនឹងលើកយកនូវចំនុចសំខាន់ៗនៃទម្រង់ក្រុមហ៊ុនទាំងពីរមកធ្វើការបកស្រាយ និងប្រៀបធៀប ក្នុងគោលដៅទាញចេញជាចម្លើយនៃបញ្ហាដែលបានចោទខាងលើ។ យើងសង្ឃឹមថាតាមរយៈឯកសារនេះ វានឹងអាចជួយដល់ការសិក្សារបស់សិស្សនិស្សិតដែលស្រលាញ់ចូលចិត្ត មុខវិជ្ជានេះ ជាពិសេសអ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុនខ្នាតតូច តែមិនដឹងថាគួរជ្រើសរើសយកប្រភេទក្រុមហ៊ុនមួយណា នឹងទទួលបានចំណេះដឹងដែលទាក់ទងនឹងប្រធានបទនេះ។ ដើម្បីកុំឲ្យខាតពេលយូរសូមលោកអ្នកបើកនូវទំព័របន្ទាប់យើងនឹងនាំអារម្មណ៍លោកអ្នកដើម្បីស្រាយបំភ្លឺចម្ងល់ទាំងឡាយឲ្យកាន់តែស៊ីជម្រៅ។

# ជំពូកទី ១

# ការបង្កើតក្រុមហ៊ុនក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅប្រទេសកម្ពុជាត្រូវអនុវត្តទៅតាមបញ្ញត្តិនៃច្បាប់ប្រទេសកម្ពុជា ជាពិសេសច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ ២០០៥។ បុគ្គលដែលមានបំណងចង់បង្កើតក្រុមហ៊ុនត្រូវតែបំពេញនូវលក្ខខណ្ឌដែលច្បាប់បានតម្រូវ (ផ្នែក ១) មិនតែប៉ុណ្ណោះក្រោយពេលដែលក្រុមហ៊ុនត្រូវបានបង្កើតឡើងហើយ ស្ថាបនិកនឹងទទួលបានសិទ្ធិ ក៏ដូចជាកាតព្វកិច្ចចំពោះក្រុមហ៊ុន និងតតិយជន (ផ្នែក ២)។ វាក៏ទាមទារឲ្យមានការគ្រប់គ្រង ដឹកនាំប្រកបដោយប្រសិទ្ធភាព តាមរយៈអង្គការគ្រប់គ្រង់ក្រុមហ៊ុន (ផ្នែក ៣) និងលើសពីនេះ ក្រុមហ៊ុនដែលបានបង្កើតរួច ក៏អាចបាត់បង់ទៅវិញដោយសារលក្ខខណ្ឌមួយចំនួនផងដែរ (ផ្នែក ៤)។

## ផ្នែកទី ១៖ លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុន

នៅក្នុងប្រទេសកម្ពុជាពាក្យថាក្រុមហ៊ុនពាណិជ្ជកម្មត្រូវបានគេស្គាល់គ្រប់ៗគ្នា ផ្ទុយពីពាក្យថាសហគ្រាសពាណិជ្ជកម្ម តែតាមការពិតពាក្យទាំងពីរនេះមានអត្ថន័យដូចគ្នា គ្រាន់តែគេប្រើក្នុងប្រព័ន្ធច្បាប់ខុសគ្នាប៉ុណ្ណោះ។ តែប្រសិនបើយើងពិនិត្យពីបុគ្គលិកលក្ខណៈរបស់វាក្នុងន័យចង្អៀតវិញ យើងអាចដឹងពីភាពខុសគ្នាខ្លះៗដូចជា ការទទួលខុសត្រូវនៃសមាជិកហ៊ុន ឬក៏ការទទួលខុសត្រូវក្រុមហ៊ុន។ បញ្ញត្តិនៃ ក្រមរដ្ឋប្បវេណី និង ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បទដ្ឋានគតិយុត្តបានបង្កើតជាលក្ខខណ្ឌសម្រាប់បង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត (កថាខណ្ឌ ១) និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (កថាខណ្ឌ ២)។

### កថាភាគទី ១៖ លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត (Limited Partnership) ត្រូវបានឲ្យនិយមន័យដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមាត្រា ៦៤ ដែលបានចែងថាជាកិច្ចសន្យា ដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឲ្យ គ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិត ម្នាក់ ឬច្រើននាក់ដែលមាន

កាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។ ការបង្កើតកិច្ចសន្យាមួយឲ្យមានសុពលភាពតម្រូវឲ្យមានការបំពេញនូវទម្រង់លក្ខខណ្ឌដោយភាគីនៃកិច្ចសន្យា។

### ១. លក្ខខណ្ឌគ្រឹះ

ដូចបានបញ្ជាក់ខាងលើ ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានបង្កើតឡើងដោយបុគ្គលពីរនាក់ ឬច្រើននាក់ក្នុងគោលបំណងទាញរកប្រាក់ចំណេញរួមគ្នា។ ជាទូទៅទំនាក់ទំនងរវាងសមាជិកក្រុមហ៊ុនទាំងអស់នឹងក្រុមហ៊ុនត្រូវបានចងភ្ជាប់ដោយកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ដូចនេះការបង្ហាញឆន្ទៈ កម្មវត្ថុនៃកិច្ចសន្យា និងសមត្ថភាពចុះកិច្ចសន្យាជាលក្ខខណ្ឌគ្រឹះសំខាន់ដើម្បីឲ្យកិច្ចសន្យាមានសុពភាព។

#### ១.១. ការបង្ហាញឆន្ទៈ និងវិការៈនៃកិច្ចសន្យា

ការព្រមព្រៀងជាកត្តាសំខាន់មុននឹងធ្វើការបង្កើតក្រុមហ៊ុន ដោយសហកម្មសិទ្ធិករនីមួយៗត្រូវមានឆន្ទៈរួមគ្នា ពិតប្រាកដដើម្បីរួមដំណើរក្នុងការបង្កើនប្រាក់ចំណូល (ស្វែងរកប្រាក់ចំណេញ) ដែលជាកម្មវត្ថុចម្បងក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ដើម្បីឲ្យការបង្ហាញឆន្ទៈបង្កើតក្រុមហ៊ុនមានសុពលភាព វាទាមទារឲ្យសហកម្មសិទ្ធិករបង្ហាញឆន្ទៈដោយសេរីដែលជាការព្រមព្រៀងគ្មានភាពសៅហ្មង និងឆន្ទៈដោយស្មោះត្រង់ដែលជាការព្រមព្រៀងពិតប្រាកដគ្មានការបោកប្រាស់ ជៀសវាងអធមិនៃការព្រមព្រៀងដែលនាំឲ្យមានវិការៈនៃការព្រមព្រៀងនេះ។

ដោយសារថាក្រុមហ៊ុនប្រភេទនេះត្រូវបានបង្កើតឡើងតាមរយៈកិច្ចសន្យាក្រុមហ៊ុន ដូច្នេះវិធាននៃកិច្ចសន្យាត្រូវបានយកមកអនុវត្ត។ សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិបង្ហាញឆន្ទៈលុបចោលកិច្ចសន្យាដែលមានវិការៈបាន ដោយមានមូលហេតុត្រឹមត្រូវដូចជា ការភាន់ច្រឡំ ការឆបោក ឬការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត នឹងអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ [1] ។ ការលុបចោលកិច្ចសន្យាក្រុមហ៊ុនដែលមានវិការៈឈានទៅដល់ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតទាំងមូល។

ការភាន់ច្រឡំចំពោះកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចកើតឡើងលើពីររូបភាពគឺ ការភាន់ច្រឡំលើវត្ថុ និងការភាន់ច្រឡំលើបុគ្គល ។ ការភាន់ច្រឡំលើវត្ថុអាចជាភាន់ច្រឡំលើ ការវាយតម្លៃទៅលើភាគទុន ទំរង់នៃក្រុមហ៊ុន (ទម្រង់ក្រុមហ៊ុនផ្សេង) ដែលសមាជិកម្នាក់ចង់

[1] មាត្រា ៣៩៥ ការបង្ហាញឆន្ទៈដែលមានវិការៈ នៃក្រមរដ្ឋប្បវេណីខ្មែរ ២០០៧

ចូលហ៊ុន ប្រភេទនៃកិច្ចសន្យា។ ការភាន់ច្រឡំលើបុគ្គលជាការភ័ន្តច្រឡំទៅលើសមត្ថភាពពិតប្រាកដរបស់បុគ្គល កិត្តិស័ព្ទ ឬគុណភាពនៃការបំរើការងាររបស់បុគ្គលដែលបានចុះកិច្ចសន្យា។

កិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតក៏អាចមានវិការៈបានផងដែរ នៅពេលមានករណីឆបោក។ វាជាការប្រើឧបាយកលទុច្ចរឹតបោកប្រាស់របស់បុគ្គលណាម្នាក់ ដើម្បីធ្វើអោយភាគីម្ខាងទៀតមានការជឿទុកចិត្តយ៉ាងពិតប្រាកដដែលឈានដល់ការយល់ព្រមចូលហ៊ុនជាមួយគ្នា។

ការប្រើប្រាស់ហិង្សា ឬការគំរាមកំហែងដើម្បីបង្កើតកិច្ចសន្យាអាចស្តែងឡើងតាមរយៈការប្រើប្រាស់កំលាំងបង្ខិតបង្ខំលើរូបរាងកាយ ផ្លូវចិត្តលើបុគ្គលម្នាក់ដើម្បីអោយគេព្រមចុះកិច្ចសន្យាជាមួយខ្លួន ឬការប្រើប្រាស់ហិង្សាទៅលើសមាជិកនៃក្រុមគ្រួសាររបស់គេ។ ការប្រើប្រាស់អំពើហិង្សា ឬការគំរាមគំហែងទៅលើភាគីនៃកិច្ចសន្យា ភាគីនោះអាចប្រកាសលុបចោលកិច្ចសន្យានោះបាន[2]។

### ១.២. សមត្ថភាពរបស់សមាជិក

សមត្ថភាពរបស់ភាគីកិច្ចសន្យាគឺជាលក្ខខណ្ឌគ្រឹះមួយទៀត ដែលនាំឲ្យកិច្ចសន្យាមានសុពលភាព។ ភាគីនៃកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានពីប្រភេទគឺ សហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិត ដែលសមត្ថភាពភាគីទាំងពីត្រូវបានកំណត់។

#### ១.២.១. សមត្ថភាពរបស់សហកម្មសិទ្ធិករទូទៅ

សមត្ថភាពសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវតែជាពាណិជ្ជករ និងត្រូវរួមគ្នាដោយគ្មានកម្រិតសងបំណុលរបស់ក្រុមហ៊ុនលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន[3]។ ដើម្បីទទួលបានលក្ខណៈសម្បត្តិជាពាណិជ្ជករ ត្រូវគោរពតាមបញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម។ ចំពោះអនីតិជន និងអនីតិជនមានអត្ថាធិនភាពមិនអាចក្លាយទៅជាសហកម្មសិទ្ធិករបានទេ។ ជាងនេះទៅទៀតប្រសិនបើយើងឃើញថាមានបុគ្គលម្នាក់ជាសហកម្មសិទ្ធិករទូទៅផង នឹងជាសហកម្មសិទ្ធិករមានកម្រិតផងក្នុងពេលតែមួយនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត នោះបុគ្គលនេះឯងត្រូវមានសិទ្ធិ នឹងកាតព្វកិច្ចជាសហកម្មសិទ្ធិករទូទៅតែមួយមុខគត់[4]។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧មាត្រា៣៥០។
[3] សារាចរណែនាំក្រសួងពាណិជ្ជកម្មស្តីពីការចុះបញ្ជីពាណិជ្ជកម្ម, ០៣ ធ្នូ ១៩៩៧។
[4] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៦៥។

### ១.២.២. សមត្ថភាពរបស់សហាកម្មសិទ្ធិករមានកម្រិត

ចំពោះសមត្ថភាពរបស់សហាកម្មសិទ្ធិករមានកម្រិត មិនត្រូវបានកំណត់ជាពាណិជ្ជករទេ។ រូបវន្តបុគ្គលដែលមានសមត្ថភាពខាងរដ្ឋប្បវេណី អាចចូលជាមាជិកភាគហ៊ុនក្នុងក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតបាន។ រូបវន្តបុគ្គលដែលមាន នីតិភាព និងមានលិទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ភាគទុនទៅឲ្យក្រុមហ៊ុនតាមរយៈកិច្ចសន្យា នឹងអាចក្លាយជាសហាកម្មសិទ្ធិករមានកម្រិតបាន។ អនីតិជនដែលទទួលបានអត្តាធិនភាព ក៏អាចចូលរួមដោយដាក់ភាគហ៊ុនដោយសេរីបាននៅក្នុងក្រុមហ៊ុននេះបានដែរ។ មិនតែប៉ុណ្ណោះ អនីតិជន និងជនដែលជនការពារដោយច្បាប់ នៅតែអាចចូលហ៊ុនបាន តែវាត្រូវធ្វូលឡើងតាមរយៈវិធានរដ្ឋប្បវេណីដែលចែងអំពីតួនាទីអាណាព្យាបាលទូទៅ ដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការធ្វើជាតំណាង។

## ២. លក្ខខណ្ឌទម្រង់

ដើម្បីឲ្យកិច្ចសន្យាក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតមានសុពលភាព លក្ខខណ្ឌគ្រឹះតែមួយមិនគ្រប់គ្រាន់ទេ វាទាមទារឲ្យមានការបំពេញលក្ខខណ្ឌទម្រង់បន្ថែមទៀត ដែលជាលក្ខខណ្ឌចាំបាច់ដើម្បីឲ្យក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតទទួលបាននីតិបុគ្គលិកលក្ខណៈ។ វាជាទម្រង់នៃកិច្ចសន្យា និងការចុះបញ្ជីពាណិជ្ជកម្ម និងផ្សព្វផ្សាយជាសាធារណៈ។

### ២.១. កិច្ចសន្យាបង្កើតក្រុមហ៊ុនសហាកម្មសិទ្ធិមានក្រិត

ដូចបានកំណត់នៅក្នុងនិយមន័យនៃក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត (ច្បាប់ស្តីពីសហាគ្រាសពាណិជ្ជកម្ម, មាត្រា ៦៥) កិច្ចសន្យារវាងសហាកម្មសិទ្ធិករទូទៅ និងសហាកម្មសិទ្ធិករមានកម្រិត ដើម្បីបង្កើតសិទ្ធិ និងកាតព្វកិច្ចរវាគ្នានឹងគ្នា គឺជាលក្ខខណ្ឌចម្បងមួយក្នុងការបង្កើតក្រុមហ៊ុននេះ។ កិច្ចសន្យានៃក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតអាចស្ថិតក្រោមទម្រង់កិច្ចសន្យាពីរគឺ កិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬជាកិច្ចសន្យាផ្ទាល់មាត់។ ក្នុងករណីកិច្ចសន្យានេះត្រូវធ្វើឡើងតាមរយៈកិច្ចសន្យាលាយលក្ខណ៍អក្សរ សហាកម្មសិទ្ធិករទូទៅទាំងអស់ រួមទាំងសហាកម្មសិទ្ធិករមានកម្រិតយ៉ាងតិចមួយនាក់ចុះហត្ថលេខាលើកិច្ចសន្យានេះ។ រយៈពេលនៃកិច្ចសន្យាត្រូវកំណត់មិនឲ្យលើសពី ៩៩ឆ្នាំឡើយ។ តែទោះបីជាពេលវេលាត្រូវបានកំណត់យ៉ាងជាក់លាក់ក៏ដោយ ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតអាចបន្តថេរៈវេលានេះបាន[5]។

[5] ច្បាប់ស្តីពីសហាគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៦៦។

ចំពោះខ្លឹមសារនៃកិច្ចសន្យារបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវចែងនូវចំណុចសំខាន់ៗ ដូចជា[6]៖

- ចំនួនទឹកប្រាក់ និងតម្លៃភាគទុនរបស់សហកម្មសិទ្ធិករនីមួយ
- នាមករណ៍របស់ក្រុមហ៊ុនដោយដាក់បញ្ចូលនុវឈ្មោះសហកម្មសិទ្ធិករទូទៅយ៉ាងហោចណាស់ម្នាក់ (ឈ្មោះសហកម្មសិទ្ធិករមានកម្រិតអាចដាក់បញ្ចូលក្នុននាមករណ៍ក្រុមហ៊ុនបាន តែត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ ជៀសវាងការបង្កើតឲ្យមានកាតព្វកិច្ចគ្មានកម្រិតចំពោះសហកម្មសិទ្ធិករមានកម្រិត)[7]
- បញ្ជាក់ពីលក្ខណៈសម្បត្តិរបស់សហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិត (ការខកខាននៃការបញ្ជាក់លក្ខណៈសម្បត្តិសហកម្មសិទ្ធិករ ជាហេតុនាំឲ្យមានការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុនទៅជា ក្រុនហ៊ុនសកម្មសិទ្ធិទូទៅ)
- មូលធនសរុប (គិចជារូបិយវត្ថុជាតិ) និងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន។

កិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិអាចមានចែងផ្សេងពីនេះផងដែរ។

**២.២. ការចុះបញ្ជី និងការផ្សព្វផ្សាយជាសាធារណៈ**

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មាត្រា ៦៧ បានកំណត់យ៉ាងច្បាស់ថា ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបានបង្កើតឡើងតាមកាលបរិច្ឆេទដែលបានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ ហើយការិយាល័យក្រឡាបញ្ជីនៃតុលាការពាណិជ្ជកម្មជាអ្នកទទួលបន្ទុកក្នុងការចុះបញ្ជីពាណិជ្ជកម្មនេះ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវចុះបញ្ជីពាណិជ្ជកម្មមុនរយៈពេល ១៥ ថ្ងៃនៃកាលបរិច្ឆេទបើកប្រតិបត្តិការពាណិជ្ជកម្ម។ គួរបញ្ជាក់ផងដែរថាកាលណាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតពុំបានចុះបញ្ជីពាណិជ្ជកម្មទេនោះក្រុមហ៊ុនបែបនេះនឹងក្លាយជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅវិញ។ ក្នុងករណីនេះក្រុមហ៊ុនប្រភេទនេះពុំទទួលបាននីតិបុគ្គលិកលក្ខណៈទេ។ សំណុំលិខិតដែលត្រូវបំពេញការចុះបញ្ជីពាណិជ្ជកម្មស្របទៅតាមច្បាប់ និងការទាមទាររបស់ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម។

[6] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ២០០។
[7] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៦៨។

មិនតែប៉ុណ្ណោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវស្ថិតនៅក្រោមវិធាននៃការផ្សព្វផ្សាយជាសាធារណៈ តាមរយៈសារពត៌មានស្របច្បាប់។

**កថាភាគទី ២៖ លក្ខខណ្ឌនៃការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (Private Company Limited) គឺជាសហគ្រាសពាណិជ្ជកម្មខ្នាតតូចដែលគ្រប់គ្រងដោយបុគ្គលឯកជន។ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ បានកំណត់ថាវាគឺជាប្រភេទក្រុមហ៊ុនមូលធន ដែលមានការចូលភាគទុនពីសមាជិកជាច្រើនរូប ហើយមានការបោះចេញជាប័ណ្ណភាគហ៊ុន[8]។ ទោះបីវាជាក្រុមហ៊ុនមូលធន តែវាមានលក្ខណៈបង្កាត់ពូជគ្រួសារ ដោយមានការរាប់អានកប្រាក់កាស និងបុគ្គល ព្រោះតែការរឹតត្បិតការផ្ទេរភាគហ៊ុននៃសមាជិកហ៊ុន។ ក្រុមហ៊ុនប្រភេទនេះមានការពេញនិយមខ្លាំងពីសំណាក់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាជនបរទេស ដោយសារតែការទទួលខុសត្រូវមានកម្រិតរបស់វា និងការការពារតាមផ្លូវច្បាប់។

ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីអំពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលបានចែងទាក់ទងនឹងក្រុមហ៊ុមឯកជនទទួលខុសត្រូវមានកម្រិត បានកំណត់ចេញជាលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់មួយចំនួន ដើម្បីបង្កើតក្រុមហ៊ុនប្រភេទនេះ។

**១. លក្ខខណ្ឌគ្រឹះ**

**១.១. ការបង្ហាញឆន្ទៈ និង វិការៈនៃការបង្ហាញឆន្ទៈ**

មិនខុសគ្នាទៅនឹងទម្រង់ក្រុមហ៊ុនដទៃទេ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើត ការបង្ហាញឆន្ទៈពិតប្រាកដរបស់សមាជិកហ៊ុន។ ម្ចាស់ភាគហ៊ុនទាំងអស់ត្រូវបង្ហាញឆន្ទៈរបស់ខ្លួន ដែលជាការព្រមព្រៀងសេរី និងពិតប្រាដក្នុងការចូលរួមភាគទុនក្នុងក្រុមហ៊ុនក្នុងគោលដៅធ្វើប្រតិបត្តិការអាជីវកម្មដើម្បីស្វែងរកប្រាក់ចំណេញ។ ការបង្ហាញឆន្ទៈត្រូវជៀសឲ្យផុតពីអធម៌នៃការព្រមព្រៀង ដែលជាវិការៈនៃការបង្ហាញឆន្ទៈនោះ។ ប៉ុន្តែវិការៈនៃការបង្ហាញឆន្ទៈចំពោះចំណុចខ្លះក្នុងលក្ខន្តិកៈ វាមិនមែនជាកម្មវត្ថុនៃមោឃភាពលក្ខន្តិកៈក្រុមហ៊ុនទេ ហើយវាមិននាំឲ្យមានមោឃភាពដល់ការប្រព្រឹត្តរបស់ក្រុមហ៊ុននោះទេ ព្រោះវិធានរួមនៃកិច្ចសន្យាមិនបានអនុ

[8] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨៦។

វត្ថុចំពោះលក្ខន្តិកៈបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតឡើយ[9]។ សមាជិកហ៊ុនគ្រាន់តែធ្វើការកែប្រែចំណុចដែលមានវិការៈតែប៉ុណ្ណោះ។

### ១.២. សមត្ថភាពរបស់សមាជិក

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានលក្ខណៈរាប់អានបុគ្គល និងប្រាក់កាស ដូច្នេះវាទាមទារឲ្យមានការចូលរួមភាគទុនពីសមាជិក។ សមាជិកក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចជារូបវន្តបុគ្គល ឬក៏ជានីតិបុគ្គល[10]។

ចំនួនសមាជិកនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវបានកំណត់នៅមាត្រា ៨២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជ។ សមាជិកភាគហ៊ុនអាចមានចាប់ពី ២ នាក់ រហូតដល់ ៣០ នាក់។ ប៉ុន្តែបុគ្គលម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ តែវាស្ថិតនៅក្រោមទម្រង់សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។ សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត មានលក្ខខណ្ឌដូចគ្នាទៅនឹងក្រុមហ៊ុនឯកជនទទួលខុសត្រូវ លើកលែងតែ លក្ខខណ្ឌដែលនិយាយអំពីទំនាក់ទំនងសមាជិកភាគហ៊ុន។

នីតិបុគ្គល ឬ រូបវន្តបុគ្គលមួយ ឬ ច្រើន ដែលមានកាយសម្បទា និងសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ ដូច្នេះវាមិនទាមទារឲ្យសមាជិកហ៊ុនត្រូវតែជាពាណិជ្ជករនោះទេ។ រូបវន្តបុគ្គលដែលមានសមត្ថភាពខាងរដ្ឋប្បវេណី អាចចូលជាមាជិកភាគហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបាន។ អនីតិជនដែលទទួលបានអត្តាធិនភាព ក៏អាចចូលរួមដោយដាក់ភាគហ៊ុនដោយសេរីបានទៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបានផងដែរ។ មិនតែប៉ុណ្ណោះ អនីតិជន និងជនដែលការពារដោយច្បាប់ នៅតែអាចចូលហ៊ុនបាន តែវាត្រូវធ្វើឡើងតាមរយៈវិធានរដ្ឋប្បវេណីដែលចែងអំពីតួនាទីអាណាព្យាបាលទូទៅ ដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការធ្វើជាតំណាង[11]។

---

[9] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ១០៤។

[10] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩១។

[11] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ១៩៨។

## ២. លក្ខខណ្ឌទម្រង់

លក្ខខណ្ឌទម្រង់គឺជាលក្ខខណ្ឌចាំបាច់មួយ ដើម្បីបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតឲ្យស្របទៅតាមច្បាប់ និងទទួលបានបុគ្គលភាពគតិយុត្ត។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតម្រូវឲ្យមានការបង្កើតជាលក្ខន្តិកៈក្រុមហ៊ុន និងការចុះបញ្ជីពាណិជ្ជកម្ម។

### ២.១.លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

លក្ខន្តិកៈគឺជាលិខិតសង្ខេបបំផុត ដែលត្រូវធ្វើឡើងតាមច្បាប់កំណត់ និងមានចែងអំពីការគ្រប់គ្រង និងការប្រព្រឹត្តិទៅនៃជីវភាពក្រុមហ៊ុន។ វាអាចត្រូវបានគេធ្វើការកែប្រែបាន តាមរយៈសេចក្ដីសម្រេចពិសេសរបស់មហាសន្និបាត[12]។ លក្ខន្តិកៈអាចធ្វើឡើងតាមរូបភាពជាលិខិតឯកជន ឬជាលិខិតសារការី។ គ្រប់ទំព័រនៃលក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខា ឬហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់របស់ករុមហ៊ុននោះ[13]។

លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវមានចែងនូវលក្ខខណ្ឌដូចខាងក្រោម[14]៖

- នាមករណ៍របស់ក្រុមហ៊ុន (ត្រូវដាក់ពាក្យ "ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត" ឬ សរសេរអក្សរកាត់នៅខាងចុង)។
- ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ថេរវេលា ជានិច្ចកាលមានរយៈពេល ៩៩ ឆ្នាំ តែថេរវេលានេះគឺអាស្រ័យទៅតាមការកំណត់របស់សមាជិកហ៊ុន។ ការបន្តថេរវេលាក្រុមហ៊ុនអាចធ្វើទៅបានតាមរយៈការសម្រេចតាមមតិភាគច្រើនរបស់សមាជិកហ៊ុននៅក្នុងមហាន្និបាតម្ចាស់ភាគហ៊ុន ដែលត្រូវធ្វើឡើងយ៉ាងហោចណាស់មុនមួយឆ្នាំនៃការមកដល់នៃថេរវេលាក្រុមហ៊ុន។
- កម្មវត្ថុអាជិវកម្មនៃក្រុមហ៊ុន និងការកំណត់នូវកម្មវត្ថុអាជីវកម្មដែលក្រុមហ៊ុននោះធ្វើពាណិជ្ជកិច្ច។ អាជីវកម្មអាចមានមួយ ឬច្រើនប្រភេទ ដែលមិនផ្ទុយនឹងបញ្ញត្តិណាមួយនៃច្បាប់។

[12] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ២២៤។
[13] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩៥។
[14] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩៣។

- ដើមទុនត្រូវប្រកាសជាសាធារណៈ ដែលមានមូលធនអប្បបរមា ២០.០០០.០០០៛ [15] ដែលត្រូវបោះចេញជាប័ណ្ណភាគហ៊ុនយ៉ាងតិច ១០០០ ប័ណ្ណភាគហ៊ុន។ ដើមទុនត្រូវកំណត់និងប្រកាសជារូបិយវត្ថុជាតិ

- ចំណាត់ប្រភេទ និងចំនួនអតិបរមានៃភាគហ៊ុន ព្រមទាំងថ្លៃចារឹកលើប័ណ្ណភាគហ៊ុនដែលបានបោះចេញដោយក្រុមហ៊ុន។

- ក្នុងករណីក្រុមហ៊ុនមានការបោះប័ណ្ណភាគហ៊ុនលើសពីមួយប្រភេទ ត្រូវបញ្ជាក់ពីចំនួនភាគហ៊ុនអតិបរមា តម្លៃចារឹកលើប័ណ្ណភាគហ៊ុន និងសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទប័ណ្ណភាគហ៊ុននីមួយៗនោះ។

- ក្នុងករណីប្រភេទភាគហ៊ុនត្រូវបោះជាស៊េរី លក្ខន្តិកៈក្រុមហ៊ុនត្រូវអនុញ្ញាតឲ្យអភិបាលកំណត់ចំនួនភាគហ៊ុនស៊េរីនីមួយៗ ដើម្បីកំណត់ប្លង់បែងចែកស៊េរីនីមួយៗ ហើយឈានដល់ការកំណត់សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទស៊េរីនីមួយៗនោះ។

- ក្នុងករណីការបោះចេញការផ្ទេរ ឬ ការកាន់កាប់ប័ណ្ណភាគហ៊ុនត្រូវហាមឃាត់ ពេលនោះត្រូវមានរបាយការណ៍ពីប្រសិទ្ធិភាព និងរបាយការណ៍ពីការកម្រិតនោះ។

- ឈ្មោះ និង អាសយដ្ឋានពិតប្រាកដរបស់សមាជិកក្រុមហ៊ុននីមួយៗ។

- ចំនួនអភិបាល ឬ ចំនួនអប្បបរមា និងអតិបរមានៃអភិបាលរស់ក្រុមហ៊ុននោះ។

លក្ខន្តិកៈក៏អាចត្រូវបានបញ្ចូលផងដែរនូវចំណុចផ្សេងទៀតតាមការចាំបាច់ [16] ។ ក្រុមហ៊ុនអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន [17] ។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនត្រូវតាក់តែង ហើយចែកជូនគ្រប់ម្ចាស់ភាគហ៊ុនទាំងអស់ព្រមទាំងត្រូវតម្កល់ឲ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម និងរក្សាទុកនៅទីស្នាក់ការចុះបញ្ជីរបស់ខ្លួន។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៨៣។
[16] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩៥។
[17] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១០២។

### ២.២. ការចុះបញ្ជី និងការផ្សព្វផ្សាយជាសាធារណៈ

ការចុះបញ្ជីពាណិជ្ជកម្មគឺជាលក្ខខណ្ឌទម្រង់មួយសំខាន់ ដើម្បីឲ្យក្រុនហ៊ុនទទួលបានបុគ្គលភាពគតិយុត្ត។ ស្ថាបនិកក្រុមហ៊ុនត្រូវស្នើសុំទៅមន្រ្តីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដើម្បីតម្កល់លក្ខន្តិកៈជាមួយនិងឯកសារសុំចុះបញ្ជីពាណិជ្ជកម្មផ្សេងទៀត។ ក្រុមហ៊ុនទទួលបាននីតិបុគ្គលិកលក្ខណៈ ចាប់ពីកាលបរិច្ឆេទដែលបានចុះក្នុងបញ្ជីណាណិជ្ជកម្ម[18]។

ឯកសារតម្រូវក្នុងការចុះបញ្ជីណាណិជ្ជកម្មត្រូវកំណត់ដោយសេចក្ដីជូនដំណឹងស្ដីពីឯកសារតម្រូវសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មចុះថ្ងៃទី ២០ មិថុនា ២០០៦។ ក្រុមហ៊ុនត្រូវធ្វើការផ្សាយជាសាធារណៈតាមរយៈសារព័ត៌មានស្របច្បាប់។

## ផ្នែកទី ២៖ សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកហ៊ុន

តាមរយៈកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធមានកម្មសិទ្ធិមានកម្រិត និងលក្ខន្តិកៈក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម បានបង្កើតជា សិទ្ធិ (កថាខណ្ឌ ១) និង កាតព្វកិច្ច (កថាខណ្ឌ ២) ចំពោះសមាជិកហ៊ុននីមួយៗ ដែលបានដាក់ទុនរបស់ខ្លួនបង្កើតក្រុមហ៊ុនទាំងនោះឡើង។

### កថាភាគទី ១៖ សិទ្ធិរបស់សមាជិកហ៊ុន

#### ១. សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅ

សហកម្មសិទ្ធិករទូទៅទទួលបានសិទ្ធិនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិតាមរយៈការកំណត់នៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុន និងប្បញ្ញត្តិនៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ សិទ្ធិទាំងនោះទាក់ទងនឹងបេតិកភ័ណ្ឌ និងទំនាក់ទំនងរវាងសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុន។ ការចូលរួមក្នុងកិច្ចការនិងគ្រប់គ្រងទ្រព្យសម្បត្តិក្រុមហ៊ុន និងការទទួលបានអត្ថប្រយោជន៍ពីអាជីវកម្ម ជាសិទ្ធិដែលសហកម្មសិទ្ធិករទូទៅម្នាក់ៗទទួលបាន។

##### ១.១. សិទ្ធចូលរួមកិច្ចការក្រុមហ៊ុន

សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ក្នុងហ៊ុន [19] ។ ពួកគេត្រូវរួមសហការគ្នាដើម្បីជាផលប្រយោជន៍ក្រុមហ៊ុន ដោយឈរលើគោលការណ៍ស្មើដៃស្មើ

[18] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៩៦ - ៩៨។
[19] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៧។

ជើង និងសហប្រតិបត្តិការការងារដែលមានប្រសិទ្ធភាពទូលំទូលាយ។ វាមិនជាកាតព្វកិច្ចរបស់អ្នកចាត់ការតែម្នាក់ឯងនោះទេ វាទាមទារឲ្យមានការចូលបំពេញតួនាទី និងអនុវត្តសកម្មភាពប្រកបដោយលក្ខណៈប៉ិនប្រសព្វរបស់រាល់សហាកម្មសិទ្ធករទូទៅដើម្បីបំរើដល់កិច្ចអាជីវកម្ម និងប្រតិបត្តិការក្រុមហ៊ុន។ មិនតែប៉ុណ្ណោះសហាកម្មសិទ្ធិករទូទៅទាំងអស់អាចចូលរួមធ្វើសេចក្តីសម្រេចអំពីកិច្ចការគ្រប់គ្រងរាល់កិច្ចការរបស់ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត។ ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតជាសិទ្ធិស្របច្បាប់ ដែលសហាកម្មសិទ្ធិករទូទៅអាចធ្វើទៅបានទោះបីជាក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតត្រូវបានកំណត់ផ្ទុយនឹងនេះក៏ដោយ។ លើកលែងតែមានការចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត។ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតដោយសម្លេងភាគច្រើនដោយប្រៀបរបស់សហាកម្មសិទ្ធិករទូទៅ ដោយមិនគិតពីតម្លៃអត្ថប្រយោជន៍ តែសេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ[20]។

### ១.២. សិទ្ធិទទួលបានព័ត៌មាន និងពិគ្រោះយោបល់

រាល់កិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតអនុញ្ញាតឲ្យសហាកម្មសិទ្ធិករទូទៅម្នាក់ៗ មានសិទ្ធិទទួលព័តមាននេះបានហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅបញ្ជី និងកំណត់ហេតុទោះបីជាសហាកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ[21]។ ពួកគេមានសិទ្ធិទទួលបានព័ត៌មានដែលទាក់ទងនឹងរបាយការណ៍នៃកិច្ចការគ្រប់គ្រងប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុ ឯកសាគណនី និងឯកសារផ្សេងៗបាននៅទីស្នាក់ការក្រុមហ៊ុន។ សហាកម្មសិទ្ធិករទូទៅអាចពិគ្រោះយោបល់ ឬលើជាសំនួរជាលាលក្ខណ៍អក្សរទៅកាន់អភិបាលចំពោះបញ្ហាណាមួយហើយអភិបាលត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរមកវិញ។

### ១.៣. សិទ្ធិលើផលប្រយោជន៍

នៅក្នុងក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត ផលប្រយោជន៍អាចជាប្រាក់ចំណេញ និងទ្រព្យសម្បត្តិរបស់សហាកម្មសិទ្ធិករម្នាក់ៗ។ សហាកម្មិសិទ្ធិករទូទៅអាចទទួលបានប្រាក់ចំណេញរបស់ខ្លួនទៅតាមចំណែកសមមាត្រនៃភាគហ៊ុនចូលរួម និងតាមការកំណត់នៅក្នុងកិច្ចសន្យា។ សហាកម្មសិទ្ធិករទូទៅអាចទទួលបានប្រាក់ចំណេញមិនសមមាត្រហ៊ុនដោយសារមូលហេតុនៃបទពិសោធ ការយល់ដឹង និងប្រសិទ្ធភាពការងារជាមួយអតិថិជន។ ខសន្យាដែលដកសហាកម្មសិទ្ធិករទូទៅពីសិទ្ធិ

[20] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៨។

[21] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៩។

ទទួលបានប្រាក់ចំណេញត្រូវចាត់ទុកគ្មានប្រសិទ្ធភាព[22]។ សហកម្មសិទ្ធិករទូទៅក៏អាចប្រគល់សិទ្ធិឲ្យទៅបុគ្គលផ្សេងទៀត ដើម្បីទទួលប្រាក់កាសជំនួសខ្លួនបានដោយពុំចាំបាច់មានការយល់ព្រមពីសហកម្មសិទ្ធិករផ្សេងទៀតបាន លើកលែងតែករណីនៃការផ្ទេរអត្ថប្រយោជន៍របស់ខ្លួនប៉ុណ្ណោះដែលដាច់ខាតត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីបណ្តាសហកម្មសិទ្ធិករទាំងអស់។

### ១.៤. សិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិក្រុមហ៊ុន

រាល់សហកម្មសិទ្ធិករទូទៅអាចប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនបាន លុះត្រាតែជាប្រយោជន៍របស់ក្រុមហ៊ុនផ្ទាល់។ តែប្រសិនបើមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទូទៅដ៏ទៃទៀតនោះ ការប្រើប្រាស់ទ្រព្យសម្បត្តិក្នុងគោលបំណងផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅនោះអាចប្រព្រឹត្តិទៅបានដោយពុំមានការប៉ះពាល់ដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀត ដែលប្រើប្រាស់ទ្រព្យសម្បត្តិនោះ[23]។ ទោះបីជាក្នុងច្បាប់ចែងថាទ្រព្យសម្បត្តិទាំងអស់របស់សហកម្មសិទ្ធិករទូទៅជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដោយគ្មានកំណត់ក៏ដោយ ក៏ច្បាប់នៅតែអនុញ្ញាតឲ្យសហកម្មសិទ្ធិករទូទៅមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិនោះជាការធានានូវកាតព្វកិច្ចផ្ទាល់ខ្លួនបានដែរទោះបីជាទ្រព្យនោះជាភាគទុន ឬ ប្រាក់ចំណេញក៏ដោយ ប៉ុន្តែត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករទាំងអស់[24]។

## ២. សិទ្ធិរបស់សហកម្មសិទ្ធិករមានកម្រិត

សហកម្មសិទ្ធិករមានកម្រិតត្រូវបានហាមឃាត់មិនឲ្យចូលរួមក្នុងការគ្រប់គ្រងអាជីវកម្មក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតឡើយ។ ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅពុំអាចបំពេញការងារពាណិជ្ជកម្មទៅមុខបានដោយមូលហេតុណាមួយនោះ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃជំនួសបានជាប្រយោជន៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតក្នុងការដំណើរការសកម្មភាពពាណិជ្ជកម្ម [25] ។ តែទោះបីជាយ៉ាងណាក៏ដោយពួកគេនៅតែទទួលបានសិទ្ធិមួយចំនួនក្នុងក្រុមហ៊ុននេះ ដូចជាការទទួលបានព័ត៌មាន ពិគ្រោះយោបល់ ទទួលបានប្រាក់ចំណេញ និងអាចផ្ទេរភាគហ៊ុនរបស់ខ្លួនទៅឲ្យអ្នកដទៃបាន។

[22] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៣។
[23] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣០។
[24] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៣។
[25] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨០។

**២.១. សិទ្ធិទទួលបានព័ត៌មាន និងពិគ្រោះយោបល់**

សហកម្មសិទ្ធិករមានកម្រិតអាចទទួលព័ត៌មានពីសៀវភៅគណនី និងឯកសារក្រុមហ៊ុនពីការរីកចំរើនក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន[26] ។ វាជាសិទ្ធិដែលសហកម្មសិទ្ធិករមានកម្រិតត្រូវតែទទួលបានព្រោះពួកគេក៏ជាសមាជិកម្នាក់នៅក្នុងក្រុមហ៊ុនដែរ ដូចនេះការទទួលបានព័ត៌មានទាក់ទងនឹងស្ថានការណ៍របស់ក្រុមហ៊ុនជារឿងមួយចាំបាច់សម្រាប់ពួកគេ។ តាមរយៈព័ត៌មានដែលទទួលបាន សហកម្មសិទ្ធិករមានកម្រិត អាចលើកជាគំណិត យោបល់ចំពោះប្រតិបត្តិការអាជីវកម្មក្រុមហ៊ុន ដាក់ជូនសហកម្មសិទ្ធិករទូទៅ និងអភិបាល ដើម្បីធ្វើការពិគ្រោះក្នុងគោលដៅដើម្បីផលប្រយោជន៍ក្រុមហ៊ុន នៅក្នុងមហាសន្និបាតបាន។

**២.២. សិទ្ធិចំពោះប្រាក់ចំណេញ**

សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗមានសិទ្ធិទទួលបានចំណែកនៃប្រាក់ចំណេញរបស់ខ្លួន។ តែក្នុងករណីដែលការផ្តល់ជូនប្រាក់ចំណេញនោះធ្វើឲ្យមានឱនភាពនៃដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិត សហានកម្មសិទ្ធិករមានកម្រិតដែលទទួលបានប្រាក់នោះត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញនោះចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញដើម្បីទប់ទល់ឱនភាពនៃភាគទុននោះ។ ពួកគេមានសិទ្ធិទទួលបានប្រាក់ចំណេញដែលបានប្រតិបត្តិពាណិជ្ជកម្មរបស់ក្រុមហ៊ុនតាមសមមាត្រហ៊ុនដែលពួកគេបានចូលរួម ឬក៏ទទួលបានប្រាកចំណេញដោយមិនសមមាត្របើមានកំណត់ដាក់លាក់ក្នុងកិច្ចសន្យា។ លើសពីនេះទៅទៀតក្នុងករណីដែលសហកម្មសិទ្ធិករមានកម្រិតជានិយោជិតនោះ ខ្លួនអាចទទួលបានប្រាក់បៀវត្សពីក្រុមហ៊ុនសហកម្មសិទ្ធិបានតាមរយៈកិច្ចសន្យាការងារអាស្រ័យលើផលប្រយោជន៍របស់ក្រុមហ៊ុន និងភាពប៉ិនប្រសប់របស់សហកម្មសិទ្ធិករមានកម្រិតនោះ[27]។

**២.៣. សិទ្ធិធ្វើអនុប្បទាន**

វាពុំមានការរឹតត្បិតខ្លាំងចំពោះការផ្ទេរដើប្រយោជន៍របស់សហកម្មសិទ្ធិករមានកម្រិត ដូចសហកម្មសិទ្ធិករទូទៅទេ។ សហកម្មសិទ្ធិការមានកម្រិតមានសិទ្ធិពេញលេញដើម្បីធ្វើការផ្ទេរអត្តប្រយោជន៍របស់ខ្លួនបាន នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដ៏ទៃទៀតឡើយ។ រីឯក្នុងទំនាក់ទំនងជាមួយតតិយជនទោះបីជា

[26] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៩ កថាខណ្ឌទី២។
[27] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧០, ៧១, ៧២។

ខ្លួនបានផ្ទេរអត្ថប្រយោជន៍រួចហើយក៏ដោយ ក៏ខ្លួននៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិត[28]។

## ៣. សិទ្ធិរបស់សមាជិកហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

### ៣.១. សិទ្ធិធ្វើអន្តរាគមន៍ និងទទួលបានព័ត៌មានក្រុមហ៊ុន

ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចចូលរួមក្នុងមហាសន្និបាទប្រចាំឆ្នាំក្រុមហ៊ុន តាមការកោះប្រជុំ និង ការកំណត់របស់អភិបាល។ មិនតែប៉ុណ្ណោះម្ចាស់ហ៊ុនទាំងឡាយ អាចធ្វើសំណូមពរទៅអភិបាលឲ្យកោះប្រជុំមហាសន្និបាទម្ចាស់ភាគហ៊ុន តាមគោលបំណងដែលបានបញ្ជាក់នៅក្នុងសំណើរបស់ខ្លួននោះ ដោយមានការស្នើសុំពីម្ចាស់ភាគហ៊ុនដែលកាន់ប័ណ្ណភាគហ៊ុន ឬមានសិទ្ធិបោះឆ្នោតដែលមានសម្លេងមិនតិចជាង ៥១% ។ ម្ចាស់ហ៊ុនដែលមានមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាទប្រចាំឆ្នាំអាច ស្នើសុំឲ្យក្រុមហ៊ុនពិនិត្យនូវសេចក្ដីជូនដំណឹងស្ដីពីប្រធានបទមួយដែលខ្លួនស្នើ និងពិភាក្សាវែកញែក ពីប្រធានបទមួយដែលសមស្របទៅនឹងសំណូមពររបស់ខ្លួន[29]។

សមាជិកហ៊ុននីមួយៗ ក៏មានសិទ្ធិពិនិត្យ និងទទួលបាននូវឯកសារដែលពាក់ព័ន្ធទៅនឹងជីវភាពក្រុមហ៊ុន នៅឯទីស្នាក់ការដែលបានចុះបញ្ជី នៅអំឡុងម៉ោងធ្វើអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ហើយអាចធ្វើសម្រង់បានដោយមិនគិតកម្រៃ[30]។ ឯកសារទាំងនោះមានដូចជា របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ កំណត់ហេតុរបស់មហាសន្និបាទ បញ្ជីឈ្មោះម្ចាស់ភាគហ៊ុនទាំឡាយ បញ្ជីសារពើពន្ធ ឯកសារឧបសម្ព័ន្ធ។

### ៣.២. សិទ្ធិចំពោះប្រាក់ចំណេញ

ម្ចាស់ហ៊ុននីមួយៗនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត មានសិទ្ធិទទួលបានប្រាក់ចំណេញទៅតាមសមមាត្រនៃភាគហ៊ុនដែលពួកគេបានចូលរួមក្នុងក្នុងក្រុមហ៊ុន ឬក៏មិនសមមាត្រទៅតាមចំណែកភាគហ៊ុនដោយសារមានការចែងនៅក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង។ ដោយការរឹតត្បិតនៃលក្ខន្តិកៈក្រុមហ៊ុន អភិបាលអាចចាត់ចែងប្រាក់បម្រុងពិសេសមួយភាគ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដោយប្រើប្រាស់មូលនិធិណាមួយដែលមានសម្រាប់

[28] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៨។

[29] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២០៧, ២១៦។

[30] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១១០។

បែងចែកភាគលាភ។ ក្រុមហ៊ុនអាចបែងចែកភាគលាភ ដោយធ្វើការបោះចេញជាប័ណ្ណភាគហ៊ុនក្រុមហ៊ុន ឬបែងចែកភាគលាភជាសាច់ប្រាក់ ឬជាទ្រព្យសម្បត្តិទៅឲ្យសមាជិកបាន[31]។ ប្រសិនបើប័ណ្ណភាគហ៊ុនត្រូវបានបោះចេញដើម្បីទូទាត់ភាគលាភ ចំនួនភាគលាភដែលបានប្រកាសបញ្ជាក់ចំនួនសាច់ប្រាក់ត្រូវបន្ថែមទៅក្នុងគណនីដើមទុន ឬត្រូវបានរក្សាទុកសម្រាប់ប្រភេទ ឬស៊េរីនៃប័ណ្ណភាគហ៊ុនដែលបានបោះចេញដើម្បីទូទាត់ភាគលាភ[32]។

ភាគលាភមិនអាចបែងចែកបានទេប្រសិនបើមានហេតុផលថា ក្រោយការបែងចែកភាគលាភ ក្រុមហ៊ុនគ្មានលទ្ធភាពសងបំណុលដែលមាន ឬតម្លៃដែលអាចប៉ាន់ស្មានបាននៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតិចជាងបំណុល និងដើមទុនតប្រកាសរបស់ភាគហ៊ុនគ្រប់ប្រភេទ[33]។ ការបង្កើតប្រាក់ចំណេញប្រឌិត ដើម្បីបែងចែកឲ្យម្ចាស់ភាគហ៊ុនត្រូវហាមឃាត់ ហើយបុគ្គលដែលប្រព្រឹត្តត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ ម្ចាស់ភាគហ៊ុនមានសិទ្ធិទទួលបានប្រាក់ចំណេញ ឬភាគលាភនៅក្រោយពេលដែលមានការអនុម័តយល់ព្រមលើគណនីនៃកាលបរិច្ឆេទដែលបានប្រព្រឹត្តកន្លងទៅ នៅមហាសន្និបាតប្រចាំឆ្នាំ។

### ៣.៣. សិទ្ធិក្នុងការធ្វើអនុប្បទាន

មាត្រា ៨៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានហាមឃាត់មិនឲ្យក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតលក់ភាគហ៊ុនជាសាធារណៈទេ ហើយក៏បានរឹតត្បិតការធ្វើអនុប្បទានភាគហ៊ុន ទៅឲ្យតតិយជនផងដែល។ តែទោះបីជាយ៉ាងនេះក្តី ការធ្វើអនុប្បទានភាគហ៊ុនរទៅសមាជិកភាគហ៊ុន សមាជិកគ្រួសារម្ចាស់ភាគហ៊ុន និងអ្នកគ្រប់គ្រង មានលក្ខណៈងាយស្រួល។

រាល់សមាជិកភាគហ៊ុន អាចធ្វើអនុប្បទានផ្នែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ខ្លួនបានដោយសេរី និងគ្រប់ពេលវេលាទៅកាន់សមាជិកភាគហ៊ុនដូចគ្នា សហព័ទ្ធ និងញាតិលោហិត។ រីឯការធ្វើអនុប្បទានទៅឲ្យតតិយជនក្រៅពី សមាជិកភាគហ៊ុន សហព័ទ្ធ ឬញាតិលោហិត ត្រូវមានការសម្រេចដោយសំឡេងភាគច្រើន ៥០% + ១ ឬ សំឡេងឯកច្ឆន្ទនៃសមាជិកភាគហ៊ុនដទៃទៀតតាមការកំណត់ក្នុងលក្ខន្តិកៈ។ រាល់ការធ្វើអនុប្បទានត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ជាលិខិតឯកជន ឬសាការី ដើម្បីមានប្រសិទ្ធភាពជាមួយក្រុមហ៊ុន និងតតិយជន ហើយត្រូវតម្កល់លិខិតនោះ

[31] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៥៧-១៥៩។
[32] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៦០។
[33] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៥៨។

នៅទីស្នាក់ការក្រុមហ៊ុន និងការិយាល័យចុះបញ្ជីពាណិជ្ជកម្ម និង ត្រូវចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់។

បំណងធ្វើអនុប្បទានទៅឲ្យតតិយជន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមហ៊ុនដើម្បីសម្រេច។ ប្រសិនបើក្រុមហ៊ុនជំទាស់ការធ្វើអនុប្បទានទៅកាន់តតិយជន ក្រុមហ៊ុនត្រូវទិញយក ឬជូនដំណឹងឲ្យសមាជិកដទៃទៀតទិញយកភាគហ៊ុននោះ។ តែបើកក្នុងកំឡុងពេល ៣ ខែ នៅតែមិនមានការឆ្លើយតបណាមួយទេ ការធ្វើអនុប្បទានទៅឲ្យតតិយជនអាចប្រព្រឹត្តទៅបាន

### ៣.៤. សិទ្ធិធ្វើសហប្រតិបត្តិការក្នុងក្រុមហ៊ុន

កិច្ចសហប្រតិបត្តិការក្នុងារគ្រប់គ្រងក្រុមហ៊ុនរបស់សមាជិកភាគហ៊ុន ដែលមិនត្រូវបានតែងតាំងជាអភិបាល គឺការចូលរួមគ្រប់គ្រងក្រុនហ៊ុនដោយប្រយោល។ សមាជិកហ៊ុនអាចចូលរួមក្នុងកិច្ចការគ្រប់គ្រងតាមរយៈ៖

- ការចូលរួមក្នុងមហាសន្និបាទប្រចាំឆ្នាំ (សមាជិកអាចផ្តល់សិទ្ធិនេះ ឲ្យបុគ្គលណាមយយផ្សេងទៀតធ្វើជាតំណាង តាមរយៈលិខិតជាលាយលក្ខន៍អក្សរ និងមានសុពលភាពមិនលើសពីមួយឆ្នាំចាប់ពីថ្ងៃចុះហត្ថលេខាប្រគល់សិទ្ធិ)[34]
- ការសម្រេចលើសេចក្តីសម្រេចដែលហួសពីអំណាចអ្នកចាត់ការ
- ការពិគ្រោះយោបល់ជាលាយលក្ខណ៍អក្សរ
- ការបោះឆ្នោតសម្រេចលើការកែប្រែលក្ខន្តិកៈ ជ្រើសរើស និងដកដំណែងអភិបាល ឬសវនករ។

## កថាភាគទី ២៖ ភាតព្វកិច្ចរបស់សមាជិកហ៊ុន

### ១. ភាតព្វកិច្ចរបស់សហកម្មសិទ្ធិករទូទៅ

តាមរយៈនិយមន័យនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រង និង មានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុន និងមិនធ្វើការប្រគួតប្រជែងណាមួយដែលនាំឲ្យមានការខាតបង់ប្រយោជន៍ចំពោះក្រុមហ៊ុនឡើយ។ ក្រៅពីនោះសហា

[34] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២១៩។

កម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលខុសត្រូវរួមគ្នាផង និងដាច់ដោយឡែកពីគ្នាផង នូវកាតព្វកិច្ចទាំងអស់របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត[35]។

### ១.១. ភាតព្វកិច្ចទទួលខុសត្រូវចំពោះបំណុលគ្មានកម្រិត

ការទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនជាកាតព្វកិច្ចចម្បងបង្អស់របស់សហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានក្រិត ក្រៅពីកាតព្វកិច្ចដែលប្រគល់ឲ្យគ្រប់គ្រងក្រុមហ៊ុន។ ការទទួលខុសត្រូវនេះ គឺជាការទទួលខុសត្រូវគ្មានកម្រិតទៅតាមសមមាត្រនៃចំណែកភាគហ៊ុនក្នុងមូលធនក្រុមហ៊ុនឡើយ។ កាលណាទ្រព្យសម្បត្តិក្រុមហ៊ុន មិនអាចសងទៅម្ចាស់បំណុលបានគ្រប់ទេ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវមានកាតព្វទទួលខុសត្រូវចំពោះបញ្ហានេះ ដោយពួកគេត្រូវលក់បេតិកភ័ណ្ឌផ្ទាល់ខ្លួនដើម្បីសងបំណុល (សហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវត្រឹមកម្រិតភាគហ៊ុនប៉ុណ្ណោះ)។ សហកម្មសិទ្ធិករទូទៅកំបាំងមុខ ដែលមិនប្រកាសចេញមុខដោយក្រុមហ៊ុនក៏ត្រូវទទួលខុសត្រូវចំពោះតតិយជនទាំងនូវរាល់កាតព្វកិច្ចដូចសហកម្មសិទ្ធិករដទៃទៀតដែរ [36] ។ ម្ចាស់បំណុលមានឯកសិទ្ធិក្នុងការជ្រើសរើសសហកម្មសិទ្ធិករទូទៅណាម្នាក់ដែលមានលទ្ធភាពសងបំណុល ជំនួសសហកម្មសិទ្ធិករដទៃទៀតបាន ហើយសហកម្មសិទ្ធិទូទៅដែលទទួលអនុវត្តកាតព្វនេះ នឹងក្លាយជាម្ចាស់បំណុលសហកម្មសិទ្ធិករទូទៅផ្សេងទៀតនៅក្នុងក្រុមហ៊ុន។

ចំពោះសហកម្មសិទ្ធិករទូទៅថ្មី ក៏ត្រូវទទួលសខុសត្រូវចំពោះបំណុលដែលបានកើតឡើងមុនពេលពួកគេបានចូលរួមក្រុមហ៊ុនដែរ ប៉ុន្តែការសងនោះត្រូវគិតតែចំពោះទ្រព្យសម្បត្តិក្រុមហ៊ុនប៉ុណ្ណោះ ដោយមិនឲ្យមានការប៉ះពាល់ដល់បេតិកភ័ណ្ឌផ្ទាល់របស់សហកម្មសិទ្ធិករទូទៅថ្មីឡើយ លើកលែងតែពួកគេបានព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនសិន[37]។

### ១.២. ភាតព្វកិច្ចទទួលខុសត្រូវចំពោះបំណុលរបស់សហកម្មសិទ្ធិករមានកម្រិត

សហកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនត្រឹមតែទទួលខុសត្រូវចំពោះបំណុលរបស់ខ្លួន និងក្រុមហ៊ុនប៉ុណ្ណោះទេ ពួកគេត្រូវមាននកាតព្វកិច្ចត្រូវទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិទាំងឡាយរបស់សហកម្មសិទ្ធិមានកម្រិតដែលមាននៅក្នុងដើមទុនក្រុមហ៊ុនផង

[35] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤២។

[36] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤៦។

[37] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥,មាត្រា៤៣។

ដែរ[38]។ វាជាបន្ទុកដ៏ធំមួយដែលសហកម្មសិទ្ធិករទូទៅមានចំពោះសមាជិកទាំងអស់នៅក្នុងក្រុមហ៊ុន។

## ២. ភាតព្វកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត

### ២.១. ភាតព្វកិច្ចបង់ភាគទុន

ការបង់ភាគហ៊ុនទៅឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺជាកាតព្វមួយដែលសហកម្មសិទ្ធិករមានកម្រិតត្រូវតែបំពេញ។ សហកម្មសិទ្ធិករមានកម្រិតអាចទទួលបានសមាជិកភាពនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន តាមរយៈការចូលរួមភាគហ៊ុន ដូច្នេះពួកគេត្រូវតែបង់ភាគហ៊ុនចូលទៅក្នុងមូលធនក្រុមហ៊ុនតាមចំណែកដែលខ្លួនបានសន្យានៅពេលបង្កើតកិច្ចសន្យាក្រុមហ៊ុន។ ការបង់ភាគហ៊ុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬ ជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ ហើយសហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា[39]។ សហកម្មសិទ្ធិករមិនត្រូវបានអនុញ្ញាតឲ្យចូលរួមភាគទុន ជាភាគហ៊ុនជំនាញទេ។

### ២.២. ភាតព្វទទួលខុសត្រូវចំពោះបំណុល

សហកម្មសិទ្ធិករមានកម្រិតត្រូវទទួលខុសត្រូវត្រឹមតែចំនួនទឹកប្រាក់ ឬតម្លៃនៃទ្រព្យសម្បត្តិដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុនក្នុងក្រុមហ៊ុនប៉ុណ្ណោះ ហើយម្ចាស់បំណុលពុំមានសិទ្ធិរឹបអូសបេតិកភ័ណ្ឌផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករមានកម្រិតបានឡើយ[40]។ នេះជាលក្ខណៈពិសេសមួយដែលពួកគេទទួលបាន។ តែទោះបីជាយ៉ាងនេះក្តី ពួកគេត្រូវទទួលខុសត្រូវដោយផ្ទាល់រាល់កាតព្វកិច្ចដែលបានធ្វើឡើងដោយការចរចាកិច្ចការពាណិជ្ជកម្មក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតដោយគ្មានការអនុញ្ញាតឲ្យធ្វើជាភ្នាក់ងារក្រុមហ៊ុន ឬ មិនអនុញ្ញាតឲ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុន។ វាអាចជាការទទួលខុសត្រូវដោយគ្មានកម្រិត ឬ លើសពីកម្រិតដែលមាននៅក្នុងភាគហ៊ុនក្រុមហ៊ុន។ ក្រៅពីនេះ សហកម្មសិទ្ធិករមានកម្រិតដែលមានឈ្មោះក្នុងនាមករណ៍ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិដូចជាសហកម្មសិទ្ធិការទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានកំណត់ច្បាស់លាស់[41]។

[38] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៤។
[39] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧០។
[40] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨២។
[41] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៧៣, ៧៩។

### ៣. ភាតព្វកិច្ចរបស់សមាជិកហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

នៅពេលដែលសមាជិកភាគហ៊ុននីមួយៗយល់ព្រមបង្កើតជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ពួកគេនឹងមានកាតព្វកិច្ចជាមួយក្រុមហ៊ុន។ ពួកគេត្រូវតែបង់ចំណែកទុនដែលបានសន្យាចូលរួម ទទួលខុសត្រូវចំពោះបំណុល និងមិនត្រូវប្រព្រឹត្តទង្វើណាដែលគេហាមឃាត់។

#### ៣.១. ភាតព្វកិច្ចទទួលខុសត្រូវចំពោះបំណុលចំពោះបំណុល

សមាជិកភាគហ៊ុនម្នាក់ៗត្រូវទទួលខុសត្រូវចំពោះបំណុលរបស់ក្រុមហ៊ុន។ ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនទាំងឡាយចំពោះបំណុលនៅក្នុងក្រុមហ៊ុន គឺមានកម្រិតត្រឹមតែលើតម្លៃជាវភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗប៉ុណ្ណោះ [42] ។ ម្ចាស់បំណុលមិនអាចរឹបអូសទ្រព្យសម្បត្តិផ្ទាល់របស់សមាជិកភាគហ៊ុនឡើយ។

#### ៣.២. ភាតព្វកិច្ចមិនប្រកួតប្រជែងក្នុងក្រុមហ៊ុន

ជាគោលការណ៍ សមាជិកភាគហ៊ុននៅក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតទាំងអស់មិនត្រូវអនុវត្តសកម្មភាពណាមួយដែលច្បាប់ និង លក្ខន្តិកៈរបស់ខ្លួនបានហាមឃាត់ឡើយ ជាពិសេសការប្រព្រឹត្តអំពើទាំងឡាយណាដែលជាសកម្មភាពប្រកួតប្រជែងទៅនឹងអាជីវកម្មរបស់ក្រុមហ៊ុន។

## ផ្នែកទី ៣៖ ការប្រព្រឹត្តទៅនៃអង្គការគ្រប់គ្រងក្រុមហ៊ុន

ក្រោយពេលដែលក្រុមហ៊ុនទទួលបានបុគ្គលិកលក្ខណៈគតិយុត្តពេញលេញហើយគឺខ្លួមត្រូវស្ថិតក្នុងដំណាក់កាលមួយបន្តអនុវត្តសកម្មភាពអាជីវកម្មរបស់ខ្លួន។ ការធ្វើពាណិជ្ជកិច្ចគឺមានលក្ខណៈស្មុកស្មាញប្រសិនបើពុំមានភាពច្បាស់លាស់ទាក់ទងនិង ការបែងចែកតួនាទី អំណាច និងទំនួលខុសត្រូវផ្នែកការងារជាដើម។ វាចាំបាច់ត្រូវមានការគ្រប់គ្រងដំណើរការប្រព្រឹត្តទៅនៃក្រុមហ៊ុននីមួយៗ។

[42] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៤៧។

## កថាភាគទី ១៖ ការប្រព្រឹត្តទៅនៃអង្គការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

### ១. អភិបាល

#### ១.១. ការជ្រើសតាំង

ជាទូទៅសហកម្មសិទ្ធិករទូទៅជាអ្នកគ្រប់គ្រង ចាត់ការ លើក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ប៉ុន្តែក្នុងកិច្ចសន្យាក៏អាចចែងផងដែរពីអ្នកគ្រប់គ្រងមួយ ឬច្រើនដែលត្រូវបានជ្រើសរើសសមាជិកខាងក្រៅក្រុមហ៊ុន។ ការជ្រើសតាំងនេះពុំត្រូវបានអនុញ្ញាជូនសហកម្មសិទ្ធិមានកម្រិតនោះទេព្រោះសិទ្ធិរបស់សហកម្មសិទ្ធិករមានកម្រិតនៅមានព្រំដែន ដែលច្បាប់បានហាមមិនឲ្យសហកម្មសិទ្ធិករប្រភេទនេះជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរបស់ក្រុមហ៊ុន ឬការងារខាងក្រៅពោលគឺការមានទំនាក់ទំនងជាមួយតតិយជន។

#### ១.២. អាណត្តិ និងការដកហូតដំណែង

គេពុំឃើញមានច្បាប់ចែងអំពីអាណត្តិរបស់អ្នកចាត់ការឡើយ។ ដូច្នេះចិរៈវេលានៃអ្នកចាត់ការត្រូវតែកំណត់នៅក្នុងកិច្ចសន្យា។ ប្រសិនបើកិច្ចសន្យាពុំបានចែងនោះទេមានន័យថាអណត្តិរបស់អ្នកចាត់ការគឺស្មើទៅនិងចិរៈវេលារបស់ក្រុមហ៊ុន។

អ្នកចាត់ការត្រូវបានតែតាំងដោយសហកម្មសិទ្ធិករទូទៅទាំងឡាយហើយក៏អាចត្រូវបានដកហូតចេញពីមុខដំណែងដោយសម្លេងភាគច្រើនដោយប្រៀបនៃវត្តមានរបស់សហកម្មសិទ្ធិករទូទៅផងដែរលើកលែងតែមានចែងផ្សេងក្នុងកិច្ចសន្យា។ រីឯការបញ្ចប់តួនាទីរបស់អ្នកចាត់ការនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺអាចបណ្តាលមកពីមូលហេតុមួយចំនួនដូចជា៖

- ការមកដល់នៃពេលវេលាក្រុមហ៊ុន
- មរណភាព អសមត្ថភាព ការសុំលាលែង មូលហេតុនៃជំងឺផ្សេងៗ របស់អ្នកចាត់ការ
- ការបញ្ឈប់អាជីវកម្មរបស់ក្រុមហ៊ុន និងធនក្ស័យបុគ្គលជាដើម។

#### ១.៣. សិទ្ធិអំណាច និងការទទួលខុសត្រូវ

អំណាចរបស់អ្នកចាត់ការត្រូវដាក់បញ្ចូលទៅក្នុងកិច្ចសន្យាហើយត្រូវចែងអំពីអំណាចរបស់អ្នកចាត់ការឲ្យបានទូលំទូលាយ។ ផ្ទុយទៅវិញប្រសិនបើកិច្ចសន្យាពុំបានចែងនោះទេអ្នកចាត់ការត្រូវបំពេញកិច្ចគ្រប់គ្រងក្រុមហ៊ុនជាប្រយោជន៍របស់ក្រុមហ៊ុន។ អ្នកចាត់ការត្រូវទទួលខុសត្រូវចំពោះមុខតតិយជន ក្នុងករណីដែលអ្នកចាត់ការនោះបានប្រព្រឹត្តអំពើក្លែងបន្លំ។ និងទទួលខុសត្រូវ

ចំពោះក្រុមហ៊ុនក្នុងករណីដែលមានកំហុសធ្ងន់ក្នុងពេលគ្រប់គ្រងក្រុមហ៊ុន ចំពោះការរំលោភអំណាច ជាពិសេសការរំលោភលើកិច្ចសន្យាក្រុមហ៊ុន។

ករណីដែលអ្នកចាត់ការបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដូចជា៖ ការរំលោភលើទំនុកចិត្ត ឬការឆបោកជាដើមទៅលើក្រុមហ៊ុន ឬតតិយជនក្តី។ ដូច្នេះខ្លួនត្រូវប្រឈមមុខទៅនឹងទោសកម្មជាដាច់ខាត។

## ២. មហាសន្និបាត

មហាសន្និបាតក្រុមហ៊ុនត្រូវធ្វើឡើងក្នុងករណីដែលអភិបាល ឬ សហកម្មសិទ្ធិករទូទៅណាម្នាក់មិនអាចសម្រេចលើកិច្ចណាមួយ ដែលតម្រូវឲ្យមានការបោះឆ្នោតសម្រេចពីសហកម្មសិទ្ធិករទាំងអស់ដែលបានចូលភាគទុន។

### ២.១. ការកោះប្រជុំ

នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតការកោះប្រជុំអាចធ្វើបានតាមពីរករណី[43]៖

- ករណីដែលក្នុងកិច្ចសន្យាក្រុមហ៊ុនពុំបានចែង សហកម្មសិទ្ធិករទូទៅ ឬសហកម្មសិទ្ធិករមានកម្រិតដែលមានដើមទុន ១/៤ ក្នុងក្រុមហ៊ុនអាចធ្វើការស្នើសុំអំពីការប្រជុំនេះអំពីបញ្ហាដែលកើតមានឡើង ហើយត្រូវសម្រេចតាមរយៈការបោះឆ្នោតក្នុងមហាសន្និបាតរបស់សហកម្មសិទ្ធិករទូទៅ។
- អ្នកចាត់ការក្រុមហ៊ុនមានសិទ្ធិផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិតយ៉ាងហោចណាស់ ២០ថ្ងៃ មុនថ្ងៃបើកមហាសន្និបាត។

### ២.២. លក្ខខណ្ឌកូរ៉ុម និង របបនៃសេចក្តីសម្រេច

ចំនួន ១៥% នៃអំណាចបោះឆ្នោតទាំងអស់របស់សហកម្មសិទ្ធិករទូទៅ និងរបស់សហកម្មសិទ្ធិករមានកម្រិត ត្រូវបានចាត់ទុកជាលក្ខខណ្ឌកូរ៉ុមដើម្បីឲ្យការសម្រេចនៅក្នុងមហាសន្និបាតអាចយកជាការបាន។ ក្នុងករណីដែលមហាសន្និបាតលើកទី១ មិនទទួលបានគូរ៉ុមគ្រប់គ្រាន់តាមចំនួនទេ ការកោះប្រជុំលើកទីពីរត្រូវបានធ្វើឡើងក្នុងរយៈពេលយ៉ាងហោចណាស់ក្រោយ ២០ថ្ងៃគិតចាប់ពីកាលបរិច្ឆេតមហាសន្និបាតលើកទី១។ មហាសន្និបាតលើកទី២ នេះយកជាការបានលុះត្រាតែមានគូរ៉ុមយ៉ាងតិច ១/៣ នៃអំណាចបោះឆ្នោតរបស់សហកម្មសិទ្ធិករទូទៅ និងរបស់សហកម្មសិទ្ធិករមានកម្រិត។ ការកំណត់កូរ៉ុមអាចមានចំនួនលើសពីនេះបានតែមិនអាចឲ្យទាបជាងនេះទេ។

[43] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ២០៥។

ចំពោះរបបនៃសេចក្តីសម្រេចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវកំណត់យកសំលេងភាគច្រើនដាច់ខាត (៥០% + ១) នៃអំណាចបោះឆ្នោតទាំងអស់របស់សហកម្មសិទ្ធិករទូទៅដែលមានវត្តមានក្នុងមហាសន្និបាត ប៉ុន្តែកិច្ចសន្យាអាចចែងខុសពីនេះបាន។ ការសម្រេចដោយសំលេងភាគច្រើនដាច់ខាតគឺជាលក្ខខណ្ឌសុពលចំពោះសេចក្តីសម្រេចសាមញ្ញដែលពុំមានការកែប្រែដោយផ្ទាល់ ឬដោយប្រយោលទៅលើកិច្ចសន្យាកិច្ចសន្យាបង្កើតកក្រុមហ៊ុន។ សមាជិកទាំងអស់ត្រូវមានការព្រមព្រៀងជាឯកច្ឆន្ទ ដែលជាសេចក្តីសម្រេចវិសាមញ្ញ ចំពោះបញ្ហាមួយចំនួនដូចជា៖

- មានការផ្លាស់ប្តូរសញ្ញាតិក្រុមហ៊ុន និងនាំទៅរកការបង្កើតកិច្ចព្រមព្រាងរបស់សហកម្មសិទ្ធិករទូទៅ
- មានការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន និងកែប្រែកិច្ចសន្យាបង្កើតក្រុមហ៊ុន
- ការបន្តអាយុជីវិតក្រុមហ៊ុន និងការបង្កើតមូលធនក្រុមហ៊ុន

ការផ្លាស់ប្តូរទាំងនេះទាមទារឲ្យមានការចុះផ្សាយជាសាធារណៈ។

### ២.៣. កំណត់ហេតុ

កំណត់ហេតុក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបានធ្វើឡើងនៅពេលមាន ការពិភាក្សា ឬ ការពិគ្រោះយោបល់អាជីវកម្មរបស់សមាជិកហ៊ុន។ សហកម្មសិទ្ធិករទូទៅទាំងឡាយត្រូវរក្សាទុកនូវកំណត់ហេតុ ដែលមានឈ្មោះអាសយដ្ឋានរបស់សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗនិងព័ត៌មានដែលទាក់ទងនិងការបង់ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះ។ កំណត់ត្រូវធ្វើតាមទម្រង់បែបបទ ដែលមានកំណត់អំពីខ្លឹមសារ និងមានហត្ថលេខាសមាជិក ហើយត្រូវរក្សាទុកឯកសារកាលប្បវត្តរបស់ក្រុមហ៊ុននៅទីស្នាក់ការក្រុមហ៊ុន។

## ៣. សវនករ

នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមិនមានបញ្ញត្តិណាមួយដែលបានចែងអំពីសវនករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតទេ។ ប៉ុន្តែគោលការណ៍ និងបញ្ញត្តិនៃអនុក្រឹត្យ លេខ ៤២ អនក្របក ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ និង ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និង វិជ្ជាជិវៈគណនេយ្យ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវរៀបចំឲ្យមានការតែងតាំងសវនករ។ កិច្ចសន្យាបង្កើតក្រុមហ៊ុនត្រូវចែងពីចំណុចនេះ។

### ៣.១. ការតែងតាំង និងបញ្ចប់តួនាទី

សហកម្មសិទ្ធិទាំងអស់នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវជ្រើសតាំងសវនករមួយរូប ដែលបានចុះបញ្ជីសវនករ ហើយមិនជាប់នឹងញាតិលោហិត ឬជាសហព័ទ្ធសមាជិកហ៊ុន

និងមិនមានតួនាទីជាអ្នកចាត់ការនៅក្នុងក្រុមហ៊ុន។ ក្នុងករណីដែលសហកម្មសិទ្ធិករមិនអាចជ្រើសរើសសវនករបាន ក្រុមហ៊ុនអាចស្នើសុំទៅតុលាការដើម្បីចាត់តាំងបេក្ខភាពសវនករជំនួសបាន។

សវនករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវបញ្ចប់តួនាទីរបស់ខ្លួននៅពេលអស់អាណត្តិដែលបានកំណត់។ តំណែងសវនករអាចត្រូវបានដកហូតគ្រប់ពេលវេលាក្នុងករណីដែលគេពិនិត្យឃើញថាបានប្រព្រឹត្តកំហុសដោយការធ្វេសប្រហែស ខ្ជីខ្ជា ឬ កេងបន្លំមូលនិធិក្រុមហ៊ុន។

### ៣.២. តួនាទី និងការទទួលខុសត្រូវ

តួនទីសំខាន់របស់សវនករគឺត្រូវធ្វើការត្រួតពិនិត្យ លើចំនុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនសហកម្មសិទ្ធិករលើរបាយការហិរញ្ញវត្ថុ។ សវនករអាចស្នើឲ្យអភិបាល អ្នកគ្រប់គ្រងបុគ្គលិក សហកម្មសិទ្ធិករទូទៅ ឬភ្នាក់ងារក្រុមហ៊ុន ផ្តល់ព័ត៌មាន ការបកស្រាយ សៀវភៅបញ្ជី និងកំណត់ហាហេតុ សម្រាប់បំពេញមុខងាររបស់ខ្លួន។ សវនករ ក៏ទទួលបានសិទ្ធិចូលរួមក្នុងមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីដឹងឮនូវកម្មវត្ថុដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន។

ចំពោះការទទួលខុសត្រូវវិញ សវនករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តឡើង។ វាអាចជាការទទួលខុសត្រូវខាងរដ្ឋប្បវេណីដោយការសងសំណងទៅក្រុមហ៊ុន និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលកើតចេញពីបទល្មើសព្រហ្មទណ្ឌដូចជា ការឆបោក ការរំលោភសេចក្តីទុកចិត្ត ឬការប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់ខ្លួន។

## កថាភាគទី ២៖ ការប្រព្រឹត្តទៅនៃអង្គការគ្រប់គ្រងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

### ១. អភិបាល

អភិបាលនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតគឺជារូបវន្តបុគ្គល ដែលត្រូវបានជ្រើសរើសដោយសមាជិកហ៊ុនដទាំអស់ដើម្បីទទួលភារកិច្ចដឹងនាំកិច្ចការ និងគ្រប់គ្រងជីវភាពក្រុមហ៊ុន។ សមត្ថភាពរបស់អភិបាលមិនត្រូវបានគេកំណត់យ៉ាងតឹងរឹងនោះទេ ដោយវាមិនទាមទារលក្ខណ

សម្បត្តិជាពាណិជ្ជករជាចាំបាច់ឡើយ។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតម្រូវឲ្យមានអភិបាលម្នាក់ ឬច្រើននាក់ តាមការចាំបាច់របស់ក្រុមហ៊ុន[44]។

### ១.១. ការជ្រើសតាំង

មាត្រា ១១៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានកំណត់ការជ្រើសរើសអភិបាលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតាមរយៈសេចក្តីសម្រេចសាមញ្ញ នៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ រាល់រូបវន្តបុគ្គល ដែលមានសមត្ថភាពមានអាយុលើសពី ១៨ ឆ្នាំ អាចបម្រើការជាអភិបាល ឬជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបាន។ អភិបាលមិនចាំបាច់ជាម្ចាស់ហ៊ុនទេ ឬ មិនចាំបាច់តម្រូវឲ្យមានលក្ខណសម្បត្តិណាផ្សេងទេ លើកលែងតែលក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឲ្យមាន។ តែជានិច្ចកាលក្រុមហ៊ុនត្រូវជ្រើសរើស បុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ ជាពិសេសគឺមានបទពិសោធខាងពាណិជ្ជកម្មយ៉ាងតិចពី ៣ ទៅ ៥ ឆ្នាំ និងជាបុគ្គល ដែលស្មោះត្រង់និង ធ្វើការងារដើម្បីប្រយោជន៍ក្រុមហ៊ុន ឲ្យធ្វើជាអភិបាល[45]។

### ១.២. អាណត្តិ និងការដកហូតដំណែង

អាណត្តិអភិបាលមានរយៈពេល ២ ឆ្នាំ ហើយអាចត្រូវបានបោះឆ្នោតសាជាថ្មីទៀតបាន តែអាណត្តិនេះអាចត្រូវបានកំណត់ផ្សេងពីនេះនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន។ អាណត្តិរបស់អភិបាលអាចត្រូវកំណត់ជាតំណាក់ៗ តែអាណត្តិរបស់អភិបាលទាំងឡាយមិនអាចបញ្ចប់ក្នុងឆ្នាំជាមយយគ្នាបានឡើយ[46]។ ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតអាចម្រេចដកហូតតំណែងអភិបាន ដោយសំឡេងភាគច្រើនដាច់ខាត ទោះជាមាន ឬគ្មានមូលហេតុនាមួយក៏ដោយ[47]។អភិបាលក៏អាចលាលែងពីតំណែងនៅពេលណាក៏បានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុន។ ការលាលែងពីតំណែងនេះ ត្រូវមានសុពលភាពភ្លាម ឬមានប្រសិទ្ធភាពចាប់ពីពេលដែលបានចែងនៅក្នុងលិខិតលាលែងនោះ។ អភិបាលត្រូវទទួលខុសត្រូវចំពោះការខូចខាតដល់ក្រុមហ៊ុនដោយសារការលាលែងនោះ។ បន្ទាប់ពីអាណត្តិរបស់ខ្លួនបានផុតកំណត់ អភិបាលត្រូវបន្តបម្រើការងាររបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសតាំងអភិបាលថ្មី[48]។

---

[44] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១១៨។
[45] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ២២៥។
[46] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១២១-១២២។
[47] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១២៣-១២៤។
[48] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១២៦។

### ១.៣. សិទ្ធិអំណាច និងការទទួលខុសត្រូវ

តាមរយៈច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងលលក្ខន្តិកៈរបស់ក្រុមហ៊ុន អភិបាលត្រូវបានគេប្រគល់សិទ្ធិអំណាចយ៉ាងទូលំទូលាយដើម្បីធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុន ប៉ុន្តែការអនុវត្តសិទ្ធិអំណាចរបស់ខ្លួនដែលហួសព្រំដែន គឺត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុន និងតតិយជន។

អភិបាលមានអំណាចគ្រប់គ្រាន់ជាតំណាងឲ្យក្រុមហ៊ុន និងធ្វើសកម្មភាពចុះហត្ថលេខារាល់កិច្ចការដែលស្ថិតនៅក្នុងរង្វង់ក្របខ័ណ្ឌនៃកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះតតតិយជន។ ការចុះកិច្ចសន្យារបស់អភិបាលលើកិច្ចសន្យាទាំងឡាយ ដែលស្ថិតនៅក្រៅកម្មវត្ថុអាជីវកម្មក្រុមហ៊ុន ក៏បណ្តាលក្រុមហ៊ុនជាប់កិច្ចសន្យាដែរ ប៉ុន្តែក្រុមហ៊ុនអាចបដិសេធមិនទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនដោយភស្តុតាងបញ្ជាក់ថា តតិយជនបានពីការហួសនៃកម្មវត្ថុអាចីវកម្មក្រុមហ៊ុន ឬបញ្ជាក់ថា តតិយជននោះ មិនអាចដោះសារថាខ្លួនមិនបានដឹងដោយកាលៈទេសៈ។ អភិបាលក៏ត្រូវបានប្រគល់សិទ្ធិអំណាចដើម្បីសម្របសម្រួលទំនាក់ទំនងជាមួយសមាជិកហ៊ុនផងដែរ។ អភិបាលអាចធ្វើការចាត់ចែងគ្រប់យ៉ាងដើម្បីផលប្រយោជន៍ក្រុមហ៊ុន។ អភិបាលត្រូវរៀបចំឲ្យមានមហាន្និបាតប្រចាំឆ្នាំ ជាពិសេសមហាន្និបាតវិសាមញ្ញនៅពេលដែលមានកិច្ចការមួយចំនួនដែលហួសពីសមត្ថកិច្ចអភិបាល និងទាមទារឲ្យមានការសម្រេចរបស់សមាជិកហ៊ុនទាំងអស់ ដូចជា ការទិញ លក់ ការដោះដូរ ដែលមានតម្លៃលើសពី ៥០% នៃដើមទុន និងសេចក្តីសម្រេចពិសេសដ៏ទៃទៀត។

ការប្រើប្រាស់អំណាចក្នុងប្រការណាមួយដែលផ្ទុយទៅនិងការកំណត់ ត្រូវចាត់ទុកជាមោឃៈនូវហត្ថលេខាបស់អភិបាល ហើយការការប្រព្រឹត្តល្មើសនេះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបច្ច័យដែលកើតឡើង។ អភិបាលត្រូវទទួលខុសត្រូវខាងរដ្ឋប្បវេណីជាបុគ្គល ឬសាម្ព័ភាពគ្នានៅចំពោះមុខក្រុមហ៊ុន និងតតិយជន ដោយការរំលោភបំពានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងកំហុសដែលបានប្រព្រឹត្តិក្នុងការគ្រប់គ្រង។ អភិបាលក៏អាចត្រូវចោទប្រកាន់នៅពេលដែលគេបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌទាក់ទងនឹងការគ្រប់គ្រងក្រុមហ៊ុន[49]។

## ២. មហាសន្និបាត

តាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតតម្រូវឲ្យមានការប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុនប្រចាំឆ្នាំ យ៉ាងតិចម្តងក្នុងមួយឆ្នាំ ហើយអភិបាល ឬក្រុម

[49] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ២២៨-២២៩។

ប្រឹក្សាភិបាលត្រូវរៀបចំមហាសន្និបាតម្ចាស់ភាគហ៊ុនលើទី ១ ក្នុងកំឡុងពេល ១២ខែបន្ទាប់ពីក្រុមហ៊ុនត្រូវបានបង្កើតឡើង។ សិទ្ធិកោះប្រជុំត្រូវបានផ្តល់ទៅឲ្យ អភិបាល សមាជិកភាគហ៊ុន និងសវនករ។

**២.១. ការកោះប្រជុំ**

ការកោះប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុនអាចត្រូវបានធ្វើឡើងតាមរយៈ ការស្នើរបស់អភិបាល ឬលិខិតស្នើសុំរបស់ម្ចាស់ភាគហ៊ុនមានសិទ្ធិក្នុងមហាសន្និបាត ដែលកាន់កាប់ប័ណ្ណភាគហ៊ុនមិនតិចជាង ៥១% នៃប័ណ្ណភាគហ៊ុនក្រុមហ៊ុនដែលបានបោះចេញ។ លិខិតស្នើសុំត្រូវមានចុះហត្ថលេខាម្ចាស់ភាគហ៊ុនម្នាក់ ឬច្រើននាក់ដែលមានបញ្ជាក់ពីគោលបំណងនៃការស្នើសុំកោះប្រជុំ។ ម្ចាស់ហ៊ុនដែលបានចុះហត្ថលេខាលើលិខិតស្នើសុំនោះ អាចកោះប្រជុំមហាសន្និបាតបានប្រសិនបើអភិបាលទាំងឡាយមិនបានកោះប្រជុំក្នុងពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានលិខិតស្នើសុំទេ[50]។

ទីកន្លែងប្រជុំមហាសន្និបាតម្ចាស់ភាគហ៊ុនត្រូវធ្វើណៅទីស្នាក់ការក្រុមហ៊ុន ឬនៅកន្លែងដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានចែងនៅក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឬតាមការកំណត់របស់អភិបាល ឬនៅក្រៅប្រទេសបើមានការយល់ព្រមពីម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោតទាំងអស់ [51] ។ លិខិតជូនដំណឹងប្រជុំមហាសន្និបាតជាលាយលក្ខណ៍អក្សរ ត្រូវផ្តល់ឲ្យម្ចាស់ហ៊ុន អភិបាល និងសវនករទាំងអស់ ក្នុងរយៈពេលពី ២០ ទៅ ៥០ ថ្ងៃ មុនកាលបរិច្ឆេទនៃមហាសន្និបាត ដោយមានកំណត់អំពីរបៀបវារៈ និងទីកន្លែងប្រជុំ[52]។

**២.២. របបនៃសេចក្តីសម្រេច**

ជាទូទៅសេចក្តីសម្រេចនៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុន អាចយកជាការបានដោយមានសំលេងភាគច្រើនដាច់ខាត ឬ៥០% + ១ នៃអំណាចបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុនដែលមានវត្តមាននៅក្នុងអង្គប្រជុំ។ សេចក្តីសម្រេចលើប្រធានបទផ្សេងៗ ឬជ្រើសរើសអភិបាលត្រូវធ្វើឡើងជាសន្លឹកឆ្នោតសម្ងាត់ លុះត្រាតែមានការកំណត់ផ្សេងក្នុងលក្ខន្តិកៈ។

[50] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២០៧។
[51] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២០៥។
[52] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២១៥។

មហាសន្និបាតម្ចាស់ភាគហ៊ុនអាចប្រព្រឹត្តទៅបាន ត្រូវមានលក្ខខណ្ឌកូរ៉ុមដែលមានវត្តមានផ្ទាល់របស់អ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតភាគច្រើន ឬដោយតំណាងជាអាណត្តិគាហក: លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិក:របស់ក្រុមហ៊ុន។ ប្រសិនបើកូរ៉ុមមិនមានគ្រប់ចំនួនក្នុងពេលបើកមហាសន្និបាតទេ ម្ចាស់ភាគហ៊ុនអាចលើកការប្រជុំពេលក្រោយ ប៉ុន្តែមហាសន្និបាតដែលមានកូរ៉ុនមិនគ្រប់មិនត្រូវបានអនុញ្ញាតឲ្យពិភាក្សាលើកិច្ចការចំនួនណាមួយឡើយ[53]។

### ២.៣. កំណត់ហេតុ

ក្រុមហ៊ុនត្រូវរៀបចំ និងរក្សាទុកនូវកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាលទាំងឡាយ និងសេចក្តីសម្រេចផ្សេងទៀតនៅក្នុងមហាសន្និបាត។ កំណត់ហេតុត្រូវរក្សាទុកនៅទីស្នាក់ការចុះបញ្ជីក្រុមហ៊ុន ឬកន្លែងណាដែលអភិបាលយល់ថាសមស្រប ហើយឯកសារទាំងអស់ត្រូវបានបើចំហដើម្បីឲ្យអភិបាលពិនិត្យបានគ្រប់ពេល[54]។ កំណត់ហេតុទាំងឡាយត្រូវរៀបចំជាបញ្ជីមួយមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេប ឬក៏លើក្រដាសមានចុះទំព័រ និងចុះហត្ថលេខាសង្ខេបតាមច្បាប់។ សេចក្តីចំលង ឬសម្រង់នៃកំណត់ហេតុទាំងនោះមានតម្លៃប្រើប្រាស់បានលុះត្រាតែមានចុះហត្ថលេខាបញ្ជាក់ត្រឹមត្រូវពីអភិបាល[55]។

## ៣. សវនករ

### ៣.១. ការតែងតាំង និងបញ្ចប់តួនាទី

សវនករមួយរូប នៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចត្រូវបានតែងតាំងតាមរយៈសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំលើកទីមួយ និងនៅមហាសន្និបាតប្រចាំឆ្នាំនីមួយៗ[56]។ ក្នុងករណីដែលក្រុមហ៊ុនមិនមានសវនករទេ ម្ចាស់ហ៊ុន ឬមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចស្នើទៅកាន់តុលាការដើម្បីធ្វើការតែងតាំងសវនករជំនួសបាន[57]។ សវនករត្រូវជ្រើសរើសចេញពីមនុស្សដែលមានវិជ្ជាជីវៈ ហើយមិនជាប់ពាក់ព័ន្ធទៅនឹងញាតិលោហិត របស់អ្នកចាត់ការឡើយ។

[53] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២១៧។
[54] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១២២។
[55] គង់ សាផន, *នីតិពាណិជ្ជកម្ម* (ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២), ២២៩។
[56] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២២៩។
[57] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៣៣។

សវនករត្រូវកាន់តំណែងរហូតដល់ការការបិទមហាសន្និបាទនៃឆ្នាំបន្ទាប់ ហើយបើសវនករថ្មីមិនបានតែតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនទេ សវនករដែលកំពុងកាន់មុខតំណែងត្រូវបន្តការងាររហូតដល់មានការតែងតាំងសវនរថ្មី។ រីឯសវនករ ដែលតែងតាំងដោយតុលាការ ត្រូវបំពេញភារកិច្ចរហូតមានការតែងតាំងសវនករថ្មីដោយម្ចាស់ភាគហ៊ុន។ សោហ៊ុយចំណាយ ឬប្រាក់លាភការរបស់សវនករត្រូវកំណត់ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុន ឬទៅតាមស្ថានភាពជាក់ស្តែង[58]។

ក្រៅពីមានសិទ្ធិតែងតាំងសវនករ ម្ចាស់ហ៊ុនក៏អាចដកតំណែងសវនករបានគ្រប់ពេល នៅពេលដែលរកឃើញថាសវនករបានប្រព្រឹត្តកំហុស ឬមានការធ្វេសប្រហែស ដែលបណ្តាលឲ្យខាតប្រយោជន៍ក្រុមហ៊ុន។ សមាជិកហ៊ុនត្រូវរកភស្តុតាង ដាក់ទៅអ្នកចាត់ការ ដើម្បីធ្វើការដកតំណែងសវនករនោះ។ នៅពេលតំណែងសវនករទំនេរ អភិបាលត្រូវកោះប្រជុំមហាន្និបាតពិសេស ដើម្បបំពេញភាពទំនេរនោះ ក្នុងរយៈពេល ២១ ថ្ងៃបន្ទាប់ពីមានភាពទំនេរ[59]។

### ៣.២. តួនាទី និងការទទួលលខុសត្រូវ

តួនទីសំខាន់របស់សវនករគឺត្រូវធ្វើការត្រួតពិនិត្យ លើចំនុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនម្ចាស់ហ៊ុន លើរបាយការហិរញ្ញវត្ថុ។ សវនករអាចស្នើឲ្យអភិបាល អ្នកគ្រប់គ្រងបុគ្គលិក ឬភ្នាក់ងារក្រុមហ៊ុន ផ្តល់ព័ត៌មាន ការបកស្រាយ សៀវភៅបញ្ជី និងកំណត់ហេតុសម្រាប់បំពេញមុខងាររបស់ខ្លួន។ សវនករ គ៏ទទួលបានសិទ្ធិចូលរួមក្នុងមហាសន្និបាតម្ចាស់ហ៊ុនដើម្បីដឹងឮនូវកម្មវត្ថុដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួន[60]។

ចំពោះការទទួលខុសត្រូវវិញ សវនករនៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តឡើង។ វាអាចជាការទទួលខុសត្រូវខាងរដ្ឋប្បវេណីដោយការសងសំណងទៅក្រុមហ៊ុន និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលកើតចេញពីបទល្មើសព្រហ្មទណ្ឌដូចជា ការឆបោក ការរំលោភសេចក្តីទុកចិត្ត ឬការប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់ខ្លួន។

---

[58] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៣១។
[59] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៣២។
[60] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៣៥។

## ផ្នែកទី ៤៖ ការរំលាយក្រុមហ៊ុន

ក្រុមហ៊ុនគឺមិនខុសទៅមនុស្សនោះទេ។ មនុស្សមានកើត ចាស់ ឈឺ ស្លាប់ រីឯក្រុមហ៊ុនវិញក៏មិនខុសគ្នាប៉ុន្មានទេគឺមានពេលចាប់ផ្តើម ហើយក៏មានពេលបញ្ចប់របស់វាផងដែរ។ តែករណីដែលក្រុមហ៊ុនត្រូវបញ្ចប់ជីវិតគឺសុទ្ធតែមានមូលហេតុរបស់វា។

### កថាភាគទី ១៖ ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

#### ១. មូលហេតុទូទៅនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានអាយុជីវិតស្មើទៅនឹងថេរវេលាដែលបានកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុន។ តែបើសហកម្មសិទ្ធិករមិនបានកំណត់ថេរវេលាក្រុមហ៊ុនទេ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មរបស់រហូតដល់ ៩៩ឆ្នាំ។ ប៉ុន្តែករណីនេះអាចពន្យារពេលបន្តបាន[61]។

សហកម្មសិទ្ធិករទូទៅទាំងឡាយក៏អាចធ្វើការព្រមព្រៀងគ្នាដើម្បីរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានមុនការមកដល់នៃថេរវេលាក្រុមហ៊ុន ដោយសេចក្តីសម្រេចរបស់សមាជិកស្តែងឡើងនូវឆន្ទៈជាឯកច្ឆ័ន ធ្វើការរំលាយក្រុមហ៊ុនចោល ដែលបណ្តាលមកពីបាត់បង់គោលការណ៍ស្មើដៃ ស្មើជើងគ្នា ឬការបាក់បែកសាមគ្គីគ្នា ឬ ការរលត់នៃកម្មវត្ថុអាជីវកម្មដែលជាកំហុសធ្ងន់ធ្ងរធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន ប្រពៃណីជាដើម។

#### ២. មូលហេតុពិសេសនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហាសកម្មសិទ្ធិមានកម្រិតក៏ត្រូវបានគេរំលាយផងដែរ ទោះបីជាមិនទាន់ដល់ថេរវេលាក្រុមហ៊ុន ឬការព្រមព្រៀងជាឯកឆន្ទដើម្បីរំលាយ។ មូលហេតុទាំងនោះមានដូចជា៖

- មរណៈភាពរបស់សហកម្មសិទ្ធិករទូទៅណាម្នាក់
- ការផ្លាស់ប្តូរទំរង់ក្រុមហ៊ុន ឬអវត្តមានសមាជិកថ្មីជាសហកម្មសិទ្ធិករទូទៅ។ ក្នុងករណីនេះប្រសិនបើសហកម្មសិទ្ធិករទូទៅទាំងឡាយ មិនត្រូវបានជំនួសក្នុងរយៈពេល ១២០ (មួយរយម្ភៃ)ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនិងត្រូវរំលាយ។
- ការបដិសេធនៃកិច្ចសន្យាក្រុមហ៊ុន ដោយមានវិការៈនៃកិច្ចសន្យាបង្កើតក្រុមហ៊ុន
- ការហាមឃាតដល់ការធ្វើអាជីវកម្ម ឬអសមត្ថភាពត្រូវបានទទួលរងទៅលើសហកម្មសិទ្ធិករទូទៅណាម្នាក់

[61] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៦៦។

- ការរំលាយដោយសេចក្តីសម្រេចរបស់តុលាការ ក្នុងករណី បំពានទៅលើកម្មវត្ថុអាជីវកម្ម ដោយប្រព្រឹត្តនូវបទល្មើសផ្សេងៗ ឬបាត់បង់ផលប្រយោជន៍ដែលនាំឲ្យមានបណ្តឹងពីក្រុមហ៊ុន សមាជិកហ៊ុន និងព្រះរាជអាជ្ញា។
- ការជំរះបញ្ជីតាមផ្លូវតុលាការ ដោយក្ស័យធន ប្តឹងសុំជំរះបញ្ជីទ្រព្យសម្បត្តិក្រុមហ៊ុន។

## កថាភាគទី ២៖ ការរំលាយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

### ១. មូលហេតុនៃការរំលាយ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាល ប្រសិនបើក្រុមហ៊ុនមិនមានបោះចេញជាប័ណ្ណភាគហ៊ុនណាមួយទេនោះ។ ប៉ុន្តែក្នុងករណីដែលក្រុមហ៊ុន គ្មានទ្រព្យសម្បត្តិ និងគ្មានបំណុល ហើយក្រុមហ៊ុននោះបានបោះចេញជាប័ណ្ណភាគមួយប្រភេទ ឬច្រើន ការរំលាយក្រុមហ៊ុនត្រូវធ្វើឡើងតាមសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុននៃប្រភេទនីមួយៗ ទោះម្ចាស់ហ៊ុននោះមាន ឬមិនមានសិទ្ធិបោះឆ្នោតក៏ដោយ[62]។

ក្រៅពីការស្ម័គ្រចិត្តរំលាយក្រុមហ៊ុនរបស់សមាជិកកហ៊ុន ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក៏អាចត្រូវបានគេរំលាយបានដែរនៅពេលដែលមានការមកដល់នូវថេរវេលាក្រុមហ៊ុននោះ។ មានន័យថាក្រុមហ៊ុនមានអាយុកាលស្មើនឹងការកំណត់ថេរវេលាក្រុមហ៊ុននៅក្នុងលក្ខន្តិកៈរបស់ខ្លួន (តែងតែមានការបន្តអាយុជីវិតក្រុមហ៊ុនប្រសិនបើ ក្រុមហ៊ុនមានដំណើរការអាជីវកម្មល្អ)។

លើសពីនេះទៅទៀតក្រុមហ៊ុនក៏អាចត្រូវបានគេរំលាយផងដែរ តាមរយៈសេចក្តីសម្រេចតុលាការ ប្រសិនបើមានបណ្តឹងសុំជម្រះបញ្ជីទ្រព្យសម្បត្តិដោយសារក្ស័យធន ពីសមាជិកហ៊ុន ឬម្ចាស់បំណុល ឬតាមរយៈបណ្តឹងរបស់ព្រះរាជអាជ្ញា ឬសមាជិកហ៊ុន ដោយសារកម្មវត្ថុអាជីវកម្មក្រុមហ៊ុនបានបំពានបទបញ្ញត្តិច្បាប់ សណ្តាប់ធ្នាប់សង្គម ឬធ្វើឲ្យខាតបង់ប្រយោជន៍សាធារណៈ។

### ២. ការជម្រះបញ្ជី

អភិបាល ឬម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត អាចស្នើឲ្យមានការជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ដើម្បីធ្វើការទូទាត់បំណុលនិងចាត់ចែងទ្រព្យសម្បត្តិ។ ក្រោយមានការយល់ព្រមលើការសេចក្តីសម្រេចជម្រះបញ្ជី និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាស

[62] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ២៥១។

ពីបំណាងរំលាយជាទម្រង់លម្អិត ទៅការកាន់មន្ត្រីទទួលបន្ទុកក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដើម្បីចេញវិញ្ញាបនបត្របញ្ជាក់ពីបំណាងរំលាយក្រុមហ៊ុននោះ[63]។ ក្រុមហ៊ុនត្រូវបញ្ឈប់អាជីវកម្ម ហើយផ្ញើលិខិតជូនដំណឹងស្តីពីបំណាងរំលាយក្រុមហ៊ុនទៅឲ្យម្ចាស់បំណុល និងចុះផ្សាយជាសាធារនៈ(២ សប្តាហ៍ជាប់គ្នា) នៅក្នុងសារព័ត៌មានស្របច្បាប់[64]។ មន្ត្រីទទួលបន្ទុកក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬអ្នកដែលមានផលប្រយោជន៍ អាចស្នើទៅតុលាការឲ្យមានការជម្រះបញ្ជីកក្រោមការត្រួតពិនិត្យរបស់តុលាការ។

ក្រោយពេលដែលការជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសសេចក្តីសម្រេចរំលាយក្រុមហ៊ុន និងផ្ញើសេចក្តីសម្រេចនោះទៅមន្ត្រីទទួលបន្ទុកក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មដើម្បីចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយ។ ក្រុមហ៊ុនត្រូវអស់អត្ថិភាព ចាប់ពីថ្ងៃដែលចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុន[65]។

[63] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥៣។
[64] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥៤។
[65] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥៦។

# ជំពូកទី ២

# ការប្រៀបធៀបរវាងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតរួចមក ឃើញថាទោះបីជាក្រុមហ៊ុនទាំងពីរជាប្រភេទក្រុមហ៊ុនពីរផ្សេងគ្នាក៏ដោយ ក៏ក្រុមហ៊ុនទាំងពីនេះមានលក្ខណៈរួម (ផ្នែក ១) និង លក្ខណៈខុសគ្នា (ផ្នែក ២) មួយចំនួនផងដែរ។

## ផ្នែកទី ១៖ លក្ខណៈដូចគ្នា

ក្រុមហ៊ុនទាំងពីរមានចំណុចដូចគ្នាមួយចំនួន ដែលអាចនិយាយបានថា វាជាធាតុសំខាន់ ឬ មូលដ្ឋាន ដែលក្រុមហ៊ុនត្រូវមាន។ ចំណុចទាំងនោះមានដូចជា ការបង្ហាញឆន្ទៈក្នុងការបង្កើតក្រុមហ៊ុន (កថាខណ្ឌ ១) សិទ្ធិ និងកាតព្វកិច្ចមួយចំនួនរបស់សមាជិកហ៊ុន (កថាខណ្ឌ ២) អង្គការដែលត្រូវគ្រប់គ្រងក្រុមហ៊ុន (កថាខណ្ឌ ៣) និង ការបញ្ចប់អាយុជីវិតរបស់ក្រុមហ៊ុន (កថាខណ្ឌ ៤)។

### កថាភាគទី ១៖ ការបង្ហាញឆន្ទៈបង្កើតក្រុមហ៊ុន

ការបង្ហាញឆន្ទៈរបស់សមាជិកហ៊ុននៅក្នុងក្រុមហ៊ុននីមួយៗ គឺជាលក្ខខណ្ឌចាំបាច់បំផុត ដែលឈានទៅដល់ការបង្កើតក្រុមហ៊ុនមួយឡើង។ ជាក់ស្តែងនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត សមាជិកហ៊ុនត្រូវតែបង្ហាញឆន្ទៈពិតរបស់ខ្លួនក្នុងការបង្កើតឲ្យមានក្រុមហ៊ុនឡើង ដោយធ្វើការដាក់ហ៊ុនរបស់ខ្លួនចូលទៅក្នុងក្រុមហ៊ុន។ ការសំដែងឆន្ទៈរបស់សមាជិកហ៊ុនក្នុងក្រុមហ៊ុនទាំងពីរ ត្រូវស្តែងឡើងតាមរយៈកិច្ចសន្យា (ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត) ឬតាមរយៈលក្ខន្តិកៈក្រុមហ៊ុន (ក្រុមហ៊ុនឯកជនទទួលខុសមានកម្រិត) ដោយមានការកំណត់នូវលក្ខខណ្ឌសំខាន់ដែលទាក់ទងនឹងសមាជិកក្រុមហ៊ុន និង សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកហ៊ុន ជាពិសេសគឺកម្មវត្ថុនៃការធ្វើពាណិជ្ជកម្មដើម្បីស្វែងរកប្រាក់ចំណេញ។ ក្រោយពេលដែលមានការបង្ហាញឆន្ទៈបង្កើតក្រុមហ៊ុនហើយ ដើម្បីឲ្យក្រុមហ៊ុនទទួលបាននូវបុគ្គលភាពគតិយុត្តស្របច្បាប់ វាតម្រូវឲ្យមានការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្ម ជាមួយនឹងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម និង មានការផ្សព្វផ្សាយជាសាធារណៈនៅក្នុងសារពត៌មានស្របច្បាប់។

## កថាភាគទី ២៖ សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកហ៊ុន

សមាជិនហ៊ុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត នឹងទទួលបានសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដូចគ្នានៅពេលដែលក្រុមហ៊ុនត្រូវបានបង្កើតឡើង។ ពួកគេមានសិទ្ធិចូលរួមក្នុងជីវភាពក្រុមហ៊ុន ទទួលបានពត៌មានទាក់ទងនឹងក្រុមហ៊ុន ទទួលបានប្រាក់ចំនេញ មិនតែប៉ុណ្ណោះ ពួកគេកត្រូវមានកាតព្វកិច្ចចំពោះបំណុលក្រុមហ៊ុនផងដែរ។

### ១. លក្ខណៈដូចគ្នានៃសិទ្ធិ របស់សមាជិកហ៊ុន

ទាំងសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិតនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ក៏ដូចជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត សុទ្ធតែមានសិទ្ធិចូលរួមក្នុងជិវភាពក្រុមហ៊ុន។ ការចូលរួមក្នុងជីវភាពក្រុមហ៊ុនមិនសំដៅលើការគ្រប់គ្រងអាជីវកម្មក្រុមហ៊ុនទេ តែសមាជិកហ៊ុនទាំងនោះអាចផ្តល់ជាយោបល់ ឬបញ្ចេញគំណិតណាមួយទាក់ទងទៅនឹងបញ្ហានៃការគ្រប់គ្រងក្រុមហ៊ុន ទៅកាន់អភិបាលដើម្បីធ្វើការពិចារណា។ លើសពីនេះទៅទៀតពួកគេមានសិទ្ធិទទួលបានពត៌មានទាក់ទិននឹងស្ថានការណ៍ក្រុមហ៊ុន ដូចជាការពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ កំណត់ហេតុក្នុងមហាសន្និបាត និងបញ្ជីសារពើពន្ធជាដើម។ អ្វីដែលពីសេសនោះគឺ សមាជិកហ៊ុនទាំងអស់មានសិទ្ធិពេញលេញ ក្នុងការទទួលបានប្រាក់ចំណេញទៅតាមសមមាត្រហ៊ុនដែលពួកគេបានចូករួមក្នុងក្រុមហ៊ុន ឬទទួលបានប្រាក់ចំណេញតាមចំណែក (មិនសមមាត្រ) ដែលបានកំណត់នៅក្នុងកិច្ចសន្យា និងលក្ខន្តិកៈក្រុមហ៊ុន។

### ២. កាតព្វកិច្ចទទួលខុសត្រូវចំពោះក្រុមហ៊ុន និងបំណុល

សមាជិកហ៊ុនាទាំងអស់នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត ត្រូវមានកាតព្វកិច្ចបង់ប្រាក់ ឬចំនែកហ៊ុនរបស់ខ្លួនដែលបានសន្យាចូលរួមក្នុងក្រុមហ៊ុន ហើយសមាជិកទាំងនោះមិនត្រូវធ្វើការប្រគួតប្រជែងជាមួយក្រុមហ៊ុនឡើយ។ សហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអាចទទួលបានប្រាក់ចំណេញទេ ហើយត្រូវធ្វើវិភាគទានទៅអោយក្រុមហ៊ុននៅពេលដែលមានឱនភាពដើមទុន រីឯម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតវិញ ក៏ត្រូវបង្វិលប្រាក់ចំណេញទៅក្រុមហ៊ុនវិញ ដើម្បីធ្វើថវិការបំរុង (ឆ្នាំដំបូង)។ កាតព្វកិច្ចមួយទៀតដែលសមាជិកហ៊ុននៃក្រុមហ៊ុនទាំងពីរមាន គឺត្រូវទទួលខុសត្រូវចំពោះរាល់ទង្វើ ឬសកម្មភាពដែលខ្លួនបានប្រព្រឹត្តចំពោះក្រុមហ៊ុន និងតតិយជន។ អ្វីដែលសំខាន់និងជាលក្ខណៈពិសេសនៃក្រុមហ៊ុនទាំងពីរគឺ ការទទួលខុសត្រូវមានកម្រិតចំពោះបំណុលក្រុមហ៊ុ

ន។ សហកម្មសិទ្ធិករមានកម្រិតនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង រាល់ម្ចាស់ភាគហ៊ុនក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត មានកាតព្វកិច្ចទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនត្រឹមតែកម្រិតដែលខ្លួនបានដាក់ហ៊ុនក្នុងមូលធនក្រុមហ៊ុនប៉ុណ្ណោះ(លើកលែងសហកម្មសិទ្ធិករទូទៅ)។

### កថាភាគទី ៣៖ អង្គការគ្រប់គ្រងក្រុមហ៊ុន

ទោះបីជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតស្ថិតនៅក្នុងទម្រង់ក្រុមហ៊ុនពីរផ្សេងគ្នាក៏ដោយ ដំណើរការប្រព្រឹត្តទៅនៃក្រុមហ៊ុនទាំងពីរតម្រូវឲ្យមានអង្គការគ្រប់គ្រងដូចគ្នា។ ក្រុមហ៊ុនទាំងពីរត្រូវមាន៖

- អភិបាល ដែលជ្រើសដោយសមាជិកហ៊ុន ដើម្បីដឹកនាំ និង គ្រប់គ្រងអាជីវកម្ម និងតំណាងឲ្យក្រុមហ៊ុន អនុវត្តសកម្មភាពពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ អភិបាលគឺជាបុគ្គលដែលមានសមត្ថភាពការងារខ្ពស់ មានបទពិសោធខាងពាណិជ្ជកម្ម។
- មហាសន្និបាត ដែលមានការចូលរួមពីសមាជិកហ៊ុន និងអភិបាល (អភិបាលមិនជាសមាជិកហ៊ុន) និង សវនករ ដើម្បីធ្វើការសម្រេចចំពោះបញ្ហាណាមួយដែលហួសសមត្ថភាពរបស់អភិបាល ការសម្រេចលើរបាយការប្រចាំឆ្នាំ ក៏ដូចជាការបែងចែកភាគលាភ។ ជាគោលការណ៍ទាំងនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតមហាសន្និបាត សេចក្តីសម្រេច ដែលអាចយកជាការបានគឺត្រូវមានសំលេង ៥០% + ១ នៃអ្នកដែលមានសិទ្ធិបោះឆ្នោត លើកលែងតែសេចក្តីសម្រេចពិសេស ដែលមានចែងក្នុងកិច្ចសន្យា លក្ខន្តិកៈក្រុមហ៊ុន និងច្បាប់ដែលមានជាធរមាន។
- សវនករ ដែលត្រូវតែងតាំងឲ្យធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុរបស់អភិបាល ហើយធ្វើការរាយការណ៍ទៅសមាជិកហ៊ុនតាមរយៈមហាសន្និបាត។

### កថាភាគទី ៤៖ ការបញ្ចប់ជីវិតក្រុមហ៊ុនដោយការព្រមព្រៀង និង អស់ថេរវេលា

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតអាចត្រូវបានគេរំលាយនៅពេលណាក៏បានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីសមាជិកហ៊ុនទាំងអស់។ ការព្រមព្រៀងរំលាយក្រុមហ៊ុន អាចត្រូវបានធ្វើឡើងនៅមុនពេលថេរវេលាក្រុមហ៊ុនមកដល់។ ក្រុមហ៊ុនទាំងពីរនេះ នឹងត្រូវគេរំលាយផងដែរ នៅពេលដែលវាមានអាយុស្មើនឹងថេរវេលាដែលបាន

កំណត់នៅក្នុងកិច្ចសន្យា និង លក្ខន្តិកៈក្រុមហ៊ុន។ បើពុំមានចែងអំពីថេរវេលាទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត មានរយៈពេល ៩៩ ឆ្នាំ (អាចបន្តអាយុជីវិតបាន)។ ក្រៅពីនេះ ក្រុមហ៊ុនក៏អាចត្រូវបានគេរំលាយផងដែរ តាមរយៈសេចក្តីសម្រេចតុលាការប្រសិនបើមានបណ្តឹងសុំជម្រះបញ្ជីទ្រព្យសម្បត្តិដោយសារក្ស័យធន ពីសមាជិកហ៊ុន ឬម្ចាស់បំណុល ឬតាមរយៈបណ្តឹងរបស់ព្រះរាជអាជ្ញា ឬសមាជិកហ៊ុន ដោយសារកមុនវត្តអាជីវកម្មក្រុមហ៊ុនបានបំពានបទបញ្ញត្តិច្បាប់ សណ្តាប់ធ្នាប់សង្គម ឬធ្វើឲ្យខាតបង់ប្រយោជន៍សាធារណៈ។

## ផ្នែកទី ២៖ លក្ខណៈខុសគ្នា

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតមានចំណុខុសគ្នាមួយចំនួន ដែលបង្កើតឲ្យមានក្រុមហ៊ុននីមួយៗ មានលក្ខណៈពិសេសរបស់វា។ ក្នុងនោះមានភាពខុសគ្នានៃលក្ខខណ្ឌបង្កើតក្រុមហ៊ុន (កថាខណ្ឌ ១) ការរឹតត្បិតនៃសិទ្ធិធ្វើអនុប្បទាន និងហានិភ័យនៃការទទួលខុសត្រូវ (កថាខណ្ឌ ២) លក្ខណៈសម្បត្តិនៃអភិបាល និងលក្ខខណ្ឌកូរ៉ុមក្នុងមហាសន្និបាត (កថាខណ្ឌ ៣) និងចុងក្រោយ ភាពផុយស្រួយនៃការបាត់បង់អាយុជីវិតក្រុមហ៊ុន (កថាខណ្ឌ ៤)។

### កថាភាគទី ១៖ លក្ខណៈខុសគ្នានៃលក្ខខណ្ឌបង្កើតក្រុមហ៊ុន

#### ១. លក្ខខណ្ឌគ្រឹះ

ការបង្ហាញឆន្ទៈដើម្បីបង្កើតក្រុមហ៊ុនគឺជាលក្ខខណ្ឌចាំបាច់សម្រាប់ក្រុមហ៊ុនទាំងពីរ ប៉ុន្តែនៅមានលក្ខខណ្ឌគ្រឹះពីរផ្សេងទៀត ដែលធ្វើឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត មានលក្ខណៈខុសគ្នា។

##### ១.១. សមត្ថភាពរបស់សមាជិកហ៊ុន

ច្បាប់ស្តីពិសហគ្រាសពាណិជ្ជកម្ម មាត្រា ៦៤ បានកំណត់ថា ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតគឺជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬ ច្រើននាក់ ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅកនុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។ មានន័យថា ដើម្បីបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សមាជិកហ៊ុនត្រូវតែជារូបវន្តបុគ្គល ហើយចាំបាច់ត្រូវមានម្នាក់ជាសហកម្មសិទ្ធិករទូទៅ ដែលជានិច្ចកាលត្រូវបានគេចាត់ទុកថា

ជាពាណិជ្ជករ និងមានភារៈកិច្ចគ្រប់គ្រងក្រុមហ៊ុន។ ក្នុងករណីដែលសមាជិកហ៊ុនទាំងអស់ជាសហកម្មសិទ្ធិករមានកម្រិត (មិនមែនពាណិជ្ជករ) ពួកគេមិនអាចបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានទេ។

ដោយឡែកនៅក្នុងមាត្រា ៩១ បានកំណត់ថា នីតិបុគ្គល ឬ រូបវន្តបុគ្គលមួយ ឬច្រើន ដែលមានកាយសម្បទា និងមានសមត្ថភាពគ្រប់គ្រាន់អាចបង្កើតក្រុមហ៊ុនមូលធនបាន ដោយធ្វើការបំពេញតម្កល់លក្ខន្តិកៈទៅឲ្យ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ តាមរយៈមាត្រានេះ សមាជិកហ៊ុននៅក្នុង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត អាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល (ធ្វើពាណិជ្ជកម្ម) ដែលមានកាយសម្បទាគ្រប់គ្រាន់ និងមានសមត្ថភាព គឺអាចបង្កើតក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតបាន។ ក្នុងន័យនេះម្ចាស់ហ៊ុនទាំងអស់ក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនចាំបាច់មានលក្ខណៈសម្បត្តិជាពាណិជ្ជកររហូតទេ ជនដែលមិនមែនជាពាណិជ្ជករដែលមានសមត្ថភាពខាងរដ្ឋប្បវេណី ហើយបានសម្រេចចូលរួមដាក់ទុន គឺអាចបង្កើតក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតបានហើយ។

### ១.២. វិការៈនៃការបង្ហាញឆន្ទៈ

ដោយសារក្រុមហ៊ុនទាំងពីរបង្កើតឡើងក្រោមលក្ខខណ្ឌទម្រង់ពីរផ្សេងគ្នា នោះវិការៈនៃការបង្ហាញឆន្ទៈបង្កើតក្រុមហ៊ុន ជាចំណុចដែលបង្ករឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក៏ខុសគ្នាដែរ។ ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានបង្កើតតាមរយៈកិច្ចសន្យាក្រុមហ៊ុន ដូច្នេះវិធានរួមនៃកិច្ចសន្យាត្រូវបានអនុវត្តចំពោះក្រុមហ៊ុន។ ប្រការដែលមានវិការៈនៃការបង្ហាឆន្ទៈលើចំណុចណាមួយនៃកិច្ចសន្យា អាចជាកម្មវត្ថុនៃមោឃភាព ឬការលប់ចោលកិច្ចសន្យា ដែលជាហេតុនាំឲ្យមានការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ដោយឡែកក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើងតាមរយៈលក្ខន្តិកៈក្រុមហ៊ុន។ កាលណាមានវិការៈនៃការបង្ហាញឆន្ទៈចំពោះចំណុចខ្លះក្នុងលក្ខន្តិកៈ វាមិនមែនជាកម្មវត្ថុនៃមោឃភាពលក្ខន្តិកៈក្រុមហ៊ុនទេ ហើយវាមិននាំឲ្យមានមោឃភាពដល់ការប្រព្រឹត្តរបស់ក្រុមហ៊ុននោះឡើយ។ សមាជិកហ៊ុនគ្រាន់តែធ្វើការកែប្រែចំណុចដែលមានវិការៈតែប៉ុណ្ណោះ។

## ២. លក្ខខណ្ឌទម្រង់

មានចំណុចសំខាន់ពីរ ខុសគ្នានៅក្នុងលក្ខខណ្ឌទម្រង់ ដើម្បីបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត។

### ២.១. កិច្ចសន្យា និង លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន

ដូចបានបញ្ជាក់ក្នុងមាត្រា ៦៤ ច្បាប់ស្តីពិសហគ្រាសពាណិជ្ជកម្ម ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតធ្វើឡើងតាមរយៈកិច្ចសន្យារវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើន ជាមួយនឹងសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬច្រើន។ មិនតែប៉ុណ្ណោះកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬជាកិច្ចសន្យាផ្ទាល់មាត់ ដោយក្នុងនោះកិច្ចសន្យាត្រូវមានចែងចំណុចសំខាន់មួយចំនួន ដូចជាសមាសភាពសហកម្មករទាំងអស់ កម្មវត្ថុអាជីវកម្ម និងសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកហ៊ុន ជាពិសេសមូលធនរបស់ក្រុមហ៊ុន។

ផ្ទុយទៅវិញដើម្បីបង្កើតក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិត ម្ចាស់ភាគហ៊ុនដែលមានសមត្ថភាពគ្រប់គ្រាន់ត្រូវធ្វើការបង្កើតជាលក្ខន្តិកៈក្រុមហ៊ុន ហើយតម្កល់ទៅឲ្យ មន្រ្តីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ នៅក្នុងលក្ខន្តិកៈក្រុមហ៊ុនឯជនទទួលខុសត្រូវមានកម្រិតត្រូវមានចែងចំណុច និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៩៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ សមាជិកហ៊ុនក៏អាចបញ្ចូលចំណុចផ្សេងទៀតទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន តាមការចាំបាច់ផងដែរ (មាត្រា ៩៤)។ ក្រុមហ៊ុនអាចរៀបចំបទបញ្ជាផ្ទៃក្នុងផ្ទាល់ ដើម្បីសម្រួលដល់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះឃើញថា លក្ខន្តិកៈក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានលក្ខណៈលម្អិតជាង កិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។

### ២.២. ការកំណត់មូលធន និងការបោះចេញប័ណ្ណភាគហ៊ុន

តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មិនតម្រូវឲ្យមានការកំណត់មូលធនអប្បរមាសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតឡើយ។ ជាធម្មតា នៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានត្រឹមតែចែងនូវមូលធនដំបូង ដែលសហកម្មសិទ្ធិករទាំងអស់បានដាក់ទុន ដើម្បីប្រកបអាជីវកម្ម។ មិនតែប៉ុណ្ណោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនអនុញ្ញាតឲ្យមានការបោះចេញជាប័ណ្ណភាគហ៊ុនទេ។ ខុសប្លែកពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនប្រភេទនេះ ត្រូវតែមានមូលធនអប្បរមាដែលបានកំណត់ដោយច្បាប់។ នៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវមានដើមទុនយ៉ាងតិច ២០.០០០.០០០៛ ហើយត្រូវបោះចេញជាប័ណ្ណភាគដែលមិនតិចជាង ១.០០០ ប័ណ្ណភាគហ៊ុន។ ការបោះចេញជាប័ណ្ណភាគហ៊ុនត្រូវលក់ឲ្យសមាជិកហ៊ុន ប៉ុន្តែក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនអាចបោះចេញជាប័ណ្ណភាគហ៊ុនដើម្បីលក់ជាសាធារណៈឡើយ។

## កថាភាគទី ២៖ ភាពខុសគ្នានៃសិទ្ធិធ្វើអនុប្បទាន និងភារការទទួលខុសត្រូវ

### ១. សិទ្ធិធ្វើអនុប្បទាន និងការផ្ទេរផលប្រយោជន៍

សិទ្ធិក្នុងការធ្វើអនុប្បទានភាគហ៊ុន ឬ ផលប្រយោជន៍របស់សមាជិកហ៊ុនត្រូវមានកំណត់ក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន។ នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិតមានការកម្រិតយ៉ាងតឹងរឹងចំពោះសហកម្មសិទ្ធិករទូទៅ តែបានបើកយ៉ាងទូលាយចំពោះសហកម្មសិទ្ធិករមានកម្រិត។ សហកម្មសិទ្ធិករទូទៅត្រូវមានការយល់ព្រមជាឯកច្ឆន្ទពីសំណាក់សហកម្មសិទ្ធិករដទៃទៀតនៅក្នុងក្រុមហ៊ុនដើម្បីអាចផ្ទេរអត្ថប្រយោជន៍របស់ខ្លួនបាន។ ផ្ទុយទៅវិញ សហកម្មសិទ្ធិករមានកម្រិតមិនចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតឡើយ ចំពោះការផ្ទេរអត្ថប្រយោជន៍របស់ខ្លួននោះ។ ដោយឡែកសិទ្ធិធ្វើអនុប្បទានភាគហ៊ុនរបស់ម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចមានការរឹតត្បិតខ្លាំង ឬ តិចគឺអាស្រ័យលើការកំណត់នៅក្នុងលក្ខន្តិកៈបង្កើតក្រុមហ៊ុន។ ម្ចាស់ហ៊ុនអាចផ្ទេរភាគហ៊ុនរបស់ខ្លួនបានដោយសេរី និង គ្រប់ពេលទៅកាន់សមាជិកភាគហ៊ុនដូចគ្នា សហព័ទ្ធ និងញាតិលោហិត តែចំពោះការធ្វើអនុប្បទានឲ្យតតិយជនខាងក្រៅក្រុមហ៊ុនត្រូវមានការ ការសម្រេចពីសមាជិកហ៊ុនទាំងអស់ដោយសំឡេងភាគច្រើនដាច់ខាត ឬ សំឡេងឯកច្ឆន្ទ ឬផ្សេងពីនេះតាមលក្ខន្តិកៈកំណត់[66]។

### ២. ការទទួលខុសត្រូវគ្មានកម្រិតរបស់សហកម្មសិទ្ធិករទូទៅ

ទោះបីជាក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិតជាប្រភេទក្រុមហ៊ុនដែលទទួលខុសត្រូវមានកម្រិតក៏ដោយ សហកម្មសិទ្ធិករទូទៅនៅតែមានហានិភ័យខ្ពស់ចំពោះបំណុលក្រុមហ៊ុន។ សហកម្មសិទ្ធិករទូទៅនៅតែទទួលខុសត្រូវគ្មានកម្រិតនៅពេលក្រុមហ៊ុនមានបំណុល ហើយទ្រព្យសម្បត្តិក្រុមហ៊ុនមិនអាចធ្វើការទូទាត់គ្រប់គ្រាន់បានទេនោះ។ វាអាចប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅ ដែលចំនែកនោះអាចលើសទៅនឹងសមមាត្រហ៊ុនដែលខ្លួនបានដាក់ទុនក្នុងក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនទាំមូលគ្មានលទ្ធភាពសងបំណុលបានគ្រប់គ្រាន់ (លើកលែងសហកម្មសិទ្ធិករមានកម្រិត)។ ផ្ទុយទៅវិញ សមាជិកហ៊ុននៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទោះបីជាពួកគេមានឋានៈជាអ្វីក៏ដោយ (ជាពាណិជ្ជករ ឬមិនមែន) ពួកគេនៅតែ

[66] ប្រការ ៦ (៦.២.៤) នៃលក្ខន្តិកៈក្រុមហ៊ុន អាលីអាត ភារី ប្រាយវេត ខមភេនី លីមីធីត កំណត់យកសម្លេងឯកច្ឆន្ទសម្រាប់ការធ្វើអនុប្បទានឲ្យអ្នកខាងក្រៅ

ទទួលខុសត្រូវត្រឹមតែកម្រិតមួយដែលពួកគេបានចូលរួមទុនក្នុងក្រុមហ៊ុន។ នៅពេលក្រុមហ៊ុនមានបំណុលចម្ចាស់ហ៊ុនទទួលខុសត្រូវដោយផ្អែកតាមសមមាត្រភាគហ៊ុនដែលមានតែប៉ុណ្ណោះ។

### កថាភាគទី ៣៖ លក្ខណៈសម្បត្តិអភិបាល និងរបបនៃសេចក្តីសម្រេចក្នុងមហាសន្និបាត

#### ១. ការជ្រើសរើសអភិបាល និងការកំណត់អាណត្តិ

នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អភិបាលម្នាក់ត្រូវបានគេជ្រើសចេញក្នុងចំណោមសហកម្មសិទ្ធិករទូទៅ តែនៅក្នុងកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អភិបាលអាចត្រូវបានគេជ្រើសពីខាងក្រៅបាន (មិនមែនជាសមាជិកហ៊ុន)។ សហកម្មសិទ្ធិករមានកម្រិតមិនអាចធ្វើជាអភិបាលបានជាដាច់ខាត។ លើសពីនេះទៅទៀត មិនមានបញ្ញត្តិណាមួយនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានកំណត់អំពីអាណត្តិរបស់អភិបាលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតទេ។ ប៉ុន្តែអាណត្តិរបស់អភិបាលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតអាចត្រូវបានកំណត់ នៅក្នុងកិច្ចសន្យាក្រុមហ៊ុនបាន បើមិនមានចែងទេ អាណត្តិរបស់អភិបាលគឺស្មើនឹងថេរវេលាក្រុមហ៊ុន។

ចំណែកឯក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ការជ្រើសរើសអភិបាលត្រូវចេញពីចំណោមម្ចាស់ភាគហ៊ុន ឬជ្រើសរើសអ្នកខាងក្រៅ ទោះបីជាពួកគេមិនមានលក្ខណៈសម្បត្តិជាពាណិជ្ជករក៏ដោយ។ បន្ថែមពីនេះ អភិបាលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចមានម្នាក់ ឬ ច្រើននាក់ ហើយត្រូវមានអាណត្តិសម្រាប់ ២ ឆ្នាំ ក្នុងករណីលក្ខន្តិកៈក្រុមហ៊ុនមិនបានកំណត់អំពីអាណត្តិអភិបាល។

#### ២. របបនៃសេចក្តីសម្រេចក្នុងមហាសន្និបាត

គោលការបង្កើតនៃក្រុនហ៊ុនទាំងពីរបានធ្វើឲ្យសិទ្ធិសម្រេចក្នុងសហាសន្និបាតមានលក្ខណៈខុសគ្នា។ វត្តមាននៃសហកម្មសិទ្ធិករមានសារៈសំខាន់ចំពោះសេចក្តីសម្រេចនានានៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ សេចក្តីសម្រេច (សេចក្តីសម្រេចធម្មតា) ត្រូវធ្វើឡើងដោយសំឡេងភាគច្រើនដោយប្រៀប (កិច្ចសន្យាក្រុមហ៊ុនអាចចែងលើសពីនេះ) របស់សហកម្មសិទ្ធិករមានវត្តមានដោយមិនគិតពីតម្លៃនៃអត្ថប្រយោជន៍ដែលគេមាន ព្រោះក្រុមហ៊ុនឈរលើគោលការណ៍រាប់អានបុគ្គល។ រីឯនៅក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតវិញ សិទ្ធិសម្រេច ឬសំឡេងនៃការបោះឆ្នោតត្រូវផ្អែកលើតម្លៃភាគហ៊ុនរបស់ម្ចាស់ភាគហ៊ុននីមួយៗបានកាន់កាប់ (គោលការរាប់អានប្រាក់កាស)។ ចំពោះសេចក្តីសម្រេចវិសាមញ្ញ ទាមទារឲ្យមានការព្រមព្រៀងជាឯកច្ឆន្ទនៃសហកម្មសិទ្ធិ

ករទាំអស់ក្នុងក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត ប៉ុន្តែសំឡេងឆ្នោត ២/៣ អាចអនុវត្តចំពោះសេចក្តីសម្រេចពិសេសក្នុងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតបាន។

## កថាភាគទី ៤៖ អាយុជីវិតក្រុមហ៊ុន និងការបាត់បង់សមាជិកភាពម្ចាស់ហ៊ុន

សហាកម្មសិទ្ធិករទូទៅនៅក្នុងក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត ពិតជាដើរតួយ៉ាងសំខាន់សម្រាប់អាជីវកម្មក្រុមហ៊ុន ជាពិសេសទាក់ទងទៅនឹងអាយុជីវិតក្រុមហ៊ុនតែម្តង។ នៅពេលដសហាកម្មសិទ្ធិករទូទៅទទួលមរណៈភាព ឬអស់សិទ្ធិជាសហាកម្មសិទ្ធិទូទៅដោយប្រការណាមួយ ហើយមិនមានសហាកម្មសិទ្ធិករថ្មីមកជំនួសសហាកម្មសិទ្ធិករទូទៅក្នុងរយៈពេល ១២០ ថ្ងៃទេ ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតនឹងត្រូវគេរំលាយ។ ប៉ុន្តែ មរណៈភាពរបស់សហាកម្មសិទ្ធិករមានកម្រិត មិនប៉ះពាល់ទៅនឹងអាយុជីវិតក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត។ ដោយឡែក ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ទោះបីជាម្ចាស់ហ៊ុនណាម្នាក់បានទទួលមរណៈភាព ឬអស់សមាសភាពជាសមាជិកហ៊ុននៅក្នុងក្រុមហ៊ុនក៏ដោយ ក៏ក្រុមហ៊ុននៅតែអាចបន្តអាយុជីវិតបាន។ នេះបានបញ្ជាក់ឲ្យឃើញថា អាយុជីវិតក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតមានលក្ខណៈផុយស្រួយជាងក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត។

## លទ្ធផលនៃការស្រាវជ្រាវ

ដោយបានធ្វើការសិក្សា និង ប្រៀបធៀបអំពីទម្រង់នៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតរួចមក យើរពិនិត្យឃើញថា ទម្រង់ក្រុមហ៊ុនទាំងពីរនេះមានលក្ខណៈពិសេស (គុណសម្បត្តិ) និង ចំណុចអវិជ្ជមាន (គុណវិបត្តិ) របស់វា។ យើងនឹងលើកយកចំណុចទាំងនោះមកធ្វើការបង្ហាញនៅផ្នែកខាងក្រោមនេះ។

### ក. គុណសម្បត្តិនៃទម្រង់ក្រុមហ៊ុនទាំងពីរ

#### ក. ១. គុណសម្បត្តិនៃទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតជាប្រភេទក្រុមហ៊ុនពាណិជ្ជកម្មខ្នាតតូច ដែលបង្កើតឡើងដោយសហកម្មសិទ្ធិករតិចបំផុត ២ រូប ហើយយ៉ាងហោចណាស់មានម្នាក់ជាសកម្មសិទ្ធិករទូទៅ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានលក្ខណៈពិសេសមួយចំនួនដែលអាចឲ្យអ្នកដែលចង់បង្កើតអាជីវកម្មផ្ទាល់ខ្លួន ប៉ុន្តែខ្វះខាតធនធាន អាចធ្វើការសហការគ្នាដើម្បីធ្វើពាណិជ្ជកិច្ចបាន។

គុណសម្បត្តិដំបូងគេបង្អស់នៃទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺក្រុមហ៊ុនប្រភេទនេះងាយស្រួលបង្កើត។ សហកម្មសិទ្ធិករ ២ រូបអាចបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតតាមរយៈកិច្ចសន្យាឯកជនរបស់ខ្លួន ដែលកិច្ចសន្យានេះអាចធ្វើឡើងដោយផ្ទាល់មាត់ ឬក៏លាយលក្ខណ៍អក្សរបាន ដោយគ្រាន់តែ បើចង់ឲ្យក្រុមហ៊ុនមានបុគ្គលភាពគតិយុត្តស្របច្បាប់ សហកម្មសិទ្ធិករត្រូវទៅចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មនៅឯក្រសួងពាណិជ្ជកម្ម។ មិនតែប៉ុណ្ណោះមូលធនអប្បបរមាមិនត្រូវបានច្បាប់កំណត់ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតទេ ដូចនេះវាបានផ្តល់ឱកាសល្អសម្រាប់បុគ្គលដែលមានជំនាញ ប៉ុន្តែមិនមានធនធានច្រើនអាចសហការគ្នាចាប់ផ្តើមអាជីវកម្មរបស់ខ្លួនបាន។

គុណសម្បត្តិមួយទៀតនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺបានផ្តល់ទៅឲ្យសហកម្មសិទ្ធិករទូទៅ ក្នុងការគ្រប់គ្រង និងស្វែងរកអ្នកដាក់ទុនចូលក្នុងក្រុមហ៊ុន។ ដូចបានបញ្ជាក់ខាងលើ សហកម្មសិទ្ធិករទូទៅ ដែលមានជំនាញ និងបទពិសោធ ប៉ុន្តែខ្វះខាតដើមទុន គេអាចគៀងគរអ្នកវិនិយោគដែលជាសហកម្មសិទ្ធិករមានកម្រិតឲ្យដាក់ភាគហ៊ុនទៅក្នុងក្រុមហ៊ុនបាន។ នៅពេលដែលមានអ្នកចូលរួមហ៊ុនកាន់តែច្រើនទំហំមូលធនរបស់ក្រុមហ៊ុនកាន់តែធំ ដែលជាហេតុនាំឲ្យដំណើរការប្រព្រឹត្តទៅនៃក្រុមហ៊ុនមានភាពល្អប្រសើ មិនតែប៉ុណ្ណោះវិសាលភាពជំនួញមានការរីចម្រើន

ហើយវានឹងផ្តល់ភាពចំនេញឲ្យក្រុមហ៊ុនកាន់តែច្រើនដែរ។ លើសពីនេះទៅទៀត ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដែលមានសហកម្មសិទ្ធិករច្រើន វាបានផ្តល់ភាពងាយស្រួលក្នុងការបែងចែកភារកិច្ច។ កាលណាសហកម្មសិទ្ធិករទូទៅច្រើនបានចូលរួមក្នុងក្រុមហ៊ុនតែមួយ ជាមួយនឹងជំនាញ និងបទពិសោធផ្សេងគ្នា ពួកគេអាចបែងចែកបន្ទុកការងារទៅតាមលទ្ធភាព និងជំនាញ។ ចំពោះដំណើរការប្រព្រឹត្តទៅរបស់ក្រុមហ៊ុន មានលក្ខណៈរលូន និងឆាប់រហ័សដោយសារតែការសម្រេចចិត្តមួយចំនួនធំគឺធ្វើឡើងដោយសហកម្មសិទ្ធិករទូទៅ ដោយមិនចាំបាច់មានការពិភាក្សា និងការបោះឆ្នោតសម្រេចពីសហកម្មសិទ្ធិករទាំងអស់ទេ។

រីឯសហកម្មសិទ្ធិករមានកម្រិតក៏ទទួលបានអត្ថប្រយោជន៍ច្រើនពីទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតផងដែរ។ ការចូលរួមភាគទុននៅក្នុងក្រុមហ៊ុននេះ ជាឱកាសល្អមួយសម្រាប់អ្នកវិនិយោគអកម្ម មានន័យថាបុគ្គលដែលមានធនធាន ប៉ុន្តែមិនមានជំនាញ ឬបទពិសោធខាងពាណិជ្ជកម្ម អាចដាក់ទុនទៅក្នុងទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដោយធ្វើជាសហកម្មសិទ្ធិករមានកម្រិត។ ពួកគេអាចទទួលបានប្រាក់ចំណេញ ដោយសារតែដំណើរការក្រុមហ៊ុន ក្រោមការគ្រប់គ្រងរបស់សហកម្មសិទ្ធិករទូទៅ មានលក្ខណៈគាប់ប្រសើ។ អ្វីដែលជាចំណុចពិសេសរបស់ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ចំពោះ សហកម្មសិទ្ធិករមានកម្រិត គឺពួកគេតម្រូវឲ្យទទួលខុសត្រូវចំពោះការខាតបង់ និងបំណុលក្រុមហ៊ុនត្រឹមតែកម្រិតដែលពួកគេបានចូលរួមប៉ុណ្ណោះ។ ការប្តឹងទាមទារសំណងរបស់ម្ចាស់បំណុលពីទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនប៉ះពាល់ដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករមានកម្រិតឡើយ។ ប៉ុន្តែការទទួលខុសត្រូវមានកម្រិតនេះ មិនអនុវត្តចំពោះសហកម្មសិទ្ធិករមានកម្រិតណាដែលបានលូកលាន់ទៅនឹងកិច្ចការជំនួញរបស់ក្រុមហ៊ុន ហើយបណ្តាលឲ្យមានការខាតបង់នោះទេ។ សហកម្មសិទ្ធិករមានកម្រិតត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។

### ក.២. គុណសម្បត្តិនៃទម្រង់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បានផ្តល់នូវការការពារទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ម្ចាស់ហ៊ុន ការប្រមូលមូលធនបានច្រើន និង ដំណើរការអចិន្ត្រៃយ៍របស់ក្រុមហ៊ុន។

គុណសម្បត្តិធំជាងគេបង្អស់នៃទម្រង់ក្រុមហ៊ុននេះ គឺការទទួលខុសត្រូវមានកម្រិតរបស់វា។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោយពេលបង្កើតត្រូវបានគេចាត់ទុកថាមាននីតិបុគ្គល

ភាពគតិយុត្តដាច់ដោយឡែកពីសមាជិកហ៊ុន ដែលធ្វើឲ្យក្រុមហ៊ុនខ្លួនឯងជាអ្នកទទួលខុសត្រូវចំពោះបំណុលទាំងអស់។ ប្រសិនបើមានបញ្ហាណាមួយកើតឡើងចំពោះក្រុមហ៊ុន សមាជិកហ៊ុនទាំងអស់មិនមានទទួលរងការប៉ះពាល់ដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនទេ។ ម្ចាស់ភាគហ៊ុនទាំងអស់គ្រាន់តែទទួលខុសត្រូវត្រឹមកម្រិតហ៊ុនដែលមាននៅក្នុងក្រុមហ៊ុនប៉ុណ្ណោះ។ ពួកគេមិនប្រឈមមុខហានិភ័យខ្ពស់ក្នុងការសងប្រាក់ដោយប្រើប្រាស់ទ្រព្យឯកជនឡើយ។

ចំណុចសំខាន់មួយទៀតនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺហិរិញ្ញវត្ថុ និងធនធានរបស់ក្រុមហ៊ុន។ ដោយសារតែក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ជាប្រភេទក្រុមហ៊ុនមួយដែលច្បាប់តម្រូវឲ្យកំណត់មូលធនអប្បបរមា (២០.០០០.០០០រ) វាមានធនធានច្រើនដើម្បីប្រកបអាជីវកម្មរបស់ខ្លួននៅពេលបង្កើតដំបូង។ ជាមួយនឹងមូលធនសមប្រកប ក្រុមហ៊ុនអាចផលិតផលិតផលបានច្រើនក្នុងតម្លៃទាប ហើយអាចផ្តល់សេវាកម្មល្អប្រសើ ម្លោះហើយវាមានការកើនឡើងនូវប្រាក់ចំណេញ និងទទួលបានការពេញចិត្តពីអតិថិជន។ លើសពីនេះ អនាគតពាណិជ្ជកម្មក្រុមហ៊ុន មានភាពនឹងនរ និង ការធានាបានច្រើន។

គុណសម្បត្តិចុងក្រោយរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺស្ថេរភាពអាជីវកម្ម។ ដូចបានបញ្ជាក់ខាងលើ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានបុគ្គលភាពគតិយុត្តដាច់ពីសមាជិកហ៊ុនទាំងអស់។ ម្ចាស់ហ៊ុនគ្រាន់តែជាភ្នាក់ងារក្រុមហ៊ុន ដូចនេះក្រុមហ៊ុននៅតែអាចបន្តដំណើរការប្រព្រឹត្តទៅរបស់ខ្លួនបាន ទោះបីជាម្ចាស់ភាគហ៊ុនណាម្នាក់បានស្លាប់ ឬដកខ្លួនចេញពីក្រុមហ៊ុន។ វាក៏បានធានាសុវត្ថភាពការងារទៅឲ្យបុគ្គលិក និង ម្ចាស់ហ៊ុនដទៃទៀតផងដែរ។

## ខ. គុណវិបត្តិនៃទម្រង់ក្រុមហ៊ុនទាំងពីរ

### ខ.១. គុណវិបត្តិនៃទម្រង់ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

ត្បិតតែ ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានចំណុចមួយចំនួនដែលចាត់ទុកថាជាគុណសម្បត្តិ ក្រុមហ៊ុនប្រភេទនេះក៏មានផ្នែកអវិជ្ជមានផងដែរ។ បុគ្គលដែលចង់បង្កើតទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវពិចារណាឲ្យបានច្បាស់លាស់ជាពិសេសត្រូវគិតទៅលើគុណវិបត្តិទាំងនេះ។

គុណវិបត្តិធំជាងគេនោះគឺ សហកម្មសិទ្ធិករទូទៅត្រូវប្រឈមមុខខ្ពស់ចំពោះការទទួលខុសត្រូវចំពោះបំណុល នឹងកាតព្វកិច្ចក្រុមហ៊ុន។ ទោះទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ជា

ប្រភេទក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតក៏ដោយ សហាកម្មសិទ្ធករទូទៅត្រូវទទួលបន្ទុកចំពោះបំណុល និងកាតព្វកិច្ច ប្រសិនបើក្រុមហ៊ុនត្រូវបានគេប្តឹងឲ្យសងប្រាក់ ឬក្រុមហ៊ុនធ្លាក់ចូលក្នុងស្ថានភាពក្ស័យធន។ ការទទួលខុសត្រូវនេះគឺគ្មានកម្រិតឡើយ។ កម្មសិទ្ធិ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហាកម្មសិទ្ធិករទូទៅ សុទ្ធតែអាចក្លាយជាកម្មវត្ថុនៃការសងបំណុល។ មិនតែប៉ុណ្ណោះសេចក្តីសម្រេចរបស់សហាកម្មសិទ្ធិករណាម្នាក់ធ្វើឡើងក្នុងនាមក្រុមហ៊ុន វានឹងក្លាយជាបន្ទុក ដែលសហាកម្មសិទ្ធិករទូទៅដទៃទៀតត្រូវទទួលខុសត្រូវ។

ចំពោះសហាកម្មសិទ្ធិករមានកម្រិតវិញទោះបីជាពួកគេតម្រូវឲ្យទទួលខុសត្រូវចំពោះបំណុលត្រឹមកម្រិតភាគហ៊ុនដែលបានចូលរួម ប៉ុន្តែសិទ្ធិ និងតួនាទីក្នុងការគ្រប់គ្រងក្រុមហ៊ុនត្រូវបានហាមឃាត់។ ទោះបីជាការចូលរួមរបស់ពួកគេច្រើនក្តី តិចក្តី ពួកគេមិនមានសិទ្ធិពេញលេញក្នុងសេចក្តីសម្រេចណាមួយដែលទាក់ទងនឹងពាណិជ្ជកិច្ចក្រុមហ៊ុនទេ។ ប្រសិនបើពួកគេពាក់ព័ន្ធនឹងសេចក្តីសម្រេចណាក្នុងនាមក្រុមហ៊ុន គេត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។ ភាពគ្មានសិទ្ធិសម្រេចនេះ អាចបង្កឲ្យមានវិវាទកើតឡើងក្នុងក្រុមហ៊ុន ហើយវាក៏អាចបង្កឲ្យក្រុមហ៊ុនទាំងមូលស្ថិតក្នុងបញ្ហាផងដែរ។

ក្រៅពីចំណុចអវិជ្ជមានដែលមានចំពោះសហាកម្មសិទ្ធិករទូទៅ និង សហាកម្មសិទ្ធិករមានកម្រិត អាយុជីវិតក្រុមហ៊ុនក៏មានលក្ខណៈផុយស្រួយផងដែរ។ ក្នុងទម្រង់ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិត យោបល់របស់សហាកម្មសិទ្ធិករគឺមានសារៈសំខាន់ ហើយយោបល់ទាំងនោះត្រូវយកមកពីចារណា (ជាពិសេសយោបល់សហាកម្មសិទ្ធិករទូទៅ) ប៉ុន្តែសហាកម្មសិទ្ធិករប្រហែជាមិនយល់ស្របគ្នាចំពោះបញ្ហាណាមួយ ដែលជាលទ្ធផលអាចបង្កឲ្យមានវិវាទ។ ការមិនយល់ស្របគ្នាអាចបណ្តាលឲ្យមានការរំលោភកិច្ចសន្យាក្រុមហ៊ុន ឬឈានដល់ការរំលាយកិច្ចសន្យាផង។ ស្ថានភាបែបនេះអាចនឹងបង្កឲ្យមានរំលាយក្រុមហ៊ុន ព្រោះកិច្ចសន្យាទម្រង់ក្រុមហ៊ុនសហាកម្មសិទ្ធិមានកម្រិតដើរតួនាទីយ៉ាងសំខាន់ដើម្បីបង្កើតក្រុមហ៊ុន។ លើសពីនេះ មរណៈភាព ឬ ការបាត់បង់សមាជិកភាពរបស់សហាកម្មសិទ្ធិករទូទៅ ក៏ប៉ះពាល់ដល់អាយុជីវិតក្រុមហ៊ុនដែរ។ ប្រសិនបើតំណែងសហាកម្មសិទ្ធិករទូទៅមិនបានដាក់បំពេញជំនួសទេ វានឹងឈានដល់ការរំលាយក្រុមហ៊ុន។

### ខ.២. គុណវិបត្តិនៃទម្រង់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រៅចំណុចវិជ្ជមានដែលបានរៀបរាប់ខាងលើ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក៏មានចំណុចអវិជ្ជមានមួយចំនួនដូចជា ការចំណាយពេលវេលាយូដើម្បីបង្កើត ក្រុមហ៊ុនមិនអាចលក់ប័ណ្ណភាគហ៊ុនជាសាធារណៈ និងការរឹតត្បិតចំពោះការធ្វើអនុប្បទានភាគហ៊ុន។

ការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អាចត្រូវប្រើរយៈពេលយូ បើធៀបទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ពីព្រោះច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មបានតម្រូវឲ្យម្ចាស់ហ៊ុន ដែលចង់បង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បង្កើតជាលក្ខន្តិកៈក្រុមហ៊ុន។ សមាជិកហ៊ុនទាំងអស់ត្រូវពិភាក្សាគ្នារាល់ចំណុចលម្អិតដែលត្រូវដាក់បញ្ចូលក្នុងលក្ខន្តិកៈ មិនតែប៉ុណ្ណោះបើសិនជាម្ចាស់ភាគហ៊ុនមិនមានជំនាញ និងបទពិសោធទេ ពួកគេត្រូវការជួលមេធាវី ឬក៏សាស្ត្រាចារ្យច្បាប់ដើម្បីតាក់តែងលក្ខន្តិកៈក្រុមហ៊ុន។

ច្បាប់មិនអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត លក់ប័ណ្ណភាគហ៊ុនជាសាធារណៈទេ។ ដោយសារក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនអាចដាក់លក់ប័ណ្ណភាគហ៊ុនរបស់ខ្លួនជាសាធារណៈ វាក្លាយជាគុណវិបត្តិមួយសម្រាប់ក្រុមហ៊ុនក្នុងការស្វែងរកអ្នកដាក់ទុនជាសាធារណៈជន។

ការធ្វើអនុប្បទានភាគហ៊ុនរបស់សមាជិកហ៊ុនក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺមានលក្ខណៈរឹតត្បិត ដែលជាចំណុចអវិជ្ជមានមួយ។ ទោះបីជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ជាក្រុមហ៊ុនមូលធនដែលមានការរាប់អានប្រាក់កាស ប៉ុន្តែម្ចាស់ហ៊ុនមិនអាចធ្វើអនុប្បទានភាគហ៊ុនបានដោយសេរីទេ ជាពិសេសការធ្វើអនុប្បទានឲ្យតតិយជន។ សមាជិកហ៊ុនដែលមានបំណងធ្វើអនុប្បទានភាគហ៊ុនទៅឲ្យតតិយជន ត្រូវជូនដំណឹងទៅឲ្យសមាជិកដទៃទៀតសម្រេច។ សេចក្តីសម្រេចចំពោះការធ្វើអនុប្បទានភាគហ៊ុនអាចយកជាបានការដោយសំឡេង ៥០% + ១ នៃសំឡេងអ្នកមានសិទ្ធិបោះឆ្នោត តែការសម្រេចនេះអាចមានលក្ខណៈរឹតត្បិតជាងនេះអាស្រ័យទៅតាមការកំណត់របស់ម្ចាស់ហ៊ុន ដែលបានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុននីមួយៗ។

# សេចក្ដីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវក្រោមប្រធានបទ "ការប្រៀបធៀបក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឃើញថាក្រុហ៊ុមនទាំងពីរ មានលក្ខណៈជាច្រើនដូចគ្នា ប៉ុន្តែក៏នៅមានភាពខុសគ្នាផងដែរ។ ក្នុងនោះមានលក្ខណៈខុសគ្នាចម្បង ៣ ដែលគួរឲ្យកត់សម្គាល់។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត និង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានរចនាសម្ព័ន្ធខុសគ្នា។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺជាក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានរូបវន្តបុគ្គលច្រើនរូបបានចែករំលែកភាពជាម្ចាស់នៃក្រុមហ៊ុន ដែលនៅក្នុងនោះ សហកម្មសិទ្ធិករទូទៅផ្ទាល់ ត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនទាំងមូល ចំពោះកិច្ចការគ្រប់គ្រង និងបំណុល ហើយសហកម្មសិទ្ធិករមានកម្រិតគ្រាន់តែជាអ្នកដាក់ទុន ឬអ្នកវិនិយោគដោយប្រយោលប៉ុណ្ណោះ។ ចំពោះក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតវិញ រចនាសម្ព័ន្ធរបស់វាមានលក្ខណៈស្មុគស្មាញជាង ហើយសេចក្ដីសម្រេចសំខាន់ៗ គឺពាក់ព័ន្ធនឹងបុគ្គលច្រើនរូប។ ម្ចាស់ហ៊ុនជាទាំងអស់ជាអ្នកសម្រេចថាក្រុមហ៊ុនត្រូវគ្រប់គ្រងដោយរបៀបណា និងជ្រើសរើសអ្នកគ្រប់គ្រង។ ភាពខុសគ្នាទី ២ គឺ ការទទួលខុសត្រូវចំពោះបំណុលក្រុមហ៊ុនរបស់សមាជិកហ៊ុន។ សហកម្មសិទ្ធិករទូទៅត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបំណុលក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដែលវាអាចបណ្ដាលឲ្យការប៉ះពាល់ដល់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សហកម្មសិទ្ធិករទូទៅ។ ខណៈដែល ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវចាត់ទុកមាននីតិបុគ្គលភាពដាច់ដោយឡែកពីម្ចាស់ហ៊ុន ក្រុមហ៊ុនផ្ទាល់ជាអ្នកទទួលខុសត្រូវចំពោះបំណុល រីឯម្ចាស់ហ៊ុនមិនប្រឈមនឹងការបាត់បង់ទ្រព្យសម្បត្តិឯកជនរបស់ខ្លួនទេ។ ការគ្រប់គ្រងគឺជាលក្ខណៈខុសគ្នាចុងក្រោយរបស់ក្រុមហ៊ុនទាំងពីរ។ ការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានលក្ខណៈសាមញ្ញ និងរហ័ស ដែលសហកម្មសិទ្ធិករទូទៅមានភារៈកិច្ចគ្រប់គ្រង និងសម្រេចចិត្តផ្នែកអាជីវកម្មដោយខ្លួនឯងបាន។ ខុសពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលតម្រូវឲ្យមានមហាសន្និបាតម្ចាស់ភាគហ៊ុនប្រចាំឆ្នាំជាដាច់ខាត ដើម្បីកំណត់ពីការគ្រប់គ្រង និង គោលនយោបាយក្រុមហ៊ុន។ ម្ចាស់ហ៊ុនមិនមានភារៈកិច្ចគ្រប់គ្រងប្រចាំថ្ងៃទេ តែត្រូវត្រួបពិនិត្យអ្នកគ្រប់គ្រងដែលខ្លួនបានជ្រើសរើស។

តែទោះបីជា ភាពខុសគ្នានៃក្រុមហ៊ុនទាំងពីរបានបង្កើតឲ្យមានលក្ខណៈពិសេស និងចំណុចអវិជ្ជមានរៀងៗខ្លួនក៏ដោយ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតពិតជាមានការពេញនិយមខ្លាំងនៅប្រទេសកម្ពុជា ជាជាងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ការពេញនិយមចំពោះក្រុមហ៊ុន

ឯកជនទទួលខុសត្រូវមានកម្រិត គឺដោយសារតែប្រភេទក្រុមហ៊ុននេះមានរចនាសម្ព័ន្ធមួយរឹងមាំ ដែលកើតចេញពីលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុង (បើធៀបនឹងកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត) ដែលបានចងជា សិទ្ធិនិងកាតព្វកិច្ច និង ទំនាក់ទំនងសមាជិកភាគហ៊ុន ក៏ដូចជា ដំណើរការគ្រប់គ្រងក្រុមហ៊ុនផងដែរ។ មិនតែប៉ុណ្ណោះមូលធនអប្បបរមា (២០ ០០០ ០០០៛) ដែលមិនតិចពេក ហើយក៏មិនច្រើនពេក ជាកត្តាមួយអាចឲ្យបុគ្គលដែលមានធនធានសមគួរអាចចូលហ៊ុនគ្នាបង្កើតជាក្រុមហ៊ុនបាន។ លើសពីនេះទៅទៀតដំណើរការអាជីវកម្មក្រុមហ៊ុនមានលក្ខណៈអចិន្ត្រៃយ៍ និងសថិតថេរដោយសារតែមរណៈភាព ឬការបាត់បង់សមាជិកហ៊ុនណាម្នាក់គឺមិនអាចប៉ះពាល់នឹងអាយុជីវិតក្រុមហ៊ុនឡើយ ដែលជាហេតុនាំឲ្យក្រុមហ៊ុនមានកិត្តិនាមយូរអង្វែង និងអាចពង្រីកក្រុមហ៊ុនកាន់តែធំ។ ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញមានចំណុចជាច្រើនដែលនាំឲ្យក្រុមហ៊ុននេះមិនមានការពេញនិយម។ វាអាចបណ្តាលមកពីការមិនយល់ច្បាស់លាស់ពីទម្រង់ និងអត្ថប្រយោជន៍ក្រុមហ៊ុនសហកម្មសិទ្ធិ និង ភាពគ្មានទំនុកចិត្តចំពោះគ្នារវាងសហកម្មសិទ្ធិករដែលងាយនឹងបង្ករឲ្យមានវិវាទ។ វិធានដែលអនុវត្តចំពោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនអាចញែកដាច់ចេញពីក្រុមហ៊ុនហកម្មសិទ្ធិទូទៅ ជាមូលហេតុមួយបង្ករឲ្យមានភាពភ័ន្តច្រលំចំពោះសហកម្មសិទ្ធិករ និងតតិយជន។ ភាពគ្មានសិទ្ធិសម្រេចនៃសហកម្មសិទ្ធិករមានកម្រិត ហានិភ័យខ្ពស់ក្នុងការទទួលខុសត្រូវចំពោះបំណុលដោយគ្មានកម្រិតរបស់សហកម្មសិទ្ធិករទូទៅ និងភាពផុយស្រួយនៃអាយុជីវិតក្រុមហ៊ុន សុទ្ធតែជាឧបសគ្គក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។

សរុបសេចក្តីមក ការសម្រេចចិត្តជ្រើសរើសប្រភេទក្រុមហ៊ុនឲ្យសាកសមនឹងសមត្ថភាពរបស់យើងគឺវាពិតជាមានការលំបាក ផ្ទុយទៅវិញប្រសិនបើយើងធ្វើការជ្រើសរើសត្រឹមត្រូវវាជាផ្នែកនៃជោគជ័យរបស់យើងផងដែរ។ ជម្រើសដ៏ត្រឹមត្រូវវាអាស្រ័យលើខ្លួនរបស់យើងដែលទាមទារឲ្យមានការពិចារណា ដូច្នេះប្រសិនបើយើងមានបំណងចង់បង្កើតក្រុមហ៊ុន ដែលមានលក្ខណៈទទួលខុសត្រូវមានកម្រិត យើងគប្បីស្វែងយល់ពីទម្រង់ក្រុមហ៊ុនឲ្យបានច្បាស់លាស់ជាមុនសិន។ ការស្វែងយល់ពីទម្រង់ក្រុមហ៊ុនជាកត្តាសំខាន់ដែលបង្ហាញឲ្យយើងដឹងថា ក្រុមហ៊ុនណាដែលសាកសមនឹងស្ថានភាពរបស់យើង? ក្រុមហ៊ុនប្រភេទណាអាចផ្តល់អត្ថប្រយោជន៍បានច្រើន ហើយងាយស្រួលក្នុងការគ្រប់គ្រង ជាពិសេសទទួលបន្ទុកកាតព្វកិច្ចទាបឬទេ? បញ្ហាទីពីរ ដែលយើងត្រូវតែដឹងគឺការស្គាល់ច្បាស់ពីសមាជិកហ៊ុនដ៏ទៃទៀតដូចជា ការស្វែងយល់ពីចិត្តគំនិតថាតើគេមានបំណងពិតប្រាកដចូលហ៊ុនជាមួយយើងឬទេ? ជាពិសេសត្រូវដឹងពីប្រវត្តិរបស់បុគ្គលនោះ និងសមត្ថភាពពិតប្រាកដរបស់បុគ្គលនោះផងដែរ។ ជាចុងក្រោយបញ្ហាដែលសំខាន់បំផុតយើងដាច់

ខាតត្រូវដឹងពីស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្នដើម្បីងាយស្រួលក្នុងដំណើរការអាជីវកម្ម។ ការដឹងពីតម្រូវការសង្គមជាចំណុចមួយដែលឲ្យយើងកំណត់កម្មវត្ថុអាជីវកម្មមួយប្រកបដោយទំនុកចិត្ត។ ដូច្នេះដើម្បីជៀសផុតពីហានិភ័យទាំងឡាយអ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុន ឬអ្នកចូលហ៊ុនទាំងឡាយគប្បីពិភាក្សាគ្នាជាមុនសិន អាចជាការបើកការប្រជុំលក្ខណៈក្រៅផ្លូវការដើម្បីធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវមួយ ។ ការធ្វើបែបនេះអាចមានអត្ថប្រយោជន៍សម្រាប់សមាជិកទាំងមូលដើម្បីសម្តែងការពេញចិត្តរបស់ខ្លួនជៀសវាងការមិនពេញចិត្ត ឬវិវាទណាមួយក្រោយពេលបានបង្កើតក្រុមហ៊ុនរួច។ តាមការបកស្រាយខាងលើឃើញថាក្រុមហ៊ុនទាំងពីរសុទ្ធតែមានគុណសម្បត្តិនិងគុណវិបត្តិរបស់វា តែអ្វីដែលសំខាន់នោះគឺយើងត្រូវដឹងខ្លួនឯងថាតើប្រភេទក្រុមហ៊ុនមួយណាសាកសមនឹងសមត្ថភាពនិងលក្ខណៈសម្បត្តិរបស់យើង និងអាចផ្តល់អត្ថប្រយោជន៍ច្រើនជាង? ដូច្នេះការគិតមុនគួរវាជាកត្តាសំខាន់ដែលយើងត្រូវធ្វើមុនគេព្រោះការសម្រេចចិត្តដ៏ត្រឹមត្រូវ ហើយវាក៏ជាផ្នែកមួយនៃភាពជោគជ័យរបស់ខ្លួនផងដែរ។

# ឯកសារយោង


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥។

ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, លេខ នស/រកម/០៦៩៥/០៤, ២៦ មិថុនា ១៩៩៥។

ប្រកាសស្តីពីការចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម, លេខ ៣៨១ ពណ.នតកប្រក, ០៩ ធ្នូ ១៩៩៨។

## សៀវភៅ

គង់ សាផន, *នីតិពាណិជ្ជកម្ម*, ភ្នំពេញ៖ អ៊ីម៉េក ព្រីនធីង, ២០១២។

អ៊ី ប៉ូលី, *នីតិក្រុមហ៊ុន*, ភ្នំពេញ, ២០០៨។

ក្រសួងពាណិជ្ជកម្ម, *សៀវភៅស្តីពីក្រុមហ៊ុនមហាជន ក្រុមហ៊ុនឯកជន និងក្រុមហ៊ុនសហកម្មសិទ្ធិ*, ភ្នំពេញ។

ក្រសួងពាណិជ្ជកម្ម, *មូលដ្ឋានគ្រឹះនៃច្បាប់ពាណិជ្ជកម្ម*, ភ្នំពេញ។

## របាយការណ៍

ក្រសួងពាណិជ្ជកម្ម. ២០១៦. *របាយការណ៍បូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១៦ និង ទិសដៅអនុវត្តន៍ការងារពាណិជ្ជកម្មឆ្នាំ២០១៧*. ភ្នំពេញ។

## គេហទំព័រ

Marnie Kunz, *Five major differences between a corporation and a partnership*, http://smallbusiness.chron.com/5-major-differences-between-corporation-partnership-18830.html (**ថតចម្លងថ្ងៃទី ១៤ មិថុនា ២០១៧**)។

https://www.thecompanywarehouse.co.uk/blog/advantages-and-disadvantages-of-partnership (ចូលទស្សនាថ្ងៃទី ០១ មិថុនា ២០១៧)។

https://www.thecompanywarehouse.co.uk/blog/advantages-and-disadvantages-of-a-limited-company (ចូលទស្សនាថ្ងៃទី ០១ មិថុនា ២០១៧)។

# លក្ខន្តិកៈក្រុមហ៊ុន

# ARTICLES OF INCORPORATION

## អាលីអាត ភាវី ប្រាយវេត ខមភេនី លីមីធីត

## ALIAT PHEAVY PRIVATE COMPANY LIMITED

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត-ដើមទុន ៖ ៤០.០០០.០០០ រៀល
(=១០.០០០ ដុល្លារអាមេរិក អត្រា ៤.០០០ រៀល/ដុល្លារអាមេរិក)

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
តំកល់ចុះលេខ: 3091/2015
ថ្ងៃទី 24-06-2015 ម៉ោង 15h00'
មន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

# លក្ខន្តិកៈ

# ក្រុមហ៊ុន

# អាលីអាត ភាវី ប្រាយវេត ខមភេនី លីមីធីត

## ALIAT PHEAVY PRIVATE COMPANY LIMITED

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត-ដើមទុន ៖ ៤០.០០០.០០០ រៀល
(=១០.០០០ ដុល្លារអាមេរិក អត្រា ៤.០០០ រៀល/ដុល្លារអាមេរិក)

អ្នកដែលមានរាយឈ្មោះខាងក្រោម ៖

១-កញ្ញា **សេង សុចិន្តា វុនាថ** ពាណិជ្ជករ សញ្ជាតិខ្មែរ
SENG SOCHINDA VUNIETH ទីលំនៅ ៖ លេខ ២០Eo ផ្លូវលេខ ៨៨ សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លិខិតឆ្លងដែនលេខ៖ N1418040 ចុះថ្ងៃទី 05-04-2013

២-លោក DUONG THANH LONG ពាណិជ្ជករ សញ្ជាតិវៀតណាម
ទីលំនៅ ៖ PN Techcon Apartments, Phu Nhuan District,
Ho Chi Minh City, Vietnam.
លិខិតឆ្លងដែនលេខ៖ B6413279 ចុះថ្ងៃទី 09-03-2012

៣-លោក NGUYEN QUOC PHONG ពាណិជ្ជករ សញ្ជាតិវៀតណាម
ទីលំនៅ ៖ Cuu Long Apartments, Binh Thanh District,
Ho Chi Minh City, Vietnam.
លិខិតឆ្លងដែនលេខ៖ B7412419 ចុះថ្ងៃទី 19-02-2013

៤-លោក **សេង សុចិន្តា** សញ្ជាតិខ្មែរ
SENG SOCHINDA ទីលំនៅ ៖ លេខ ២០Eo ផ្លូវលេខ ៨៨ សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
អត្តសញ្ញាណប័ណ្ណលេខ៖ 010075699 ចុះថ្ងៃទី 24-10-2001

បានរៀបចំលក្ខន្តិកៈនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយទៅតាមការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តនិងតាមលក្ខខណ្ឌដូចតទៅ ៖

# ប្រការ ១
## នាមករណ៍-ទ្រនំប្រាយ

### ១-១ ៖ នាមករណ៍

ក្រុមហ៊ុនមាននាមថា ៖

**អាលីអាត ភាវី ប្រាយវេត ខមភេនី លីមីធីត**

**ALIAT PHEAVY PRIVATE COMPANY LIMITED**

ក្រុមហ៊ុនមានត្រាសម្គាល់ សម្រាប់ក្រុមហ៊ុនប្រើប្រាស់ ដែលមាននាមករណ៍របស់ក្រុមហ៊ុននៅក្នុងផ្ទៃត្រា ។

នៅក្នុងរាល់លិខិតស្នាម វិក្កយបត្រ ឯកសារផ្សព្វផ្សាយ និងឯកសារផ្សេងៗទៀតគ្រប់ប្រភេទ ដែលផ្សាយចេញពីក្រុមហ៊ុន ត្រូវតែមានចែងពីក្រោយ ឬពីក្រោមនាមករណ៍ នូវពាក្យថា ៖ " ក្រុមហ៊ុនឯកជន ទទួលខុសត្រូវមានកម្រិត " ឬសរសេរជាអក្សរកាត់ ។

### ១-២ ៖ ទ្រនំប្រាយ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយត្រូវបានបង្កើតឡើង ដែលក្នុងនោះមានម្ចាស់ហ៊ុនដូចមានចែងនៅក្នុងប្រការខាងក្រោយ នឹងអាចបន្ថែមម្ចាស់ហ៊ុននៅពេលក្រោយទៀត ។

ចាប់ពីថ្ងៃបានចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិច្បាប់ ក្រុមហ៊ុននេះមាននីតិបុគ្គលិកលក្ខណៈផ្ទាល់ ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រោមការកំណត់នៃប្រការទាំងឡាយ ដែលចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

# ប្រការ ២
## កម្មវត្ថុអាជីវកម្ម

ក្រុមហ៊ុនមានកម្មវត្ថុអាជីវកម្មនៅកម្ពុជានិងនៅប្រទេសដទៃដោយចំពោះ ឬមិនចំពោះដូចតទៅ ៖

១- សេវាពិគ្រោះយោបល់លើផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុ និងវិនិយោគ
២- ភ្នាក់ងារពាណិជ្ជកម្ម-តំណាងពាណិជ្ជកម្ម

៣- សេវាកកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

៤- សេវាផ្នែកព័ត៌មានវិទ្យា

៥- សេវាផ្សាយពាណិជ្ជកម្ម

៦- បោះពុម្ពផ្សាយ

៧- សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន

៨- ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ ការប្តូរប្រាក់ ( exchanging) នីហរ័ណ អាហរ័ណទំនិញ ឱសថ និងសម្ភារៈបរិក្ខារពេទ្យ គ្រប់ប្រភេទ

ការចូលរួមតាមគ្រប់មធ្យោបាយរបស់ក្រុមហ៊ុនជាមួយរាល់សហគ្រាស ឬក្រុមហ៊ុនដទៃ ដែលមានហើយ ឬដែលនឹងបង្កើត និងដែលមានជាប់ទាក់ទងដោយចំពោះ ឬមិនចំពោះដល់កម្មវត្ថុអាជីវកម្ម ពិសេសតាមវិធីបង្កើតក្រុមហ៊ុនថ្មី ភាគទុន ការចុះឈ្មោះ ឬទិញសិទ្ធិសមាជិក ការរំលាយបញ្ចូលគ្នា សម្ព័ន្ធភាព ឬការចូលរួមសហប្រតិបត្តិការនានា ។

ជាទូទៅ ក្រុមហ៊ុនធ្វើរាល់ប្រតិបត្តិការពាណិជ្ជកម្មដែលជាប់ទាក់ទងដោយចំពោះ ឬមិនចំពោះ ឬប្រហាក់ប្រហែលគ្នា ឬប្រទាក់គ្នា នឹងសកម្មភាពខាងលើ ក្នុងគោលដៅធ្វើឱ្យក្រុមហ៊ុនមានការរីកចម្រើន ។

## ប្រការ ៣
## ទីស្នាក់ការ

ទីស្នាក់ការក្រុមហ៊ុនតាំងនៅ លេខ ២០E, ផ្លូវលេខ ៨៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ទីស្នាក់ការនេះ អាចត្រូវបានផ្ទេរទៅនៅកន្លែងផ្សេងទៀតក្នុងក្រុង ឬខេត្តដដែល អាស្រ័យដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងផ្ទេរទៅទីកន្លែងផ្សេងទៀតក្រៅពីក្រុង ឬខេត្តនៃទីតាំងចាស់ អាស្រ័យដោយសេចក្តីសម្រេចមហាសន្និបាតម្ចាស់ហ៊ុន ។

តាមសេចក្តីសម្រេចនៃមហាសន្និបាតម្ចាស់ហ៊ុន ព្រមទាំងអនុលោមទៅតាមច្បាប់ជាធរមាន ក្រុមហ៊ុនអាចមានសាខាមួយ ឬច្រើនកន្លែងរបស់ក្រុមហ៊ុននៅតាមបណ្តាលខេត្តនានា ឬនៅបរទេស ។

## ប្រការ ៤
## ថិរវេលា

ថិរវេលាសកម្មភាពរបស់ក្រុមហ៊ុនមានចំនួន ៩៩ឆ្នាំ ដែលត្រូវផ្តើមគិតចាប់ពីថ្ងៃបានចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម លើកលែងតែមានករណីរំលាយក្រុមហ៊ុនមុនកាលកំណត់ឬការពន្យារពេលបន្ត។

យ៉ាងតិចណាស់មួយឆ្នាំមុនការផុតកំណត់នៃថិរវេលា ៩៩ឆ្នាំ នេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំឱ្យមានការប្រជុំមហាសន្និបាតនៃម្ចាស់ហ៊ុន ដើម្បីសម្រេចទៅតាមលក្ខខណ្ឌទាំងឡាយនៃកូរ៉ុម និងភាគច្រើន

ដែលតម្រូវចាំបាច់សម្រាប់កែប្រែលក្ខន្តិកៈ ថាតើក្រុមហ៊ុនត្រូវរំលាយ ឬត្រូវពន្យារពេលបន្ត ។ បើប្រធានក្រុមប្រឹក្សាភិបាលមិនបានកោះប្រជុំធ្វើសេចក្តីសម្រេចនេះទេ សំឡេង ១/៣ នៃអំណាចបោះឆ្នោតម្ចាស់ហ៊ុនទាំងអស់ ក្រោយពេលដែលបានដាក់ពាក្យសុំឱ្យប្រជុំតាមរយៈលិខិតអនុសិដ្ឋិ ហើយមិនបានទទួលផលតាមសំណូមពរនោះ អាចស្នើសុំទៅប្រធានតុលាការមានសមត្ថកិច្ច តែងតាំងអាណត្តិតាហកបស់តុលាការឱ្យទទួលបន្ទុករៀបចំការប្រជុំក្នុងនាមម្ចាស់ហ៊ុនទាំងអស់ធ្វើសេចក្តីសម្រេចអំពីបញ្ហានេះ ។

# ប្រការ ៥
## ដើមទុន-ភាគហ៊ុន-ម្ចាស់ហ៊ុន

### ៥-១ ៖ ដើមទុន-ភាគហ៊ុន

ម្ចាស់ហ៊ុន ដែលមានរាយនាមដូចខាងក្រោមបានដាក់ភាគទុនជាសាច់ប្រាក់ដូចតទៅ ៖

| | |
|---|---|
| ១-លោក **សេខ សុចិន្តា** | ចំនួន 12,000,000 រៀល |
| ២-កញ្ញា **សេខ សុចិន្តា ឌរនោថ** | ចំនួន 10,000,000 រៀល |
| ៣-លោក DUONG THANH LONG | ចំនួន 10,000,000 រៀល |
| ៤-លោក NGUYEN QUOC PHONG | ចំនួន 8,000,000 រៀល |

សរុបភាគទុនទាំងអស់ចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល)
(=១០.០០០ ដុល្លារអាមេរិក អត្រា ៤.០០០ រៀល/ដុល្លារអាមេរិក)

ភាគទុនសរុបចំនួន ៤០.០០០.០០០ រៀល នេះត្រូវបង់ចូលមកក្នុងបេឡាក្រុមហ៊ុនជាសាច់ប្រាក់ទាំងស្រុងនិងគ្រប់ចំនួនដោយម្ចាស់ហ៊ុនទៅតាមភាគហ៊ុនផ្ទាល់ខ្លួនម្នាក់ៗ ហើយការបង់បញ្ចូលនេះត្រូវបានម្ចាស់ហ៊ុនទាំងអស់គ្នាទទួលស្គាល់ថាពិតជាបានបង់គ្រប់ចំនួនមែន ។

ដើមទុនចុះបញ្ជីក្រុមហ៊ុនត្រូវបានកំណត់ចំនួន ៤០.០០០.០០០ រៀល (សែសិបលានរៀល) ស្មើនឹងចំនួនទឹកប្រាក់សរុបដែលបានបង់ខាងលើ ។ ដើមទុននេះត្រូវបានបែងចែកជាចំនួន ១.០០០ ភាគហ៊ុន ដែលនៅក្នុងនោះភាគហ៊ុននីមួយៗមានតម្លៃ ៤០.០០០ រៀល ។

ភាគហ៊ុនទាំងឡាយខាងលើនេះត្រូវតែបង់បញ្ចូលមកក្នុងក្រុមហ៊ុនទាំងស្រុងនិងគ្រប់ចំនួនហើយត្រូវបានបែងចែកនិងចុះលេខជូនម្ចាស់ហ៊ុនម្នាក់ៗ ទៅតាមសមាមាត្រនៃភាគទុនរៀងៗខ្លួនគឺ ៖

| | |
|---|---|
| ១-លោក **សេខ សុចិន្តា** | មានចំនួន 300 ភាគហ៊ុន ពីលេខ 0001 ដល់លេខ 0300 |
| ២- កញ្ញា **សេខ សុចិន្តា ឌរនោថ** | មានចំនួន 250 ភាគហ៊ុន ពីលេខ 0301 ដល់លេខ 0550 |
| ៣-លោក DUONG THANH LONG | មានចំនួន 250 ភាគហ៊ុន ពីលេខ 0551 ដល់លេខ 0800 |
| ៤-លោក NGUYEN QUOC PHONG | មានចំនួន 200 ភាគហ៊ុន ពីលេខ 0801 ដល់លេខ 1000 |

សរុបចំនួនភាគហ៊ុនមាន ១.០០០ ភាគហ៊ុន ស្មើនឹងដើមទុនក្រុមហ៊ុនចំនួន ៤០.០០០.០០០ រៀល
(ជាអក្សរ ៖ ចំនួនមួយពាន់ភាគហ៊ុន ស្មើនឹងដើមទុន សែសិបលានរៀល)

រាល់ម្ចាស់ហ៊ុនប្រកាសថា ភាគហ៊ុនចំនួន ១.០០០ ភាគហ៊ុន ដែលបានបង្កើតឡើងនិងបែងចែកតាមសមាមាត្រដូចខាងលើ គឺបានទទួលការយល់ព្រមរវាងគ្នានិងគ្នាព្រមទាំងបានត្រូវបង់បញ្ចូលគ្រប់ចំនួនមកក្នុងក្រុមហ៊ុន ។ គ្រប់ភាគហ៊ុនត្រូវបានចុះបញ្ជីទៅតាមចំណែកនៃម្ចាស់ហ៊ុន ។

អាចទទួលសិទ្ធិជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន តែល្គឹកណាដែលមានកម្មសិទ្ធិភាគហ៊ុនដែលបានបែងចែកជូន ។ ក្នុងករណីចង់ធ្វើអនុប្បទានភាគហ៊ុន ត្រូវតែមានការព្រមព្រៀងរវាងម្ចាស់ហ៊ុនទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងប្រការ ៦ ចំណុច ៦-២ នៃលក្ខន្តិកៈនេះ ។

## ៥-២ ៖ ការបង្កើនដើមទុន-ការបន្ថយដើមទុន

### ការបង្កើនដើមទុន

ដើមទុនអាចត្រូវបានបង្កើនតាមគ្រប់វិធី ដែលច្បាប់អនុញ្ញាត ព្រមទាំងឱ្យស្របទៅតាមសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុន ៖

-បង្កើតបន្ថែមភាគហ៊ុនថ្មីៗ ជាសាច់ប្រាក់ ឬជាវត្ថុ

-បង្វិលបញ្ចូលមួយភាគ ឬទាំងស្រុងនៃមូលនិធិបម្រុងមកក្នុងដើមទុន

-ដំឡើងតម្លៃ នៃភាគហ៊ុននីមួយៗ ដែលមានរួចហើយ

-តាមគ្រប់វិធីដទៃទៀត ដែលច្បាប់អនុញ្ញាត

ក្នុងករណីបង្កើនដើមទុន តាមវិធីដំឡើងតម្លៃនៃភាគហ៊ុន ដែលមានរួចហើយ និងដែលត្រូវបង់ចូលមកក្នុងក្រុមហ៊ុនជាសាច់ប្រាក់នោះ ត្រូវតែមានសេចក្តីសម្រេចដោយឯកច្ឆន្ទអំពីម្ចាស់ហ៊ុន ។

ការយល់ព្រមទទួលជាអនុប្បទានិក ចំពោះជនដែលត្រូវបញ្ចូលមកក្នុងក្រុមហ៊ុន នាឱកាសបង្កើនដើមទុន ស្របទៅតាមប្រការ ៦ ត្រូវតែធ្វើឱ្យបានត្រឹមត្រូវទៅតាមលក្ខខណ្ឌកំណត់ក្នុងប្រការនេះ ។

ក្នុងករណីបង្កើនដើមទុនដោយដាក់បន្ថែមភាគទុនជាវត្ថុ ភាគទុនជាវត្ថុនេះត្រូវតែបានវាយតម្លៃដោយស្នងការភាគទុន កាលណាតម្លៃភាគទុននេះលើសពី ៤០% នៃដើមទុន ។ បើតម្លៃភាគទុនជាវត្ថុនេះមានតម្លៃតិចជាង ៤០% នៃដើមទុនក្រុមហ៊ុន ការវាយតម្លៃភាគទុននេះអាចធ្វើឡើងដោយត្រឹមតែម្ចាស់ហ៊ុនទាំងអស់គ្នា ។

ក្នុងករណីបង្កើនដើមទុនដោយភាគទុនជាសាច់ប្រាក់ រាល់ម្ចាស់ហ៊ុន លើកលែងតែមានការប្រកែកត្រឹមត្រូវ មានសិទ្ធិជ្រើសរើសយកចំនួនភាគទុនថ្មីទៅតាមសមាមាត្រនៃភាគទុនដែលខ្លួនមាន ទៅតាមបែបបទមួយកំណត់ដោយសេចក្តីសម្រេចនៃមហាសន្និបាតម្ចាស់ហ៊ុន ។

### ការបន្ថយដើមទុន

ដើមទុនអាចត្រូវបានបន្ថយ អាស្រ័យដោយសេចក្តីសម្រេចនៃមហាសន្និបាតម្ចាស់ហ៊ុន ដែលសម្រេចទៅតាមលក្ខខណ្ឌបញ្ញត្តិនៃច្បាប់ ។ ក៏ប៉ុន្តែការបន្ថយដើមទុន មិនត្រូវឱ្យប៉ះពាល់ដល់សមភាពនៃម្ចាស់ហ៊ុន ឬក៏មិនត្រូវឱ្យនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូង និងទាបជាងដើមទុនកំណត់ដោយច្បាប់ ។ ការបន្ថយដើមទុន ត្រូវតែអនុញ្ញាតដោយមហាសន្និបាតម្ចាស់ហ៊ុន ។

## ៥-៣ ៖ មហាសន្និបាតម្ចាស់ហ៊ុន

**៥-៣.១ ៖**

មហាសន្និបាតម្ចាស់ហ៊ុនត្រូវប្រារព្ធឡើងយ៉ាងហោចណាស់ ១ឆ្នាំម្តង ក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**៥-៣.២ ៖**

មហាសន្និបាតម្ចាស់ហ៊ុនអាចកោះប្រជុំនៅពេលណាក៏បាន ដោយម្ចាស់ភាគហ៊ុនណាក៏បាន ឬដោយប្រធានក្រុមប្រឹក្សាភិបាល ឬដោយសវនករ ។

**៥-៣.៣ ៖**

សម័យប្រជុំនៃមហាសន្និបាតត្រូវធ្វើឡើងនៅទីស្នាក់ការក្រុមហ៊ុន ឬនៅកន្លែងដទៃទៀត ដូចមានបញ្ជាក់ក្នុងលិខិតអញ្ជើញ ។ លិខិតអញ្ជើញត្រូវមានចែងពីកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែងមហាសន្និបាត និងផ្ញើជូនម្ចាស់ហ៊ុនទាំងអស់ យ៉ាងហោចណាស់ ២០ថ្ងៃមុនថ្ងៃប្រជុំ ។

រាល់ម្ចាស់ហ៊ុនត្រូវតម្កល់ទុកនៅក្នុងទីស្នាក់ក្រុមហ៊ុន នូវអាសយដ្ឋានជាក់លាក់បច្ចុប្បន្នរបស់ខ្លួន ។ បើពុំដូច្នោះទេ ម្ចាស់ហ៊ុននោះមិនអាចប្តឹងតវ៉ាបានឡើយ ប្រសិនបើខ្លួនមិនបានទទួលសេចក្តីជូនដំណឹងពីកិច្ចប្រជុំណាមួយ ។

**៥-៣.៤ ៖**

កូរ៉ុមនៃរាល់មហាសន្និបាតម្ចាស់ហ៊ុន គឺត្រូវមានវត្តមានដោយផ្ទាល់ ឬ អ្នកតំណាងរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ។

**៥-៣.៥ ៖**

សេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុនអាចយកជាការបាន លុះណាតែមានការយល់ព្រមពីម្ចាស់ហ៊ុន ដែលតំណាងឱ្យសំឡេងជាឯកច្ឆន្ទ( ១០០%) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

**៥-៣.៦ ៖**

មហាសន្និបាតម្ចាស់ហ៊ុនអាចធ្វើឡើងដោយការឆ្លើយតបជាលិខិតលាយលក្ខអក្សរជំនួសការមកចូលរួមប្រជុំដោយផ្ទាល់ ។

ក្នុងករណីនេះ សេចក្តីសម្រេចអាចយកជាការបាន លុះណាតែមានការយល់ព្រមជាឯកច្ឆន្ទអំពីម្ចាស់ហ៊ុនទាំងអស់ ។

**៥-៣.៧ ៖**

ម្ចាស់ហ៊ុនទាំងអស់មានសិទ្ធិពេញលេញនៅក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ទោះបីគេមានឋានៈណាក៏ដោយ ឬមានភាគហ៊ុនប៉ុន្មានក៏ដោយ ។ គេមានសិទ្ធិផ្តល់សំឡេងស្មើនឹងចំនួនភាគហ៊ុនដែលគេមានដោយគ្មានការកម្រិតអ្វីឡើយ ។ ម្ចាស់ហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនម្ចាស់ហ៊ុនម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួនដែរ លើកលែង តែក្រុមហ៊ុនមានម្ចាស់ហ៊ុនតែ ២ រូប ។ ទោះបីក្នុងករណីណាក៏ដោយម្ចាស់ហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនតតិយជនណាម្នាក់ធ្វើជាតំណាងរបស់ខ្លួនដោយមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ ។

៥-៣.៨ ៖

កំណត់ហេតុទាំងឡាយ ត្រូវរៀបរៀងលើបញ្ជីមួយមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេប ឬក៏លើសន្លឹកក្រដាសមានចុះលើទំព័រ និងចុះហត្ថលេខាសង្ខេបស្របទៅតាមច្បាប់ ។ សេចក្តីចំលង ឬសម្រង់នៃកំណត់ហេតុទាំងនេះមានតម្លៃប្រើប្រាស់បានលុះណាតែមានចុះហត្ថលេខា បញ្ជាក់ថាត្រឹមត្រូវអំពីប្រធានក្រុមប្រឹក្សាភិបាល ។

## ៥-៤ ៖ កិច្ចសន្យារវាងក្រុមហ៊ុនជាមួយម្ចាស់ហ៊ុន ឬជាមួយអភិបាល

កិច្ចសន្យាទាំងឡាយ ដែលធ្វើឡើងរវាងក្រុមហ៊ុនជាមួយម្ចាស់ហ៊ុន ឬជាមួយអភិបាល ត្រូវតែដាក់ស្នើសុំសេចក្តីសម្រេចអំពីសន្និបាតនៃម្ចាស់ហ៊ុន ។

ត្រូវតែដាក់ស្នើសុំសេចក្តីសម្រេចអំពីសន្និបាតនៃម្ចាស់ហ៊ុនដែរ ចំពោះកិច្ចសន្យាទាំងឡាយ ដែលធ្វើឡើងរវាងក្រុមហ៊ុននេះជាមួយនឹងក្រុមហ៊ុនមួយដទៃទៀត ដែលមានម្ចាស់ហ៊ុន ឬអភិបាលជាម្ចាស់ហ៊ុន ឬអភិបាលនៃក្រុមហ៊ុនដើម ។

## ៥-៥ ៖ សិទ្ធិទាក់ទងព័ត៌មានរបស់ម្ចាស់ហ៊ុន

នៅក្នុងពេលពិគ្រោះយោបល់របស់ម្ចាស់ហ៊ុនទាំងឡាយ ទោះបីតាមលិខិតក្តី ឬតាមមហាសន្និបាតក្តី ម្ចាស់ហ៊ុនម្នាក់ៗមានសិទ្ធិទាក់ទងឯកសារនិងព័ត៌មានចាំបាច់ ដើម្បីគេអាចថ្លែងគំនិតបានដោយត្រឹមត្រូវ និងប្រកាន់យកសេចក្តីវិនិច្ឆ័យណាមួយលើការចាត់ចែងក្រុមហ៊ុន ។

ម្យ៉ាងទៀត នៅរាល់ពេលណាក៏ដោយ ម្ចាស់ហ៊ុនមានសិទ្ធិស្នើសុំឱ្យក្រុមហ៊ុនចេញសេចក្តីចម្លងនៃលក្ខន្តិកៈដែលមានបញ្ជាក់ការចម្លងត្រឹមត្រូវ មានតម្លៃប្រើប្រាស់តាមច្បាប់ជាធរមាន ។

## ៥-៦ ៖ សវនករ

ម្ចាស់ហ៊ុនទាំងអស់ អាចតែងតាំងដោយសេចក្តីសម្រេចមហាសន្និបាតម្ចាស់ហ៊ុន នូវសវនករមួយរូប ឬច្រើនរូបដោយអនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់ ។

អណត្តិនៃសវនករមានរយៈពេលកំណត់ចំនួន ៣ឆ្នាំ ។ សវនករត្រូវបានទទួលប្រាក់រង្វាន់ស្របទៅតាមច្បាប់ ។

## ៥-៧ ៖ គណនីចរន្ត

ដោយមានការព្រមព្រៀងគ្នាជាមួយអភិបាល ម្ចាស់ហ៊ុនម្នាក់ៗអាចបង្វិលឬដាក់ជាគណនីចរន្តចូលទៅក្នុងបេឡាក្រុមហ៊ុននូវប្រាក់មួយចំនួនដែលចាំបាច់ដល់តម្រូវការប្រើប្រាស់របស់ក្រុមហ៊ុន ។

ចំណូលប្រាក់ទាំងនេះអាចផ្តល់ការប្រាក់ ឬអាចជាប្រាក់គ្មានការ នឹងអាចត្រូវបានប្រើប្រាស់ក្នុងលក្ខខណ្ឌ ដែលអភិបាលកំណត់ ។

ការប្រាក់ដែលផ្តល់ឱ្យ ត្រូវចុះបញ្ចូលទៅក្នុងសោហ៊ុយចំណាយទូទៅ និងអាចត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ។

គណនីចរន្តទាំងឡាយមិនត្រូវបានចាត់ទុកជាកូនបំណុលឡើយ ។ ក្រុមហ៊ុនមានអំណាចសងវិញទាំងស្រុង ឬសងវិញជាផ្នែកៗក្រោយពីបានជូនដំណឹងជាលាយលក្ខអក្សរមួយខែមុន ។ ការសងនេះ ជាដំបូងត្រូវសងជូនទៅគណនីចរន្តណាដែលមានទឹកប្រាក់ខ្ពស់ជាងគេ ។ ក្នុងករណីគណនីចរន្តទាំងនោះមានទឹកប្រាក់ស្មើគ្នា ការសងត្រូវសងទៅតាមសមាមាត្រដូចគ្នាលើគណនីនីមួយៗ ។

ម្ចាស់ហ៊ុនណា ដែលចង់ដកយកវិញនូវប្រាក់ដែលខ្លួនបានដាក់ ត្រូវជូនដំណឹងចំពោះអភិបាលក្នុងរយៈពេល ៣ខែជាមុន ។

# ប្រការ ៦

## ភាគហ៊ុននៃក្រុមហ៊ុន អនុប្បទាន និងការផ្ទេរភាគហ៊ុន

## ៦-១ ៖ ភាគហ៊ុននៃក្រុមហ៊ុន

### ៦-១.១ ៖ សិទ្ធិ និងភារកិច្ចនៃភាគហ៊ុន

រាល់ភាគហ៊ុនមិនអាចត្រូវតំណាងដោយប័ណ្ណលក់ដូរសេរីលើផ្សារហ៊ុនបានឡើយ ។

ភាគហ៊ុននីមួយៗផ្តល់ជូនកម្មសិទ្ធិករនូវសិទ្ធិស្មើគ្នាក្នុងប្រាក់ចំណេញ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន ។

ភាគហ៊ុនមួយផ្តល់នូវអំណាចមានសំឡេងមួយនៅក្នុងការបោះឆ្នោត និងនៅក្នុងសេចក្តីសម្រេចចិត្តទាំងឡាយរបស់ក្រុមហ៊ុន ។

ម្ចាស់ហ៊ុនទាំងឡាយទទួលខុសត្រូវ និងរ៉ាប់រងចំពោះបំណុល និងការខាតបង់របស់ក្រុមហ៊ុនត្រឹមតែចំនួនទឹកប្រាក់នៃភាគទុនផ្ទាល់របស់ខ្លួន ដែលមានដាក់មកក្នុងក្រុមហ៊ុន ។ លើសពីនេះ រាល់ការអំពាវនាវមូលនិធិអំពីសាធារណជនត្រូវបានហាមឃាត់ ។

ការកាន់កាប់កម្មសិទ្ធិលើភាគហ៊ុនមួយ ផ្តល់នូវសិទ្ធិអំណាចពេញលេញក្នុងការចូលរួមជាម្ចាស់ហ៊ុនក្នុងលក្ខន្តិកៈក្រុមហ៊ុន និងសិទ្ធិអំណាចចូលរួមក្នុងមហាសន្និបាតទាំងឡាយនៃក្រុមហ៊ុន ។

ទោះបីនៅក្នុងដៃជនណាក៏ដោយ រាល់សិទ្ធិអំណាច និងភារកិច្ចរបស់ភាគហ៊ុនត្រូវរក្សាទុកដដែល ។ អ្នកតំណាង ប្រតិសិទ្ធិ ទាយាទ និងម្ចាស់បំណុលផ្ទាល់ខ្លួនរបស់ម្ចាស់ហ៊ុនម្នាក់ៗ ទោះបីក្នុងលេសណាមួយក៏ដោយ មិនមានសិទ្ធិបង្ខំបិទទ្វារក្រុមហ៊ុន ឃុំឃាំងទ្រព្យសម្បត្តិ និងឯកសាររបស់ក្រុមហ៊ុន ឬក៏ជ្រៀតជ្រែកតាមបែបណាមួយក្តីចូលទៅក្នុងកិច្ចការគ្រប់គ្រងក្រុមហ៊ុនឡើយ ។

អ្នកទាំងនេះ នៅក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន ត្រូវគោរពទៅតាមសេចក្តីសម្រេចនៃការជម្រះបញ្ជីសារពើភណ្ឌ និងសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងអស់ ។

### ៦-១.២ ៖ អវិភាគីយភាពនៃភាគហ៊ុន

ភាគហ៊ុននីមួយៗមិនអាចចែកបានចំពោះក្រុមហ៊ុន ។ កម្មសិទ្ធិករអវិភាគទាំងឡាយ (ដែលទទួលកម្មសិទ្ធិទាំងមូល) ត្រូវតែងតាំងអណត្តិគាហករូបមួយរូប ដែលជ្រើសរើសយកពីក្នុងចំណោមខ្លួនទាំងឡាយ ឬអ្នក

ដទៃពីនេះ ដើម្បីធ្វើជាតំណាងនៅអមក្រុមហ៊ុន ។ បើគ្មានការព្រមព្រៀងគ្នាទេ កម្មសិទ្ធិករអវិភាគដែលរវៀសវៃជាងគេ ត្រូវស្នើសុំទៅប្រធានតុលាការមានសមត្ថកិច្ចឱ្យតែងតាំងអាណត្តិគាហកនេះ ។

## ៦-២ ៖ អនុប្បទាន និងការផ្ទេរភាគហ៊ុន

៦-២.១ ៖

រាល់ម្ចាស់ហ៊ុន អាចធ្វើអនុប្បទានភាគហ៊ុនរបស់ខ្លួនមួយផ្នែក ឬទាំងស្រុង និងគ្រប់ពេលវេលាជូនទៅម្ចាស់ហ៊ុនដូចគ្នា ឬជូនទៅតតិយជនជាសមាជិកគ្រួសារ បុគ្គលដទៃ ឬក្រុមមនុស្សផ្សេងទៀត ដែលមានផលប្រយោជន៍គ្រួសារ ឬអាជីវកម្មរួមគ្នា ។

រាល់អនុប្បទានភាគហ៊ុនត្រូវតែធ្វើឡើងជាលាយលក្ខអក្សរ ជាលិខិតរវាងឯកជនឬជាលិខិតសារការី ។ ដើម្បីមានប្រសិទ្ធិភាពជាមួយក្រុមហ៊ុន ឬជាមួយតតិយជន លិខិតនេះត្រូវមានការបញ្ជាក់ទទួលស្គាល់របស់ក្រុមហ៊ុន ហើយតម្កល់ទុកមួយច្បាប់ដើមនៅទីស្នាក់ការក្រុមហ៊ុន និងនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ព្រមទាំងចុះផ្សាយក្នុងសារព័ត៌មានណាមួយ ។

**៦-២.២ ៖**

ការធ្វើអនុប្បទានភាគហ៊ុន អាចប្រព្រឹត្តដោយសេរីរវាងម្ចាស់ហ៊ុននិងម្ចាស់ហ៊ុនដូចគ្នា ។

ការធ្វើអនុប្បទាននេះក៏អាចប្រព្រឹត្តដោយសេរីដែររវាងម្ចាស់ហ៊ុនម្នាក់និងសហព័ទ្ធ បុព្វជន កូនចៅទោះបីជាអនុប្បទានិកទាំងនេះមិនមែនជាម្ចាស់ហ៊ុនក៏ដោយ ។

**៦-២.៣ ៖**

ការធ្វើអនុប្បទានភាគហ៊ុនដោយគិតថ្លៃក្ដី ឬឥតគិតថ្លៃក្ដី ជូនទៅតតិយជនដែលមិនមែនជាម្ចាស់ហ៊ុន ឬជូនទៅអ្នកដទៃក្រៅពីសហព័ទ្ធ បុព្វជន កូនចៅ អាចប្រព្រឹត្តទៅបានដោយសេចក្ដីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុនតំណាងឱ្យសំឡេងជាឯកច្ឆន្ទ(១០០%)នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ។

បំណងធ្វើអនុប្បទានភាគហ៊ុន ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅក្រុមហ៊ុន និងផ្ញើជាលិខិតអនុសិដ្ឋជូនទៅម្ចាស់ហ៊ុនដទៃទៀត ដែលមានបញ្ជាក់ការបានទទួល ។

បើក្រុមហ៊ុនមិនយល់ព្រមលើការធ្វើអនុប្បទាននេះទេ ក្នុងអំឡុងពេល ៣ខែ នៃការជូនដំណឹងថាមិនយល់ព្រមនេះ ក្រុមហ៊ុនត្រូវធ្វើលិខិតជូនដំណឹងដល់គ្រប់ម្ចាស់ហ៊ុនដទៃទៀត ដើម្បីទិញយកភាគហ៊ុន ដែលចង់ធ្វើអនុប្បទាននេះ ទៅតាមតម្លៃមួយឯកភាពរវាងភាគីទាំងអស់ ។

ក្រុមហ៊ុនអាចសម្រេចក្រោមការព្រមព្រៀងគ្នាជាមួយម្ចាស់ហ៊ុនដែលចង់ធ្វើអនុប្បទាន ធ្វើការបន្ថយនូវដើមទុនក្នុងតម្លៃជាប្រាក់ស្មើនឹងភាគហ៊ុនអនុប្បទាន និងធ្វើការទិញយកវិញនូវភាគហ៊ុនទាំងនោះ តាមតម្លៃកំណត់ក្នុងលក្ខខណ្ឌដូចចែងខាងលើ ។

បើហួសពីរយៈពេល ៣ខែ ក្រុមហ៊ុនមិនបានទិញ ឬមិនបានចាត់ចែងឱ្យម្ចាស់ហ៊ុនណាម្នាក់ ឬតតិយជនណាម្នាក់ឱ្យទិញយកនូវភាគហ៊ុនទាំងនេះទេ ឬមិនបានផ្ដល់ចម្លើយស្ដីអំពីការសម្រេចអំពីករណីធ្វើ អនុប្បទានភាគហ៊ុននេះទេ នោះនឹងចាត់ទុកថាក្រុមហ៊ុនយល់ព្រមលើការធ្វើអនុប្បទាននេះ ហើយសមាជិក ដែលចង់ធ្វើអនុប្បទាន អាចអនុវត្តនូវការធ្វើអនុប្បទានដូចមានចែងពីខាងដើមដោយបញ្ញត្តិ ។

**៦-២.៤ ៖**

ក្នុងករណីមរណភាពនៃម្ចាស់ហ៊ុនម្នាក់ ក្រុមហ៊ុនអាចបន្តដំណើរការជាប្រក្រតី រវាងម្ចាស់ហ៊ុនទាំងឡាយដែលនៅរស់ ជាមួយនឹងសិទ្ធិវន្តឬទាយាទនៃម្ចាស់ហ៊ុនដែលស្លាប់ និងជាយថាហេតុ ជាមួយសហ

ព័ទ្ធនៅរស់ ដោយអ្នកខាងក្រោយទាំងនេះ មិនមែនជាម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន លើកលែងតែមាន លក្ខខណ្ឌណាផ្សេង ដែលតម្រូវឱ្យការព្រមព្រៀងគ្នារវាងអ្នកទាំងឡាយនេះ ត្រូវធ្វើឡើងតាមសេចក្តីសម្រេច របស់មហាសន្និបាតម្ចាស់ហ៊ុន តំណាងឱ្យសំឡេងជាឯកច្ឆន្ទ(១០០%) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

បើមានលក្ខខណ្ឌតម្រូវបែបនេះ ទាយាទ សិទ្ធិវន្ត ឬសហព័ទ្ធ ត្រូវផ្តល់នូវសំណុំលិខិតទាំងឡាយ ដែលបញ្ជាក់នូវលក្ខណៈពិតជាទាយាទ សិទ្ធិវន្ត ឬសហព័ទ្ធរបស់ខ្លួនជូនមកក្រុមហ៊ុនក្នុងរយៈពេល ៣ខែ យ៉ាងយូរគិតពីថ្ងៃមរណភាព ដើម្បីម្ចាស់ហ៊ុនទាំងអស់ពិគ្រោះគ្នា ។ ក្នុងរយៈពេល ៨ថ្ងៃ ចាប់ពីបានទទួលសំណុំលិខិតទាំងនេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវផ្ញើជូនម្ចាស់ហ៊ុននូវលិខិតអនុសិដ្ឋមានបញ្ជាក់ការបានទទួល ដែលក្នុងលិខិតនោះមានរៀបរាប់បង្ហាញនូវលក្ខណៈពិតរបស់ទាយាទ សិទ្ធិវន្ត ឬសហព័ទ្ធនៃម្ចាស់ហ៊ុនស្លាប់ ព្រមទាំងចំនួននៃភាគហ៊ុនរបស់សមាជិកស្លាប់នោះ ។

លិខិតនេះសំណូមពរឱ្យម្ចាស់ហ៊ុនទាំងអស់ផ្តល់នូវចម្លើយព្រមព្រៀងរបស់ខ្លួន ។ ក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយពីបានទទួលលិខិតសំណូមពរនេះ ម្ចាស់ហ៊ុនទាំងអស់ត្រូវតែផ្តល់ចម្លើយយល់ព្រម ឬមិនយល់ព្រម ។ ហួសពី ៣ខែ នេះ ម្ចាស់ហ៊ុនដែលមិនបានឆ្លើយតប នឹងត្រូវចាត់ទុកថាយល់ព្រម ។

# ប្រការ ៧

## ការបែងចែកលទ្ធផល-ការទូទាត់ភាគលាភ

### ៧-១ ៖ ការបែងចែកលទ្ធផល

គណនីនៃលទ្ធផល ដែលសរុបផលទទួលបាន ដកចេញនូវបន្ទុកទាំងឡាយនៃការិយបរិច្ឆេទ បន្ទាប់ពីបានដកចេញនូវការរម្លស់ទុននិងសំវិធានវត្ថុទាំងឡាយ បង្កើតបានជាប្រាក់ចំណេញឬការខាតបង់នៃការិយបរិច្ឆេទ ។

លើប្រាក់ចំណេញនេះ ក្រោយពីបានកាត់ចេញនូវប្រាក់ខាតពីមុន ត្រូវដកយក ៥% សម្រាប់បង្កើតមូលនិធិបម្រុងស្របច្បាប់ ។ ការដកយក ៥% នេះនឹងត្រូវបញ្ឈប់នៅពេលដែលមូលនិធិបម្រុងកើនដល់ចំនួន ១០% នៃដើមទុនក្រុមហ៊ុន ។

ប្រាក់ចំណេញដែលអាចបែងចែកជូនម្ចាស់ហ៊ុនបាន គឺប្រាក់ចំណេញដែលកាត់ចេញនូវប្រាក់ខាត ពីមុន និងដកចេញនូវប្រាក់សម្រាប់មូលនិធិបម្រុងស្របច្បាប់ព្រមទាំងបូកបន្ថែមនូវប្រាក់កម្រៃដែលលើសទុក ពីមុន។

ប្រាក់ចំណេញនេះ ត្រូវបានដាក់ជូនសន្និបាតចាត់ចែង ដែលតាមសំណើរបស់អភិបាល អាចរក្សាទុកជាថ្មីសម្រាប់ឆ្នាំក្រោយ ឬចាត់ចែងដាក់ទៅក្នុងមូលនិធិបម្រុងទូទៅឬពិសេស ឬចាត់ចែងបែងចែកជូន ម្ចាស់ហ៊ុនទាំងឡាយទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។ ម្យ៉ាងទៀត មហាសន្និបាតអាចសម្រេច ធ្វើការបែងចែកនូវប្រាក់បម្រុងដែលអាចចាត់ចែងបាន ហើយសេចក្តីសម្រេចនេះ ត្រូវបញ្ជាក់ច្បាស់លាស់ នូវប្រភេទនៃមូលនិធិបម្រុង ដែលត្រូវបានកាត់ដកយកប្រាក់បម្រុងមកបែងចែកនេះ ។ ក៏ប៉ុន្តែភាគលាភ ត្រូវកាត់យកជាអាទិភាពអំពីប្រាក់ចំណេញ ដែលអាចបែងចែកបាននៃការិយបរិច្ឆេទ ។

### ៧-២ ៖ ការទូទាត់ភាគលាភ

ក្រោយពីបានយល់ព្រមលើគណនី និងពិនិត្យឃើញថាមានចំនួនប្រាក់គ្រប់គ្រាន់សម្រាប់ធ្វើការបែងចែកនោះ គេត្រូវធ្វើការចាត់ចែងបែងចែកនិងទូទាត់ភាគលាភ ។ ទម្រង់បែបបទនៃការបែងចែកត្រូវកំណត់ដោយសន្និបាតនៃសមាជិកហ៊ុន ឬបើពុំនោះទេ ដោយអភិបាលនៃក្រុមហ៊ុន ។ ការទូទាត់ភាគលាភត្រូវតែធ្វើឡើងនៅក្នុងរយៈពេលយឺតបំផុត ៩ខែ គិតពីថ្ងៃបិទការិយបរិច្ឆេទ ។ រយៈពេលនេះអាចត្រូវបានពន្យារដោយដីកានៃប្រធានតុលាការមានសមត្ថកិច្ច ដែលសម្រេចតាមការស្នើសុំរបស់អភិបាល ។

**ការខាតបង់ ៖**

ការខាតបង់ ដែលពិនិត្យឃើញនៅក្នុងបញ្ជីគណនេយ្យ នឹងត្រូវបែងចែកសងទៅតាមសមាមាត្រនៃភាគហ៊ុនដែលម្ចាស់ហ៊ុនម្នាក់ៗមាន ។ សល់ពីនោះ នឹងត្រូវសងរម្លស់ដោយកាត់យកពីប្រាក់ចំណេញនៃឆ្នាំបន្តបន្ទាប់ ។

# ប្រការ ៨

## ឆ្នាំការិយបរិច្ឆេទនៃក្រុមហ៊ុន-បញ្ជីសារពើភណ្ឌ

ឆ្នាំការិយបរិច្ឆេទ ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ លើកលែងតែឆ្នាំការិយបរិច្ឆេទដំបូង ដែលត្រូវចាប់ផ្តើមពីថ្ងៃចុះបញ្ជីពាណិជ្ជកម្ម និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំបង្កើតក្រុមហ៊ុន ។

នៅពេលបិទការិយបរិច្ឆេទនីមួយៗ អភិបាលត្រូវធ្វើបញ្ជីសារពើភណ្ឌអំពីទ្រព្យសកម្មនិងបំណុលរបស់ក្រុមហ៊ុន បញ្ជីតុល្យការរៀបរាប់លម្អិតនូវទ្រព្យសកម្មនិងបំណុល គណនីនៃលទ្ធផលសរុប ផលទទួលបាន និងបន្ទុកទាំងឡាយ ឧបសម្ព័ន្ធភ្ជាប់ជាមួយ ព្រមទាំងអធិប្បាយនូវព័ត៌មានក្នុងបញ្ជីតុល្យការនិងគណនីនៃ លទ្ធផល ។

ទោះបីគ្មានចំណេញ ឬមានប្រាក់ចំណេញមិនគ្រប់គ្រាន់ក៏ដោយ អភិបាលត្រូវចាត់ចែងធ្វើការរំលោះទុននិងសំវិធានវត្ថុចាំបាច់ ។

អភិបាលត្រូវធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រងដែលទាក់ទងដល់ការិយបរិច្ឆេទកន្លងមក ។

របាយការណ៍ស្តីពីការគ្រប់គ្រងក្រុមហ៊ុន បញ្ជីតុល្យការ គណនីនៃលទ្ធផល និងឧបសម្ព័ន្ធពង្រាងអត្ថបទនៃសេចក្តីសម្រេចសម្រាប់ដាក់ស្នើសុំយោបល់ និងជាយថាហេតុ របាយការណ៍នៃស្នងការគណនី ត្រូវតែបានផ្ញើជូនទៅម្ចាស់ហ៊ុនទាំងឡាយយ៉ាងតិច ២០ថ្ងៃ មុននឹងបើកសន្និបាត ដែលកោះប្រជុំដើម្បីពិនិត្យសម្រេចលើគណនីទាំងនេះ ។

ចាប់ពីថ្ងៃដែលបានទទួលព័ត៌មានទាំងនេះ ម្ចាស់ហ៊ុនម្នាក់ៗមានសិទ្ធិចោទសំណួរជាលាយលក្ខអក្សរដែលអភិបាលមានកាតព្វកិច្ចនឹងឆ្លើយបកស្រាយនៅក្នុងសន្និបាត ។

នៅក្នុងអំឡុងពេល ២០ថ្ងៃ មុនសន្និបាត បញ្ជីសារពើភណ្ឌត្រូវដាក់នៅទីស្នាក់ការ សម្រាប់ម្ចាស់ហ៊ុនទាំងឡាយដែលចង់ពិនិត្យ ។

ជារួមមក គ្រប់ម្ចាស់ហ៊ុនមានសិទ្ធិរាល់ពេលក្នុងការយកព័ត៌មានដោយផ្ទាល់ខ្លួន និងនៅទីស្នាក់ការក្រុមហ៊ុន អំពីគណនីប្រចាំឆ្នាំ បញ្ជីសារពើភណ្ឌ របាយការណ៍ទាំងឡាយ ដែលបានដាក់ជូនសន្និបាត ព្រមទាំងកំណត់ហេតុទាំងឡាយនៃសន្និបាត ដែលទាក់ទងទៅនឹងការិយបរិច្ឆេទទាំង ៣ឆ្នាំ កន្លងមក ។

# ប្រការ ៩
# ការរំលាយក្រុមហ៊ុន-ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន-វិវាទ

## ៩-១ ៖ ការខាតបង់លើដើមទុន-ការរំលាយក្រុមហ៊ុនមុនការកំណត់

ក្នុងករណីមានការខាតបង់ ៣/៤ នៃដើមទុនក្រុមហ៊ុន ក្រុមហ៊ុនត្រូវរំលាយចោលបើប្រសិនណាស្ថានការណ៍មិនអាចធ្វើឱ្យមានប្រក្រតីភាពឡើងវិញក្នុងថិរវេលា ១ឆ្នាំ ។

ក្រុមហ៊ុនក៏អាចត្រូវបានរំលាយមុនការកំណត់បាន ដោយសេចក្តីសម្រេចសមូហភាពនៃម្ចាស់ហ៊ុន ទោះបីមិនមានការខាងបង់ដើមទុនដូចខាងលើក៏ដោយ ។

ក្រុមហ៊ុនក៏អាចត្រូវរំលាយបានដែរ តាមផ្លូវតុលាការ ដោយមូលហេតុត្រឹមត្រូវ ។

## ៩-២ ៖ ការរំលាយក្រុមហ៊ុន-ការជម្រះបញ្ជី

នៅពេលផុតថិរវេលានៃក្រុមហ៊ុន ឬក្នុងករណីមានការរំលាយក្រុមហ៊ុនដោយការសម្រេចរបស់មហាសន្និបាតម្ចាស់ភាគហ៊ុន ក្រុមហ៊ុនត្រូវធ្វើការជម្រះបញ្ជី ។

នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន មានអត្ថិភាពសម្រាប់តម្រូវការនៃការជម្រះបញ្ជី រហូតដល់ពេលបិទការជម្រះបញ្ជីនេះ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ។ និទ្ទេស " ក្រុមហ៊ុនស្ថិតក្នុងការជម្រះបញ្ជី " ព្រមទាំងនាមនៃអ្នកជម្រះបញ្ជី ត្រូវតែមានចែងលើរាល់លិខិតស្នាមនិងឯកសារទាំងឡាយដែលផ្សាយចេញពីក្រុមហ៊ុន ។

ការជម្រះបញ្ជីត្រូវធ្វើឡើងដោយអ្នកជម្រះបញ្ជីម្នាក់ឬច្រើននាក់ ដែលតែងតាំងដោយម្ចាស់ហ៊ុនតំណាងឱ្យសំឡេងជាឯកច្ឆន្ទ(១០០%) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។ អ្នកជម្រះបញ្ជីអាចត្រូវបានជ្រើសរើសក្នុងចំណោមម្ចាស់ហ៊ុន ឬយកអ្នកដទៃក្រៅពីនេះ ។

ការជម្រះបញ្ជីត្រូវអនុវត្តន៍ស្របទៅតាមច្បាប់ ។

ផលពិតបានមកពីការជម្រះបញ្ជី ជាដំបូងត្រូវប្រើប្រាស់សម្រាប់សងវិញនូវទឹកប្រាក់ភាគហ៊ុនដែលមិនទាន់បានសង ។ ចំណែកដែលសល់លើសពីនោះ នឹងត្រូវបែងចែកជូនម្ចាស់ហ៊ុនទាំងឡាយ ទៅតាម សមាមាត្រនៃភាគហ៊ុនដែលម្នាក់ៗមាន ។

## ៩-៣ ៖ មរណភាព-ការហាមឃាត់-ធនក្ស័យនៃម្ចាស់ហ៊ុនម្នាក់

មរណភាព អសមត្ថភាព ការហាមឃាត់ ធនក្ស័យ ឬភាពហិនហោចរបស់ម្ចាស់ហ៊ុនណាម្នាក់ ដែលជារូបវន្តបុគ្គល ព្រមទាំងការកែទម្រង់ឡើងវិញ ឬការជម្រះបញ្ជីតាមផ្លូវតុលាការរបស់ម្ចាស់ហ៊ុនមួយ ដែលជានីតិបុគ្គលមិនបណ្តាលឱ្យក្រុមហ៊ុនរលាយឡើយ ។ ក៏ប៉ុន្តែ បើព្រឹត្តិការណ៍ណាមួយក្នុងចំណោមព្រឹត្តិការណ៍ខាងលើបានកើតមានឡើងចំពោះអភិបាល អភិបាលនេះត្រូវបានបញ្ឈប់ពីតំណែងជាអភិបាលភ្លាម ។

## ៩-៤ ៖ ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន

ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុនទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចធ្វើបាន ដោយសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុន តំណាងឱ្យសំឡេងជាឯកច្ឆន្ទ(១០០%) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។ ការផ្លាស់ប្តូរនេះ អាចអនុវត្តបានតែនៅក្រោយពេលដែលក្រុមហ៊ុនសម្រេចបានគុណ្យការនៃការិយបរិច្ឆេទ ២ឆ្នាំ រួចមកហើយ ។ ប្រសិនបើនៅក្នុងគុណ្យការខាងក្រោយដើមទុនជាក់ស្តែងបានកើនរហូតដល់ចំនួនលើសពី ១០០,០០០,០០០ រៀល (មួយរយលានរៀល) ក្រុមហ៊ុនអាចផ្លាស់ប្តូរទ្រង់ទ្រាយទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបាន ដោយសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុនតំណាងឱ្យសំឡេងជាឯកច្ឆន្ទ(១០០%) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

រាល់សេចក្តីសម្រេចផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ត្រូវតែមានធ្វើជាមុននូវរបាយការណ៍លើស្ថានភាពរបស់ក្រុមហ៊ុនទោះបីជាក្រុមហ៊ុនមិនទាន់មានសវនករនៅឡើយក៏ដោយ ។

នៅក្រោយរយៈពេល ២ឆ្នាំ បើចំនួនម្ចាស់ហ៊ុនកើនលើសពី ៣០រូប ក្រុមហ៊ុនត្រូវផ្លាស់ប្តូរទ្រង់ទ្រាយទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានដែរ ។

### ៩-៥ ៖ វិវាទ

រាល់បណ្តឹងជំទាស់មុខ ឬវិវាទ ដែលអាចកើតឡើងរវាងម្ចាស់ហ៊ុននិងម្ចាស់ហ៊ុន ឬរវាងម្ចាស់ហ៊ុនជាមួយនិងអភិបាល និងជាមួយបុគ្គលិកក្រុមហ៊ុន នៅក្នុងចិរវេលាក្រុមហ៊ុន ឬនៅក្នុងរយៈពេលជម្រះបញ្ជី ត្រូវធ្វើការដោះស្រាយដោយការសម្រុះសម្រួលគ្នាក្នុងក្រុមហ៊ុន ។

ក្នុងករណីមិនអាចសម្រុះសម្រួលគ្នាបានទេ នឹងត្រូវដាក់ជូនទៅស្ថាប័នផ្សះផ្សាវិវាទពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១០
## អភិបាល- ក្រុមប្រឹក្សាភិបាល - ប្រធានក្រុមប្រឹក្សាភិបាល

### ១០-១ ៖ អភិបាល

ក្រុមហ៊ុនត្រូវបានចាត់ចែង និងគ្រប់គ្រងដោយអភិបាល៣រូប ជារូបវន្តបុគ្គល ដែលជ្រើសតាំងដោយម្ចាស់ហ៊ុនទាំងអស់ ។

អណត្តិរបស់អភិបាលអាចមានរយៈពេលមិនកំណត់ ។

អភិបាលអាចត្រូវបានជ្រើសតាំងឡើងវិញ ក្នុងករណីចាំបាច់និងសមស្រប ។

អភិបាលត្រូវបានជ្រើសតាំងដោយសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងឡាយ ដែលតំណាងឱ្យសំឡេងជាឯកច្ឆន្ទ (១០០%)នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

អភិបាលអាចលាលែងពីតំណែងខ្លួនបាន ក៏ប៉ុន្តែត្រូវតែជូនដំណឹងយ៉ាងតិច ៣ខែ មុនដោយលិខិតអនុសិដ្ឋមានបញ្ជាក់ការបានទទួល ផ្ញើជូនម្ចាស់ហ៊ុនគ្រប់រូប ។

អភិបាលអាចត្រូវបានដកហូតតំណែងបាន ដោយសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងឡាយ ដែលតំណាងឱ្យសំឡេងជាឯកច្ឆន្ទ(១០០%) នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ដែលវត្តមានក្នុងអង្គប្រជុំ ។

អភិបាលអាចទទួលក្នុងលក្ខណៈជារង្វាន់នៃមុខតំណែង នូវប្រាក់បៀវត្ស ដែលកំណត់ជូនដោយសេចក្តីសម្រេចនៃម្ចាស់ហ៊ុនទាំងឡាយ ។

## ១០-២ ៖ ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវរួមប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់ ៣ខែ ។

កូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល គឺវត្តមានដោយផ្ទាល់ ឬអ្នកតំណាងនៃអភិបាលទាំង០៣ ។

នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល សេចក្តីសម្រេចរបស់អង្គប្រជុំ ត្រូវបានអនុលោមទៅតាមការយល់ព្រម របស់អភិបាលទាំងអស់ ដែលមានវត្តមានក្នុងអង្គប្រជុំ ។ កូរ៉ុមរបស់ក្រុមប្រឹក្សាភិបាល គឺវត្តមានដោយផ្ទាល់នៃចំនួនភាគច្រើនរបស់អភិបាលនៅពេលប្រជុំ ។ អភិបាលអាចធ្វើជាអណត្តិគាហកឱ្យ អភិបាលតែមួយរូបនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយមានការអនុញ្ញាតជាលាយលក្ខអក្សរ ។

ប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីចាំបាច់ ១/៣ នៃចំនួនអភិបាលមានសិទ្ធិអាចកោះប្រជុំមហាសន្និបាតរបស់ក្រុមប្រឹក្សាភិបាល ដោយធ្វើលិខិតអញ្ជើញផ្ញើជូនទៅអភិបាលទាំងអស់យ៉ាងហោចណាស់ ២០ថ្ងៃមុនប្រជុំ ។

លិខិតអញ្ជើញចំពោះអភិបាលក្នុងប្រទេសកម្ពុជា ត្រូវផ្ញើតាមប្រៃសណីយ៍ ឬអ្នកនាំសាររបស់ក្រុមហ៊ុន ឬតាមហ្វាក់ ។

លិខិតអញ្ជើញចំពោះអភិបាលក្រៅប្រទេស នឹងផ្ញើរភ្លាមៗ តាមយន្តហោះ ឬតាមទូរសារ (ហ្វាក់) ឬតាមទូរលេខ ។

លិខិតអញ្ជើញនោះ នឹងបញ្ជាក់ពិសេសដោយឡែកអំពីកន្លែង កាលបរិច្ឆេទ និងពេលម៉ោងរបស់កិច្ចប្រជុំនោះ និងរបៀបវារៈដែលត្រូវចរចា ។

រាល់អភិបាលត្រូវតែតម្កល់ទុកនៅឯទីស្នាក់ការក្រុមហ៊ុន នូវអាស័យដ្ឋានជាក់លាក់បច្ចុប្បន្នរបស់ខ្លួន ។

បើពុំដូច្នោះទេអភិបាលនោះមិនអាចប្តឹងតវ៉ាបានឡើយ ប្រសិនបើខ្លួនមិនបានទទួលសេចក្តីជូនដំណឹងពីកិច្ចប្រជុំណាមួយ ។

## ១០-៣ ៖ ការតែងតាំងក្រុមប្រឹក្សាភិបាល

ត្រូវបានតែងតាំងជាអភិបាលនៃក្រុមហ៊ុនសម្រាប់អាណត្តិមានរយៈពេលមិនកំណត់ឆ្នាំចំពោះ ៖

១-កញ្ញា **សេង សុចិន្តា ទរនោថ** យល់ព្រមទទួលមុខងារជាប្រធានក្រុមប្រឹក្សាភិបាល
ទីលំនៅ ៖ លេខ ២០Eo ផ្លូវលេខ ៨៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

២-លោក DUONG THANH LONG យល់ព្រមទទួលមុខងារជាអភិបាល
ទីលំនៅ ៖ PN Techcon Apartments, Phu Nhuan District, Ho Chi Minh City, Vietnam.

៣-លោក NGUYEN QUOC PHONG យល់ព្រមទទួលមុខងារជាអភិបាល
ទីលំនៅ ៖ Cuu Long Apartments, Binh Thanh District, Ho Chi Minh City, Vietnam.

១-កញ្ញា **សេង សុចិន្តា ទរនោថ**

២-លោក DUONG THANH LONG

៣-លោក NGUYEN QUOC PHONG

ប្រកាសថាយល់ព្រមទទួលមុខងារជាអភិបាលដែលបានប្រគល់ជូន និងធានាថាមិនដែលមានជាប់ទោសពៃរ៍ណាមួយដែលហាមឃាត់ដល់ការតែងតាំងនេះឡើយ ។

រាល់អភិបាលដែលបានតែងតាំងនេះ សន្យាថានឹងលះបង់ពេលវេលាចាំបាច់សម្រាប់ធ្វើកិច្ចការរបស់ក្រុមហ៊ុន ស្មោះត្រង់ជាមួយក្រុមហ៊ុន និងធ្វើការងារដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន ។

## ១០-៤ ៖ អំណាចនៃប្រធានក្រុមប្រឹក្សាភិបាល

ដោយមានសម្រេចដោយក្រុមប្រឹក្សាភិបាល នៅក្នុងទំនាក់ទំនងជាមួយតតិយជន ប្រធានក្រុមប្រឹក្សាភិបាល មានសិទ្ធ និងភារៈកិច្ច ដូចតទៅ ៖

(I) ប្រធានក្រុមប្រឹក្សាភិបាលមានសិទ្ធិសម្រេចលើរាល់កិច្ចការប្រចាំថ្ងៃរបស់ក្រុមហ៊ុន

(II) មានអំណាចគ្រប់គ្រាន់ជាតំណាងឱ្យក្រុមហ៊ុន និងធ្វើសកម្មភាពចុះហត្ថលេខាលើរាល់កិច្ចសន្យារបស់ក្រុមហ៊ុន ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះតតិយជន ។

(III) អនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

(IV) អនុវត្តគម្រោងជំនួញ និងគម្រោងវិនិយោគរបស់ក្រុមហ៊ុន

(V) ការប្រើប្រាស់អំណាចក្នុងប្រការណាមួយ ដែលផ្ទុយពីកិច្ចការដែលរៀបរាប់រួចមកហើយនេះ ត្រូវចាត់ ទុកជាមោឃៈនូវហត្ថលេខារបស់អភិបាល ហើយការប្រព្រឹត្តល្មើសនេះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបច្ច័យទាំងឡាយ ដែលមានកើតឡើងដោយសារឥរិយាបថទាំងនោះ និងអាចត្រូវបានដកហូតពីមុខតំណែងចេញពីប្រធានក្រុមប្រឹក្សាភិបាល ។

(VI) ការចុះកិច្ចសន្យារបស់ប្រធានក្រុមប្រឹក្សាភិបាលជាមួយតតិយជន លើកិច្ចការទាំងឡាយដែលស្ថិតនៅក្រៅកម្មវត្ថុអាជីវកម្ម ក៏បណ្តាលឱ្យក្រុមហ៊ុនជាប់កិច្ចសន្យានោះជាមួយតតិយជនដែរ ។

ក្នុងករណីនេះ ក្រុមហ៊ុនក៏អាចប្រកែកមិនទទួលខុសត្រូវរបស់ខ្លួនបានដែរ ដោយភស្តុតាងបញ្ជាក់ថាតតិយជននោះបានដឹងដោយច្បាស់លាស់ថា កិច្ចការដែលខ្លួនបានចុះកិច្ចសន្យានោះ ហួសពីកម្មវត្ថុអាជីវកម្មឬមួយភស្តុតាងបញ្ជាក់ថា តតិយជននោះមិនអាចដោះសារថាខ្លួនមិនបានដឹងដោយកាលៈទេសៈ ។

ក្រុមហ៊ុនមិនអាចយកការចុះផ្សាយសម្រង់លក្ខន្តិកៈក្នុងសារព័ត៌មាន មកធ្វើជាភស្តុតាងគ្រប់គ្រាន់សម្រាប់ជាសំអាង ដើម្បីរួចផុតពីការទទួលខុសត្រូវលើកិច្ចសន្យាដូចបានពោលខាងលើនេះបានទេ ។

ដូច្នេះ នៅពេលកើតវិវាទបែបនេះ ត្រូវតែផ្តល់នូវឯកសារសំអាងនានាដូចជា រួមបញ្ចូលតែមិនកំណត់លិខិតសំអាងជាលាយលក្ខអក្សរ ឬ វត្ថុតាងផ្សេងៗ។

នៅក្នុងទំនាក់ទំនងជាមួយម្ចាស់ហ៊ុនទាំងអស់ ប្រធានក្រុមប្រឹក្សាភិបាលអាចធ្វើរាល់កិច្ចការចាត់ចែងគ្រប់យ៉ាង ដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន ។

ក៏ប៉ុន្តែ កិច្ចការខ្លះដូចមានបញ្ជាក់ខាងក្រោមនេះ ត្រូវតែមានការអនុញ្ញាតដោយសេចក្តីសម្រេចជាឯកច្ឆន្ទនៃម្ចាស់ហ៊ុនទាំងឡាយ គឺការទិញ ការលក់ ការដោះដូរអចលនទ្រព្យឬមូលនិធិពាណិជ្ជកម្ម ការចុះ កិច្ចសន្យាខ្ចីបុលក្នុងនាមក្រុមហ៊ុន ការខ្ចីឥណទានពីធនាគារ ការធ្វើហ៊ីប៉ូតែកលើអសង្ហារឹមភណ្ឌរបស់ ក្រុមហ៊ុន ឬការបញ្ចាំមូលនិធិពាណិជ្ជកម្ម ឬការចូលរួមសហការក្នុងការបង្កើតក្រុមហ៊ុននានា ការកែប្រែលក្ខន្តិកៈ ។

ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាល អាចតែងតាំងអាណត្តិគាហក ម្នាក់ឬច្រើននាក់ ឱ្យទទួលចាត់ចែងនូវកម្មវត្ថុណាមួយ ឬកម្មវត្ថុមួយចំនួន ដោយមានការកំណត់ជាក់លាក់ជា ជំនួសខ្លួន និងក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ ។

## ប្រការ ១១

## នីតិបុគ្គលិកលក្ខណៈ-ការចុះបញ្ជីពាណិជ្ជកម្ម-ការចុះផ្សាយ-សោហ៊ុយ

**១១-១ ៖**

ក្រុមហ៊ុនមាននីតិបុគ្គលិកលក្ខណៈពេញលេញ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីពាណិជ្ជកម្ម ។ ដើម្បី ទទួលបានការចុះបញ្ជីពាណិជ្ជកម្មនេះ ស្ថាបនិក ឬអភិបាល ឬអាណត្តិគាហក ដែលមានសមត្ថភាពតាមផ្លូវ ច្បាប់ ត្រូវចុះឈ្មោះ និងតម្កល់ទុកលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មតាមការបញ្ញត្តិនៃច្បាប់ ។

**១១-២ ៖**

រាល់សិទ្ធិពេញលេញ ត្រូវបានប្រគល់ជូនស្ថាបនិក ឬអភិបាល ឬអាណត្តិគាហក ដែលមានសមត្ថភាព តាមផ្លូវច្បាប់ ដើម្បីបំពេញទម្រង់ការនៃការផ្សព្វផ្សាយដែលច្បាប់បានបញ្ញត្តិ និងជាពិសេសដើម្បីចុះហត្ថលេខា លើសេចក្តីប្រកាសចុះផ្សាយក្នុងសារព័ត៌មាន ។

**១១-៣ ៖**

រាល់សោហ៊ុយចំណាយ ពន្ធអាករផ្សេងៗ និងកម្រៃនានា ដែលកើតមានមុនពេលក្រុមហ៊ុនចុះបញ្ជី ពាណិជ្ជកម្ម ត្រូវជាបន្ទុករបស់ម្ចាស់ហ៊ុនទាំងអស់គ្នា ទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។ ចាប់ពីកាល បរិច្ឆេទនៃការចុះបញ្ជីនេះរាល់សោហ៊ុយចំណាយទាំងអស់នេះ នឹងត្រូវទទួលបន្ទុកដោយក្រុមហ៊ុន ដែលនឹងធ្វើ ការរម្លស់នៅមុនពេលបែងចែកប្រាក់ចំណេញ និងយ៉ាងយូរបំផុតត្រូវរម្លស់ឱ្យអស់នៅក្នុងអំឡុងពេល ៥ឆ្នាំ ។

## មាត្រា ១២

## បទបញ្ញត្តិផ្សេងៗ

រាល់បញ្ហាទាំងឡាយដែលមិនមានចែង ឬមិនគូរអនុវត្តនៅក្នុងលក្ខន្តិកៈនេះ នឹងត្រូវបានដាក់អោយ អនុវត្តដោយកិច្ចព្រមព្រៀងនៃកិច្ចសន្យា ឬតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

លក្ខន្តិកៈនេះ នឹងត្រូវបានកែប្រែ ដោយសេចក្តីសម្រេចរបស់កិច្ចប្រជុំទូទៅរបស់សមាជិកហ៊ុន

លក្ខន្តិកៈនេះ ត្រូវមានអានុភាពអនុវត្តពីថ្ងៃចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន។ លក្ខន្តិកៈត្រូវចុះហត្ថ លេខាទាំងភាសាខ្មែរ និងភាសាអង់គ្លេស។

ធ្វើជា ៤ ច្បាប់ដើម ថ្ងៃទី ២៤ ខែ 06 ឆ្នាំ ២០១៥

**បានអាន និង យល់ព្រម**
**ទទួលមុខងារជាអភិបាល**

DUONG THANH LONG

**បានអាន និង យល់ព្រម**
**ទទួលមុខងារជាប្រធានក្រុមប្រឹក្សាភិបាល**

**សេង សុចិន្តា ខរនាថ**

**បានអាន និង យល់ព្រម**

**សេង សុចិន្តា**

**បានអាន និង យល់ព្រម**
**ទទួលមុខងារជាអភិបាល**

NGUYEN QUOC PHONG

ក្រសួងពាណិជ្ជកម្ម
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
ចំណុះបញ្ជីលេខ: 3091/2015 ពណ.ចបព
ថ្ងៃទី 24-06-2015 ម៉ោង 15h00
មន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

# លក្ខន្តិកៈក្រុមហ៊ុន

# MEMORANDUM AND ARTICLES OF ASSOCIATION

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត - ដើមទុន : ៤០,០០០,០០០ រៀល

(=10,000 USD; អត្រា4,000 រៀល/$)

# លក្ខន្តិកៈ

# ក្រុមហ៊ុន

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត - ដើមទុន : ៤០,០០០,០០០ រៀល
(=10,000 USD; អត្រា 4,000 រៀល/$)

អ្នកដែលមានកាយឈ្មោះដូចខាងក្រោម :

១- លោក

ពាណិជ្ជករ សញ្ជាតិខ្មែរ
ទីលំនៅ : លេខ ២៣ ផ្លូវលេខ ៤៤៦ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
អត្តសញ្ញាណប័ណ្ណលេខ :010497239 ចុះថ្ងៃទី 20-06-2005

២- លោកស្រី

ពាណិជ្ជករ សញ្ជាតិខ្មែរ
ទីលំនៅ : លេខ ២៣ ផ្លូវលេខ ៤៤៦ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ
អត្តសញ្ញាណប័ណ្ណលេខ :N0759880 ចុះថ្ងៃទី 01-02-2010

បានរៀបចំលក្ខន្តិកៈនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយទៅតាមការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត និងតាមលក្ខខណ្ឌដូចតទៅ :

## ប្រការទី ១
## នាមករណ៍-ទ្រង់ទ្រាយ

### ១-១ : នាមករណ៍

ក្រុមហ៊ុនមាននាមថា :

ក្រុមហ៊ុនមានត្រាសំគាល់សំរាប់ក្រុមហ៊ុនប្រើប្រាស់ដែលមាននាមករណ៍របស់ក្រុមហ៊ុននៅក្នុងផ្ទៃត្រា ។

នៅក្នុងរាល់លិខិតស្នាម វិក័យប័ត្រ ឯកសារផ្សព្វផ្សាយ និងឯកសារផ្សេងៗទៀតគ្រប់ប្រភេទ ដែលផ្សាយចេញពីក្រុមហ៊ុន ត្រូវតែមានចែងពីក្រោយ ឬ ពីក្រោមនាមករណ៍ នូវអក្សរច្បាស់ និងគ្រប់ពាក្យថា :" ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត S.A.R.L ឬ (LTD) " ព្រមទាំងចែងនូវចំនួនដើមទុនចុះបញ្ជីក្រុមហ៊ុនផង ។

### ១-២ : ទ្រង់ទ្រាយ

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមួយត្រូវបានបង្កើតឡើងដែលក្នុងនោះមានម្ចាស់ហ៊ុនដូចមានចែងនៅប្រការខាងក្រោយ និងអាចមានបន្ថែមម្ចាស់ហ៊ុននៅពេលក្រោយទៀត ។

ចាប់ពីថ្ងៃបានចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិច្បាប់ ក្រុមហ៊ុននេះមាននីតិបុគ្គលិកលក្ខណៈផ្ទាល់ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងក្រោមការកំណត់នៃប្រការទាំងឡាយ ដែលចែងក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

## ប្រការទី ២
## កម្មវត្ថុអាជីវកម្ម

ក្រុមហ៊ុនមានកម្មវត្ថុអាជីវកម្មនៅកម្ពុជា និងនៅប្រទេសដទៃដោយចំពោះ ឬ មិនចំពោះដូចតទៅ :

- ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណៈ អាហរណទំនិញគ្រប់ប្រភេទ - នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
- ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
- ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
- មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
- បើកសាលារៀន
- ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
- សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
- សេវាផ្សាយពាណិជ្ជកម្ម
- បោះពុម្ពផ្សាយ
- ផលិតខ្សែភាពយន្ត វីដេអូ CD
- ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និង ចែកចាយទំនិញ
- សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
- សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
- ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
- វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
- វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

-ការចូលរួមតាមគ្រប់មធ្យោបាយរបស់ក្រុមហ៊ុនជាមួយរាល់សហគ្រាស ឬក្រុមហ៊ុនដទៃដែលមានហើយ ឬដែលនឹងបង្កើត និងដែលមានជាប់ទាក់ទងដោយចំពោះ ឬមិនចំពោះដល់កម្មវត្ថុអាជីវកម្ម ពិសេសតាមវិធីបង្កើតក្រុមហ៊ុនថ្មី ភាគទុនការចុះឈ្មោះ ឬទិញសិទ្ធិសមាជិក ការរំលាយបញ្ចូលគ្នា សម្ព័ន្ធភាព ឬការចូលរួមសហប្រតិបត្តិការនានា ។

ជាទូទៅ ក្រុមហ៊ុនធ្វើរាល់ប្រតិបត្តិការពាណិជ្ជកម្ម ដែលជាប់ទាក់ទងដោយចំពោះ ឬមិនចំពោះជាមួយកម្មវត្ថុខាងលើ ឬកម្មវត្ថុប្រហាក់ប្រហែលគ្នា ឬប្រទាក់គ្នា ឬដែលមានចរិតសំដៅអនុគ្រោះដល់កិច្ចអភិវឌ្ឍន៍រាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ។

## ប្រការទី ៣
## ទីស្នាក់ការ

ទីស្នាក់ការក្រុមហ៊ុនតាំងនៅ : លេខ ២១៣ មហាវិថីព្រះមុនីវង្ស សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ទីស្នាក់ការនេះនឹង អាចត្រូវបានផ្ទេរទៅនៅកន្លែងផ្សេងទៀតក្នុងក្រុងដដែល អាស្រ័យដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល និងផ្ទេរទៅទីកន្លែងផ្សេងទៀតក្រៅពីរាជធានីភ្នំពេញ អាស្រ័យដោយសេចក្តីសំរេចមហាសន្និបាតម្ចាស់ហ៊ុន ។

តាមសេចក្តីសំរេចនៃមហាសន្និបាតម្ចាស់ហ៊ុន ព្រមទាំងអនុលោមទៅតាមច្បាប់ជាធរមាន ក្រុមហ៊ុនអាចមានសាខាមួយ ឬច្រើនកន្លែងរបស់ក្រុមហ៊ុន នៅតាមបណ្តាខេត្តនានា ឬនៅបរទេស ។

## ប្រការទី ៤
## ថេរវេលា

ថេរវេលាសកម្មភាពរបស់ក្រុមហ៊ុនមានចំនួន៩៩ឆ្នាំ ដែលត្រូវផ្តើមគិតចាប់ពីថ្ងៃបានចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម លើកលែងតែមានករណីរំលាយក្រុមហ៊ុនមុនកាលកំណត់ ឬការពន្យាពេលបន្ត ។ ថេរវេលានេះ អាចត្រូវបានរំលាយមុនពេលកំណត់ ឬអាចត្រូវបានពន្យាពេលបន្ត ។

យ៉ាងតិចណាស់មួយឆ្នាំមុនការផុតកំណត់នៃថេរវេលា ៩៩ឆ្នាំ នេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំអោយមានការប្រជុំមហាសន្និបាតនៃម្ចាស់ហ៊ុន ដើម្បីសំរេចទៅតាមលក្ខខណ្ឌទាំងឡាយនៃកូរ៉ុម និងភាគច្រើនដែលតំរូវចាំបាច់សំរាប់កែប្រែលក្ខន្តិកៈថាតើក្រុមហ៊ុនត្រូវរំលាយ ឬត្រូវពន្យាពេលបន្ត ។ បើប្រធានក្រុមប្រឹក្សាភិបាលមិនបានកោះប្រជុំធ្វើសេចក្តីសំរេចនេះទេ សម្លេង ១ / ៣ នៃអំណាចបោះឆ្នោតម្ចាស់ហ៊ុនទាំងអស់ ក្រោយពេលដែលបានដាក់ពាក្យសុំអោយប្រជុំ តាមរយៈលិខិតអនុសិដ្ឋ ហើយមិនបានទទួលផលតាមសំណូមពរនោះ អាចស្នើសុំទៅប្រធានតុលាការមានសមត្ថកិច្ច តែងតាំងអាណត្តិគាហករបស់តុលាការ អោយទទួលបន្ទុករៀបចំការប្រជុំក្នុងនាមម្ចាស់ហ៊ុនទាំងអស់ធ្វើសេចក្តីសំរេចអំពីបញ្ហានេះ ។

## ប្រការទី ៥
## ដើមទុន-ភាគហ៊ុន-ម្ចាស់ហ៊ុន

### ៥-១ : ដើមទុន-ភាគហ៊ុន

ម្ចាស់ហ៊ុនដែលមានរាយនាមដូចខាងក្រោមបានដាក់ភាគទុនជាសាច់ប្រាក់ដូចតទៅ :

១- លោក ចំនួន 20,000,000 រៀល

២- លោកស្រី ចំនួន 20,000,000 រៀល

សរុបភាគទុនទាំងអស់ចំនួន ៤០,០០០,០០០ រៀល ( សែសិបលានរៀល)

(=10,000 USD; អត្រា 4,000 រៀល/$)

ភាគទុនសរុបចំនួន ៤០,០០០,០០០ រៀលនេះ ត្រូវបង់ចូលមកក្នុងបេឡាក្រុមហ៊ុនជាសាច់ប្រាក់ទាំងស្រុង និង គ្រប់ចំនួនដោយម្ចាស់ហ៊ុនទៅតាមភាគហ៊ុនផ្ទាល់របស់ខ្លួនម្នាក់ៗ ហើយការបង់បញ្ចូលនេះ ត្រូវបានម្ចាស់ហ៊ុនទាំងអស់គ្នាទទួលស្គាល់ថាពិតជាបង់គ្រប់ចំនួនមែន ។

ដើមទុនចុះបញ្ជីក្រុមហ៊ុនត្រូវបានកំណត់ចំនួន ៤០,០០០,០០០ រៀល ( សែសិបលានរៀល ) ស្មើនឹងចំនួនទឹកប្រាក់សរុបដែលបានបង់ខាងលើ ។ ដើមទុននេះត្រូវបានបែងចែកជាចំនួន ១,០០០ ហ៊ុន ដែលនៅក្នុងនោះ ភាគហ៊ុននិមួយៗមានតំលៃ ៤០,០០០ រៀល ។

ភាគហ៊ុនទាំងឡាយខាងលើនេះ ត្រូវតែបង់បញ្ចូលក្នុងក្រុមហ៊ុនទាំងស្រុងនិងគ្រប់ចំនួន ហើយត្រូវបានបែងចែក និង ចុះលេខជូនម្ចាស់ហ៊ុនម្នាក់ៗ ទៅតាមសមាមាត្រនៃភាគទុនរៀងៗខ្លួនគឺ :

១- លោក មានចំនួន 500 ភាគហ៊ុន ពីលេខ 0001 ដល់លេខ 0500

២- លោកស្រី មានចំនួន 500 ភាគហ៊ុន ពីលេខ 0501 ដល់លេខ 1000

សរុបចំនួនភាគហ៊ុនមាន ១,០០០ ភាគហ៊ុន ស្មើនឹងដើមទុនក្រុមហ៊ុនចំនួន ៤០,០០០,០០០ រៀល

( ជាអក្សរ : ចំនួនមួយពាន់ភាគហ៊ុន ស្មើនឹងដើមទុន សែសិបលានរៀល)

រាល់ម្ចាស់ហ៊ុនប្រកាសថា ភាគហ៊ុនចំនួន ១,០០០ ភាគហ៊ុន ដែលបានបង្កើតឡើង និងបែងចែកតាមសមាមាត្រដូចខាងលើ គឺបានទទួលការយល់ព្រមរវាងគ្នានិងគ្នា ព្រមទាំងបានត្រូវបង់បញ្ចូលគ្រប់ចំនួនមកក្នុងក្រុមហ៊ុន ។ គ្រប់ភាគហ៊ុនត្រូវបានចុះបញ្ជីទៅតាមចំណែកនៃម្ចាស់ហ៊ុន ។

អាចទទួលសិទ្ធិជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន តែល្គឹកណាដែលមានកម្មសិទ្ធិភាគហ៊ុនដែលបានបែងចែកជូន។ ក្នុងករណីចង់ធ្វើអនុប្បទានភាគហ៊ុន ត្រូវតែមានការព្រមព្រៀងរវាងម្ចាស់ហ៊ុនទៅតាមលក្ខខណ្ឌដែលមាននៅក្នុងប្រការទី ៦ ចំណុច ៦-២ នៃលក្ខន្តិកៈនេះ ។

## ៥-២ : ការបង្កើនដើមទុន-ការបន្ថយដើមទុន

### ការបង្កើនដើមទុន

ដើមទុនអាចត្រូវបានបង្កើនតាមគ្រប់វិធីដែលច្បាប់អនុញ្ញាត ព្រមទាំងអោយស្របទៅតាមសេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុន :

- បង្កើតបន្ថែមនូវភាគហ៊ុនថ្មីៗ ជាសាច់ប្រាក់ ឬជាវត្ថុ
- បង្វិលបញ្ចូលមួយភាគ ឬទាំងស្រុងនៃមូលនិធិបំរុងមកក្នុងដើមទុន
- ដំឡើងតំលៃនៃភាគហ៊ុននិមួយៗ ដែលមានរួចហើយ
- តាមគ្រប់វិធីដទៃទៀតដែលច្បាប់អនុញ្ញាត ។

ក្នុងករណីបង្កើនដើមទុន តាមវិធីតំលើងតំលៃនៃភាគហ៊ុនដែលមានរួចហើយ និងដែលត្រូវបង់ចូលមកក្នុងក្រុមហ៊ុនជាសាច់ប្រាក់នោះ ត្រូវតែមានសេចក្តីសំរេចដោយឯកច្ឆ័ន្ទអំពីម្ចាស់ហ៊ុន ។

ការយល់ព្រមទទួលជាអនុប្បទានិក ចំពោះជនដែលត្រូវបញ្ចូលមកក្នុងក្រុមហ៊ុននាឱកាសបង្កើនដើមទុន ស្របទៅតាមប្រការទី ៦ ត្រូវតែធ្វើអោយបានត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌកំណត់ក្នុងប្រការនេះ ។

ក្នុងករណីបង្កើនដើមទុនដោយដាក់បន្ថែមភាគទុនជាវត្ថុ ភាគទុនជាវត្ថុនេះត្រូវតែបានវាយតំលៃដោយស្នងការភាគទុនកាលណាតំលៃភាគទុននេះលើសពី ៤០ % នៃដើមទុន ។ បើតំលៃភាគទុនជាវត្ថុនេះមានតំលៃតិចជាង ៤០ % នៃដើមទុនក្រុមហ៊ុន ការវាយតំលៃភាគទុននេះអាចធ្វើឡើងដោយត្រឹមតែម្ចាស់ហ៊ុនទាំងអស់គ្នា ។

ក្នុងករណីបង្កើនដើមទុនដោយភាគទុនជាសាច់ប្រាក់ រាល់ម្ចាស់ហ៊ុន លើកលែងតែមានការប្រកែកត្រឹមត្រូវ មានសិទ្ធិជ្រើសរើសយកចំនួនភាគទុនថ្មីទៅតាមសមាមាត្រនៃភាគទុនដែលខ្លួនមាន ទៅតាមបែបបទមួយកំណត់ដោយសេចក្តីសំរេចនៃមហាសន្និបាតម្ចាស់ហ៊ុន ។

### ការបន្ថយដើមទុន

ដើមទុនអាចត្រូវបានបន្ថយ អាស្រ័យដោយសេចក្តីសំរេចនៃមហាសន្និបាតម្ចាស់ហ៊ុន ដែលសំរេចទៅតាមល័ក្ខខ័ណ្ឌបញ្ញត្តិនៃច្បាប់ ។ ក៏ប៉ុន្តែការបន្ថយដើមទុន មិនត្រូវអោយប៉ះពាល់ដល់សមភាពនៃម្ចាស់ហ៊ុន ឬក៏មិនត្រូវអោយនៅតិចជាងពាក់កណ្តាលនៃដើមទុនចុះបញ្ជីដំបូង និងទាបជាងដើមទុនកំណត់ដោយច្បាប់ ។ ការបន្ថយដើមទុនត្រូវតែអនុញ្ញាតដោយមហាសន្និបាតម្ចាស់ហ៊ុន ។

## ៥-៣ : មហាសន្និបាតម្ចាស់ហ៊ុន

### ៥-៣.១ :

មហាសន្និបាតម្ចាស់ហ៊ុនត្រូវប្រារព្ធឡើងយ៉ាងហោចណាស់ ១ ឆ្នាំ ម្តងក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល។

### ៥-៣.២ :

មហាសន្និបាតម្ចាស់ហ៊ុនអាចកោះប្រជុំនៅពេលណាក៏បាន ដោយសំលេងភាគច្រើនរបស់ក្រុមប្រឹក្សាភិបាល ឬដោយប្រធានក្រុមប្រឹក្សាភិបាល ឬដោយសំលេងភាគច្រើននៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ឬដោយសវនករ ។

៥-៣.៣ :

សម័យប្រជុំនៃមហាសន្និបាតត្រូវធ្វើឡើងនៅទីស្នាក់ការក្រុមហ៊ុន ឬនៅទីកន្លែងដទៃទៀត ដូចមានបញ្ជាក់ក្នុងលិខិតអញ្ជើញ ។ លិខិតអញ្ជើញត្រូវមានចែងពីកាលបរិច្ឆេទ របៀបវារៈ និងទីកន្លែងនៃមហាសន្និបាត និងផ្ញើជូនម្ចាស់ហ៊ុនទាំងអស់យ៉ាងយូរ ២០ ថ្ងៃមុនថ្ងៃប្រជុំ ។

រាល់ម្ចាស់ហ៊ុនត្រូវតំកល់ទុកនៅក្នុងទីស្នាក់ការក្រុមហ៊ុន នូវអាសយដ្ឋានជាក់លាក់បច្ចុប្បន្នរបស់ខ្លួន ។ បើពុំដូច្នោះទេម្ចាស់ហ៊ុននោះ មិនអាចប្តឹងតវ៉ាបានឡើយ ប្រសិនបើខ្លួនមិនបានទទួលសេចក្តីជូនដំណឹងពីកិច្ចប្រជុំណាមួយ ។

៥-៣.៤ :

កូរ៉ុមនៃមហាសន្និបាតម្ចាស់ហ៊ុន ត្រូវបានកំណត់ចំនួនសំលេងភាគច្រើនលើសពីពាក់កណ្តាលនៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ។

ក្នុងករណីមហាសន្និបាតលើកទី១ មិនបានទទួលកូរ៉ុមគ្រប់គ្រាន់តាមចំនួនកំណត់ខាងលើនេះទេត្រូវកោះប្រជុំមហាសន្និបាតលើកទី២ ក្នុងអំឡុងពេលយ៉ាងហោចណាស់ ២០ ថ្ងៃក្រោយ ។

កូរ៉ុមនៃមហាសន្និបាតលើកទី២ ត្រូវបានកំណត់ចំនួនសំលេងយ៉ាងតិច ១/៣ នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ។

៥-៣.៥ :

សេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុនអាចយកជាការបាន លុះណាតែមានការយល់ព្រមពីម្ចាស់ហ៊ុន ដែលតំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

៥-៣.៦ :

មហាសន្និបាតម្ចាស់ហ៊ុនអាចធ្វើឡើងដោយការធ្វើចំលើយជាលិខិតលាយលក្ខអក្សរជំនួសការមកចូលរួមប្រជុំដោយផ្ទាល់។

ក្នុងករណីនេះ សេចក្តីសំរេចអាចយកជាការបាន លុះណាតែមានការយល់ព្រមជាឯកច្ឆ័ន្ទអំពីម្ចាស់ហ៊ុនទាំងអស់ ។

៥-៣.៧ :

ម្ចាស់ហ៊ុនទាំងអស់មានសិទ្ធិពេញលេញនៅក្នុងការចូលរួមធ្វើសេចក្តីសំរេចចិត្ត ទោះបីគេមានឋានៈណាក៏ដោយ ឬមានភាគហ៊ុនប៉ុន្មានក៏ដោយ ។ គេមានសិទ្ធិផ្តល់សំលេងស្មើនឹងចំនួនភាគហ៊ុនដែលគេមាន ដោយគ្មានការកម្រិតអ្វីឡើយ ។
ម្ចាស់ហ៊ុនម្នាក់អាចចាត់តាំងអោយសហព័ទ្ធខ្លួនចូលរួមជាតំណាងនៅក្នុងសេចក្តីសំរេចនានា ។
ម្ចាស់ហ៊ុនម្នាក់អាចប្រគល់សិទ្ធិជូនម្ចាស់ហ៊ុនម្នាក់ទៀតធ្វើជាតំណាងរបស់ខ្លួនដែរ លើកលែងតែក្រុមហ៊ុនមានម្ចាស់ហ៊ុនតែ២រូប ។
ទោះបីក្នុងករណីណាក៏ដោយម្ចាស់ហ៊ុនម្នាក់អាច ប្រគល់សិទ្ធិជូនតតិយជនណាម្នាក់ធ្វើជាតំណាងរបស់ខ្លួនដោយមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ ។

៥-៣.៨ :

កំណត់ហេតុទាំងឡាយ ត្រូវរៀបរៀងលើបញ្ជីមួយមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេបឬក៏លើសន្លឹកក្រដាសមានចុះលើទំព័រ និងចុះហត្ថលេខាសង្ខេបស្របទៅតាមច្បាប់ ។

សេចក្តីចំលងឬសំរង់នៃកំណត់ហេតុទាំងនេះមានតំលៃប្រើប្រាស់បាន លុះណាតែមានចុះហត្ថលេខាបញ្ជាក់ថាត្រឹមត្រូវអំពីប្រធានក្រុមប្រឹក្សាភិបាល ។

## ៥-៤ : កិច្ចសន្យារវាងក្រុមហ៊ុនជាមួយម្ចាស់ហ៊ុន ឬជាមួយអភិបាល

កិច្ចសន្យាទាំងឡាយដែលធ្វើឡើងរវាងក្រុមហ៊ុនជាមួយម្ចាស់ហ៊ុន ឬជាមួយអភិបាលត្រូវតែដាក់ស្នើសុំសេចក្តីសំរេចអំពីសន្និបាតនៃម្ចាស់ហ៊ុន ។

ត្រូវតែដាក់ស្នើសុំសេចក្តីសំរេចអំពីសន្និបាតនៃម្ចាស់ហ៊ុនដែរ ចំពោះកិច្ចសន្យាទាំងឡាយដែលធ្វើឡើងរវាងក្រុមហ៊ុននេះជាមួយនឹងក្រុមហ៊ុនមួយផ្សេងទៀត ដែលមានម្ចាស់ហ៊ុន ឬអភិបាលជាម្ចាស់ហ៊ុន ឬអភិបាលនៃក្រុមហ៊ុនដើម ។

## ៥-៥ : សិទ្ធិទាក់ទងពត៌មានរបស់ម្ចាស់ហ៊ុន

នៅក្នុងពេលពិគ្រោះយោបល់របស់ម្ចាស់ហ៊ុនទាំងឡាយ ទោះបីតាមលិខិតក្តី ឬតាមមហាសន្និបាតក្តី ម្ចាស់ហ៊ុនម្នាក់ៗមានសិទ្ធិទាក់ទងឯកសារនិងពត៌មានចាំបាច់ ដើម្បីគេអាចថ្លែងគំនិតបានដោយត្រឹមត្រូវ និងប្រកាន់យកសេចក្តីពិស្តារណាមួយលើការចាត់ចែងក្រុមហ៊ុន ។

ម្យ៉ាងទៀត នៅរាល់ពេលណាក៏ដោយ ម្ចាស់ហ៊ុនមានសិទ្ធិស្នើសុំអោយក្រុមហ៊ុនចេញសេចក្តីចំលងនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលមានបញ្ជាក់ការចំលងត្រឹមត្រូវមានតំលៃប្រើប្រាស់តាមច្បាប់ជាធរមាន ។

## ៥-៦ : សវនករ

ម្ចាស់ហ៊ុនទាំងអស់ អាចតែងតាំងដោយសេចក្តីសំរេចមហាសន្និបាតម្ចាស់ហ៊ុន នូវសវនករមួយរូប ឬច្រើនរូបដោយអនុលោមទៅតាមបទបញ្ញត្តិនៃច្បាប់ ។

អាណត្តិនៃសវនករមានរយះពេលកំណត់ចំនួន ៣ ឆ្នាំ ។ សវនករត្រូវបានទទួលប្រាក់រង្វាន់ស្របទៅតាមច្បាប់ ។

## ៥-៧ : គណនីចរន្ត

ដោយមានការព្រមព្រៀងគ្នាជាមួយអភិបាលម្ចាស់ហ៊ុនម្នាក់ៗអាចបង្ផិល ឬដាក់ជាគណនីចរន្តចូលទៅក្នុងបេឡាក្រុមហ៊ុននូវប្រាក់មួយចំនួនដែលចាំបាច់ដល់តំរូវការប្រើប្រាស់របស់ក្រុមហ៊ុន ។

ចំណូលប្រាក់ទាំងនេះអាចផ្តល់ការប្រាក់ ឬអាចជាប្រាក់គ្មានការ និងអាចត្រូវបានប្រើប្រាស់ក្នុងល័ក្ខខ័ណ្ឌដែលអភិបាលកំណត់ ។

ការប្រាក់ដែលផ្តល់អោយ ត្រូវចុះបញ្ចូលទៅក្នុងសោហ៊ុយចំណាយទូទៅ និងអាចត្រូវបានពិនិត្យឡើងវិញ ជារៀងរាល់ឆ្នាំ ។

គណនីចរន្តទាំងឡាយមិនត្រូវបានចាត់ទុកជាកូនបំណុលឡើយ ។ ក្រុមហ៊ុនមានអំណាចសងវិញទាំងស្រុង ឬសងវិញជាផ្នែកៗក្រោយពីបានជូនដំណឹងជាលាយល័ក្ខអក្សរមួយខែមុន ។ ការសងនេះ ជាដំបូងត្រូវសងជូនទៅគណនីចរន្តណាដែលមានទឹកប្រាក់ខ្ពស់ជាងគេ ។ ក្នុងករណីគណនីចរន្តទាំងនោះមានទឹកប្រាក់ស្មើគ្នា ការសងត្រូវសងទៅតាមសមាមាត្រដូចគ្នាលើគណនីនិមួយៗ ។

ម្ចាស់ហ៊ុនណាដែលចង់ដកយកវិញនូវប្រាក់ដែលខ្លួនបានដាក់ត្រូវជូនដំណឹងចំពោះអភិបាលក្នុងរយះពេល ៣ ខែជាមុន ។

# ប្រការទី ៦

## ភាគហ៊ុននៃក្រុមហ៊ុន អនុប្បទាន និង ការផ្ទេរភាគហ៊ុន

### ៦-១ : ភាគហ៊ុននៃក្រុមហ៊ុន

### ៦-១.១ : សិទ្ធិ និងភារកិច្ចនៃភាគហ៊ុន

រាល់ភាគហ៊ុន មិនអាចត្រូវតំណាងដោយប័ណ្ណលក់ដូរសេរីលើផ្សារហ៊ុនបានឡើយ ។ ភាគហ៊ុននីមួយៗ ផ្តល់ជូនកម្មសិទ្ធិករនូវសិទ្ធិស្មើគ្នាក្នុងប្រាក់ចំណេញ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន ។

ភាគហ៊ុនមួយ ផ្តល់នូវអំណាចមានសំលេងមួយនៅក្នុងការបោះឆ្នោត និងនៅក្នុងសេចក្តីសំរេចចិត្តទាំងឡាយរបស់ក្រុមហ៊ុន ។

ម្ចាស់ហ៊ុនទាំងឡាយទទួលខុសត្រូវ និងរ៉ាប់រងចំពោះបំណុល និងការខាតបង់របស់ក្រុមហ៊ុនត្រឹមតែចំនួនទឹកប្រាក់នៃភាគទុនផ្ទាល់របស់ខ្លួន ដែលមានដាក់មកក្នុងក្រុមហ៊ុន ។ លើសពីនេះ រាល់ការអំពាវនាវមូលនិធិអំពីសាធារណៈជនត្រូវបានហាមឃាត់ ។

ការកាន់កាប់កម្មសិទ្ធិលើភាគហ៊ុនមួយ ផ្តល់នូវសិទ្ធិអំណាចពេញលេញក្នុងការចូលរួមជាម្ចាស់ហ៊ុន ក្នុងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន និងសិទ្ធិអំណាចចូលរួមក្នុងមហាសន្និបាតទាំងឡាយនៃក្រុមហ៊ុន ។

ទោះបីនៅក្នុងដៃជនណាក៏ដោយ រាល់សិទ្ធិអំណាច និងភារកិច្ចរបស់ភាគហ៊ុន ត្រូវរក្សាទុកដដែល ។

អ្នកតំណាង ប្រតិសិទ្ធិ ទាយាទ និង ម្ចាស់បំណុលផ្ទាល់ខ្លួនរបស់ម្ចាស់ហ៊ុនម្នាក់ៗ ទោះបីក្នុងលេសណាមួយក៏ដោយ មិនមានសិទ្ធិបង្ខំបិទទ្វារក្រុមហ៊ុន ឃុំឃាំងទ្រព្យសម្បត្តិ និងឯកសាររបស់ក្រុមហ៊ុន ឬក៏ជ្រៀតជ្រែកតាមបែបណាមួយក្តីចូលទៅក្នុងកិច្ចការគ្រប់គ្រងក្រុមហ៊ុនឡើយ ។ អ្នកទាំងនេះ នៅក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន ត្រូវគោរពទៅតាមសេចក្តីសំរេចនៃការជំរះបញ្ជីសារពើភ័ណ្ឌ និងសេចក្តីសំរេចនៃម្ចាស់ហ៊ុនទាំងអស់ ។

### ៦-១.២ : អវិភាគីយភាព នៃភាគហ៊ុន

ភាគហ៊ុននីមួយៗមិនអាចចែកបានចំពោះក្រុមហ៊ុន។ កម្មសិទ្ធិករអវិភាគទាំងឡាយ (ដែលទទួលកម្មសិទ្ធិទាំងមូល) ត្រូវតែងតាំងអាណត្តិគាហកមួយរូបដែលជ្រើសរើសយកពីក្នុងចំណោមខ្លួនទាំងឡាយ ឬអ្នកដទៃពីនេះ ដើម្បីធ្វើជាតំណាងនៅអមក្រុមហ៊ុន ។ បើគ្មានការព្រមព្រៀងគ្នាទេ កម្មសិទ្ធិករអវិភាគដែលរៀសរវៃជាងគេត្រូវស្នើសុំទៅប្រធានតុលាការមានសមត្ថកិច្ច អោយតែងតាំងអាណត្តិគាហកនេះ ។

### ៦-២ : អនុប្បទាន និង ការផ្ទេរភាគហ៊ុន

**៦-២.១ :** រាល់ម្ចាស់ហ៊ុន អាចធ្វើអនុប្បទានភាគហ៊ុនរបស់ខ្លួនមួយផ្នែកឬទាំងស្រុងនិងគ្រប់ពេលវេលាជូនទៅម្ចាស់ហ៊ុនដូចគ្នា ឬជូនទៅតតិយជនជាសមាជិកគ្រួសារ បុគ្គលដទៃ ឬក្រុមមនុស្សផ្សេងទៀតដែលមានផលប្រយោជន៍គ្រួសារ ឬអាជីវកម្មរួមគ្នា ។

រាល់អនុប្បទានភាគហ៊ុន ត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ជាលិខិតរវាងឯកជន ឬជាលិខិតសារការី ។ ដើម្បីបានប្រសិទ្ធិភាពជាមួយក្រុមហ៊ុន ឬជាមួយតតិយជន លិខិតនេះត្រូវមានការបញ្ជាក់ទទួលស្គាល់របស់ក្រុមហ៊ុន ហើយតំកល់ទុកមួយច្បាប់ដើមនៅទីស្នាក់ការក្រុមហ៊ុន និងនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ព្រមទាំងចុះផ្សាយក្នុង

៦-២.២ : ការធ្វើអនុប្បទានភាគហ៊ុន អាចប្រព្រឹត្តដោយសេរីរវាងម្ចាស់ហ៊ុន និង ម្ចាស់ហ៊ុនដូចគ្នា ។ ការធ្វើអនុប្បទាននេះក៏អាចប្រព្រឹត្តដោយសេរីដែររវាងម្ចាស់ហ៊ុនម្នាក់ និងសហព័ទ្ធ បុព្វជន កូនចៅ ទោះបីជាអនុប្បទានិកទាំងនេះមិនមែនជាម្ចាស់ហ៊ុនក៏ដោយ ។

៦-២.៣ : ការធ្វើអនុប្បទានភាគហ៊ុនដោយគិតថ្លៃក្តីឬឥតគិតថ្លៃក្តី ជូនទៅតតិយជនដែលមិនមែនជាម្ចាស់ហ៊ុន ឬជូនទៅអ្នកដទៃក្រៅពីសហព័ទ្ធ បុព្វជន កូនចៅ អាចប្រព្រឹត្តទៅបានដោយសេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុន តំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

បំណងធ្វើអនុប្បទានភាគហ៊ុន ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរទៅក្រុមហ៊ុន និងធ្វើជាលិខិតអនុសិដ្ឋជូនទៅម្ចាស់ហ៊ុនដទៃទៀត ដែលមានបញ្ជាក់ការបានទទួល ។

បើក្រុមហ៊ុនមិនយល់ព្រមលើការធ្វើអនុប្បទាននេះទេ ក្នុងអំឡុងពេលពាខែនៃការជូនដំណឹងថា មិនយល់ព្រមនេះក្រុមហ៊ុនត្រូវធ្វើលិខិតជូនដំណឹងដល់គ្រប់ម្ចាស់ហ៊ុនដទៃទៀត ដើម្បីទិញយកភាគហ៊ុនដែលចង់ធ្វើអនុប្បទាននេះ ទៅតាមតំលៃមួយឯកភាពរវាងភាគីទាំងអស់ ។

ក្រុមហ៊ុនអាចសំរេចក្រោមការព្រមព្រៀងគ្នាជាមួយម្ចាស់ហ៊ុន ដែលចង់ធ្វើអនុប្បទាន ធ្វើការបន្ថយនូវដើមទុនក្នុងតំលៃជាប្រាក់ស្មើនឹងភាគហ៊ុនអនុប្បទាន និងធ្វើការទិញយកវិញនូវភាគហ៊ុនទាំងនោះ តាមតំលៃកំណត់ក្នុងល័ក្ខខ័ណ្ឌដូចចែងខាងលើ ។

បើហួសពីរយៈពេល ៣ ខែ ក្រុមហ៊ុនមិនបានទិញ ឬមិនបានចាត់ចែងអោយម្ចាស់ហ៊ុនណាម្នាក់ ឬតតិយជនណាម្នាក់អោយទិញយកនូវភាគហ៊ុនទាំងនេះទេ ឬមិនបានផ្តល់ចំលើយស្តីអំពីការសំរេចអំពីករណីធ្វើអនុប្បទានភាគហ៊ុននេះទេ នោះនឹងចាត់ទុកថាក្រុមហ៊ុនយល់ព្រមលើការធ្វើអនុប្បទាននេះ ហើយសមាជិកដែលចង់ធ្វើអនុប្បទានអាចអនុវត្តនូវការធ្វើអនុប្បទានដូចមានចែងពីខាងដើមដោយបញ្ញត្តិ ។

៦-២.៤ : ក្នុងករណីមរណភាពនៃម្ចាស់ហ៊ុនម្នាក់ ក្រុមហ៊ុនអាចបន្តដំណើរការជាប្រក្រតីរវាងម្ចាស់ហ៊ុនទាំងឡាយដែលនៅរស់ ជាមួយនឹងសិទ្ធិវន្ត ឬទាយាទនៃម្ចាស់ហ៊ុនដែលស្លាប់ និងជាយថាហេតុ ជាមួយសហព័ទ្ធនៅរស់ ដោយអ្នកខាងក្រោយទាំងនេះ មិនមែនជាម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន លើកលែងតែមានល័ក្ខខ័ណ្ឌណាផ្សេង ដែលតំរូវអោយការព្រមព្រៀងគ្នារវាងអ្នកទាំងឡាយនេះ ត្រូវធ្វើឡើងតាមសេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុនតំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

បើមានល័ក្ខខ័ណ្ឌតំរូវបែបនេះ ទាយាទ សិទ្ធិវន្ត ឬសហព័ទ្ធ ត្រូវផ្តល់នូវសំណុំលិខិតទាំងឡាយ ដែលបញ្ជាក់នូវលក្ខណៈពិតជាទាយាទ សិទ្ធិវន្ត ឬសហព័ទ្ធរបស់ខ្លួន ជូនមកក្រុមហ៊ុនក្នុងរយៈពេល ៣ ខែ យ៉ាងយូរ គិតពីថ្ងៃមរណៈភាពដើម្បីម្ចាស់ហ៊ុនទាំងអស់ពិគ្រោះគ្នា ។ ក្នុងរយៈពេល ៨ ថ្ងៃ ចាប់ពីបានទទួលសំណុំលិខិតទាំងនេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវផ្ញើជូនម្ចាស់ហ៊ុនទាំងអស់នូវលិខិតអនុសិដ្ឋមានបញ្ជាក់ការបានទទួល ដែលក្នុងលិខិតនោះមានរៀបរាប់បង្ហាញនូវលក្ខណៈពិតរបស់ទាយាទ សិទ្ធិវន្ត ឬសហព័ទ្ធនៃម្ចាស់ហ៊ុនស្លាប់ ព្រមទាំងចំនួននៃភាគហ៊ុនរបស់សមាជិកស្លាប់នោះ ។ លិខិតនេះ សំណូមពរអោយម្ចាស់ហ៊ុនទាំងអស់ផ្តល់នូវចំលើយព្រមព្រៀងរបស់ខ្លួន ។ ក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយពីបានទទួលលិខិតសំណូមពរនេះ ម្ចាស់ហ៊ុនទាំងអស់ត្រូវតែផ្តល់ចំលើយយល់ព្រម ឬមិនយល់ព្រម ។ ហួសពីពាខែនេះ ម្ចាស់ហ៊ុនដែលមិនបានឆ្លើយតបនឹងត្រូវចាត់ទុកថាយល់ព្រម ។

# ប្រការទី ៧

## ការបែងចែកលទ្ធផល - ការទូទាត់ភាគលាភ

### ៧-១ : ការបែងចែកលទ្ធផល

គណនីនៃលទ្ធផល ដែលសរុបផលទទួលបាន ដកចេញនូវបន្ទុកទាំងឡាយនៃការិយបរិច្ឆេទ បន្ទាប់ពីបានដកចេញនូវការរំលស់ទុន និងសំវិធានធនទាំងឡាយ បង្កើតបានជាប្រាក់ចំណេញ ឬការខាតបង់នៃការិយបរិច្ឆេទ ។

លើប្រាក់ចំណេញនេះ ក្រោយពីបានកាត់ចេញនូវប្រាក់ខាតពីមុន ត្រូវដកយក ៥ % សំរាប់បង្កើតមូលនិធិបំរុងស្របច្បាប់ ។ ការដកយក ៥ % នេះ នឹងត្រូវបញ្ឈប់នៅពេលដែលមូលនិធិបំរុងកើនដល់ចំនួន ១០ % នៃដើមទុនក្រុមហ៊ុន ។

ប្រាក់ចំណេញដែលអាចបែងចែកជូនម្ចាស់ហ៊ុនបាន គឺប្រាក់ចំណេញដែលកាត់ចេញនូវប្រាក់ខាតពីមុន និងដកចេញនូវប្រាក់សំរាប់មូលនិធិបំរុងស្របច្បាប់ព្រមទាំងបូកបន្ថែមនូវប្រាក់គំរៃដែលលើសទុកពីមុន ។

ប្រាក់ចំណេញនេះ ត្រូវបានដាក់ជូនសន្និបាតចាត់ចែងដែលតាមសំណើរបស់អភិបាល អាចរក្សាទុកជាថ្មីសំរាប់ឆ្នាំក្រោយ ឬចាត់ចែងដាក់ទៅក្នុងមូលនិធិបំរុងទូទៅ ឬពិសេស ឬចាត់ចែងបែងចែកជូនម្ចាស់ហ៊ុនទាំងឡាយទៅតាម សមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។ ម្យ៉ាងទៀត មហាសន្និបាតអាចសំរេចធ្វើការបែងចែកនូវប្រាក់បំរុងដែលអាចចាត់ចែងបាន ហើយសេចក្តីសំរេចនេះ ត្រូវបញ្ជាក់ច្បាស់លាស់នូវប្រភេទនៃមូលនិធិបំរុង ដែលត្រូវបានកាត់ដកយកប្រាក់បំរុងមកបែងចែកនេះ ។ ក៏ប៉ុន្តែភាគលាភត្រូវកាត់យកជាអាទិភាពអំពីប្រាក់ចំណេញដែលអាចបែងចែកបាននៃការិយបរិច្ឆេទ ។

### ៧-២ : ការទូទាត់ភាគលាភ

ក្រោយពីបានយល់ព្រមលើគណនីនិងពិនិត្យឃើញថា មានចំនួនប្រាក់គ្រប់គ្រាន់សំរាប់ធ្វើការបែងចែកនោះ គេត្រូវធ្វើការចាត់ចែងបែងចែកនិងទូទាត់ភាគលាភ ។ ទំរង់បែបបទនៃការបែងចែកត្រូវកំណត់ដោយសន្និបាតនៃសមាជិកហ៊ុន ឬបើពុំនោះទេ ដោយអភិបាលនៃក្រុមហ៊ុន ។ ការទូទាត់ភាគលាភត្រូវតែធ្វើឡើងនៅក្នុងរយៈពេលយឺតបំផុត ៩ ខែ គិតពីថ្ងៃបិទការិយបរិច្ឆេទ ។ រយៈពេលនេះ អាចត្រូវបានពន្យាដោយដីការនៃប្រធានតុលាការមានសមត្ថកិច្ច ដែលសំរេចតាមការស្នើសុំរបស់អភិបាល ។

**ការខាតបង់ :** ការខាតបង់ដែលពិនិត្យឃើញនៅក្នុងបញ្ជីគណនេយ្យ នឹងត្រូវបែងចែកសងទៅតាមសមាមាត្រនៃភាគហ៊ុនដែលម្ចាស់ហ៊ុនម្នាក់ៗមាន ។ សល់ពីនោះនឹងត្រូវសងរំលស់ ដោយកាត់យកពីប្រាក់ចំណេញនៃឆ្នាំបន្តបន្ទាប់ ។

# ប្រការទី ៨

## ឆ្នាំការិយបរិច្ឆេទនៃក្រុមហ៊ុន - បញ្ជីសារពើភ័ណ្ឌ

ឆ្នាំការិយបរិច្ឆេទចាប់ផ្តើមពីថ្ងៃទី ១ ខែ មករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ដោយលើកលែងឆ្នាំការិយបរិច្ឆេទដំបូង និងត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំបង្កើតក្រុមហ៊ុន ។

នៅពេលបិទការិយបរិច្ឆេទនិមួយៗ អភិបាលត្រូវធ្វើបញ្ជីសារពើភ័ណ្ឌអំពីទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុន បញ្ជីតុល្យការរៀបរាប់លំអិតនូវទ្រព្យសកម្ម និងបំណុលគណនីនៃលទ្ធផលសរុប ផលទទួលបាន និងបន្ទុកទាំងឡាយ ឧបសម្ព័ន្ធភ្ជាប់ជាមួយ ព្រមទាំងអធិប្បាយនូវពត៌មានក្នុងបញ្ជីតុល្យការ និងគណនីនៃលទ្ធផល ។

ទោះបីគ្មានចំណេញ ឬមានប្រាក់ចំណេញមិនគ្រប់គ្រាន់ក៏ដោយ អភិបាលត្រូវចាត់ចែងធ្វើការរំលោះទុន និងសំវិធានធនចាំបាច់ ។

អភិបាលត្រូវធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រងដែលទាក់ទងដល់ការិយបរិច្ឆេទកន្លងមក ។

របាយការណ៍ស្តីពីការគ្រប់គ្រងក្រុមហ៊ុន បញ្ជីតុល្យការ គណនីនៃលទ្ធផល និងឧបសម្ព័ន្ធពង្រាងអត្ថបទនៃសេចក្តីសំរេចសំរាប់ដាក់ស្នើសុំយោបល់ និងជាយថាហេតុរបាយការណ៍នៃស្នងការគណនី ត្រូវតែបានផ្ញើជូនទៅម្ចាស់ហ៊ុនទាំងឡាយយ៉ាងតិច ២០ ថ្ងៃមុននឹងបើកសន្និបាត ដែលកោះប្រជុំដើម្បីពិនិត្យសំរេចលើគណនីទាំងនេះ ។

ចាប់ពីថ្ងៃដែលបានទទួលពត៌មានទាំងនេះ ម្ចាស់ហ៊ុនម្នាក់ៗ មានសិទ្ធិចោទសំណួរជាលាយល័ក្ខអក្សរ ដែលអភិបាលមានកាតព្វកិច្ចនឹងឆ្លើយបកស្រាយនៅក្នុងសន្និបាត ។

នៅក្នុងអំឡុងពេល ២០ ថ្ងៃ មុនសន្និបាត បញ្ជីសារពើភ័ណ្ឌត្រូវដាក់នៅទីស្នាក់ការ សំរាប់ម្ចាស់ហ៊ុនទាំងឡាយដែលចង់ពិនិត្យ ។

ជាប្រចាំ គ្រប់ម្ចាស់ហ៊ុនមានសិទ្ធិរាល់ពេលក្នុងការយកពត៌មានដោយផ្ទាល់ខ្លួន និងនៅទីស្នាក់ការក្រុមហ៊ុន អំពីគណនីប្រចាំឆ្នាំ បញ្ជីសារពើភ័ណ្ឌ របាយការណ៍ទាំងឡាយដែលបានដាក់ជូនសន្និបាត ព្រមទាំងកំណត់ហេតុទាំងឡាយនៃសន្និបាតដែលទាក់ទងទៅនឹងការិយបរិច្ឆេទទាំងបាឆ្នាំកន្លងមក ។

## ប្រការទី ៩

## ការរំលាយក្រុមហ៊ុន – ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន – វិវាទ

### ៩–១ : ការខាតបង់លើដើមទុន – ការរំលាយក្រុមហ៊ុនមុនការកំណត់

ក្នុងករណីមានការខាតបង់ ៣/៤ នៃដើមទុនក្រុមហ៊ុន ក្រុមហ៊ុនត្រូវរំលាយចោលបើប្រសិនណាស្ថានការណ៍មិនអាចធ្វើអោយមានប្រក្រតីភាពឡើងវិញបានក្នុងថេរវេលា ១ ឆ្នាំ ។

ក្រុមហ៊ុនក៏អាចត្រូវបានរំលាយមុនការកំណត់បានដោយសេចក្តីសំរេចសមូហភាពនៃម្ចាស់ហ៊ុន ទោះបីមិនមានការខាតបង់ដើមទុនដូចខាងលើក៏ដោយ ។

ក្រុមហ៊ុនក៏អាចត្រូវរំលាយបានដែរ តាមផ្លូវតុលាការ ដោយមូលហេតុត្រឹមត្រូវ ។

### ៩–២ : ការរំលាយក្រុមហ៊ុន – ការជំរះបញ្ជី

នៅពេលផុតថេរវេលានៃក្រុមហ៊ុន ឬក្នុងករណីមានការរំលាយក្រុមហ៊ុនដោយមូលហេតុណាមួយក្តី ក្រុមហ៊ុនត្រូវធ្វើការជំរះបញ្ជី ។

ក៏ប៉ុន្តែការរំលាយនេះ មានអនុភាពចំពោះតតិយជនចាប់ពីថ្ងៃ ដែលបានប្រកាសផ្សាយក្នុងបញ្ជីពាណិជ្ជកម្ម ។

នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន មានអត្ថិភាពសំរាប់តំរូវការជំរះបញ្ជី រហូតដល់ពេលបិទការជំរះបញ្ជីនេះ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ។ និទ្ទេសន៍ "ក្រុមហ៊ុនស្ថិតក្នុងការជំរះបញ្ជី" ព្រមទាំងនាមនៃអ្នកជំរះបញ្ជីត្រូវតែមានចែងលើរាល់លិខិតស្នាម និងឯកសារទាំងឡាយដែលផ្សាយចេញពីក្រុមហ៊ុន ។

ការជំរះបញ្ជីត្រូវធ្វើឡើងដោយអ្នកជំរះបញ្ជីម្នាក់ឬច្រើននាក់ ដែលតែងតាំងដោយម្ចាស់ហ៊ុនតំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។ អ្នកជំរះបញ្ជីអាចត្រូវបានជ្រើសរើសក្នុងចំណោមម្ចាស់ហ៊ុន ឬយកអ្នកដទៃក្រៅពីនេះ ។

ការជំរះបញ្ជីត្រូវអនុវត្តស្របទៅតាមច្បាប់ ។

ផលពិតបានមកពីការជំរះបញ្ជី ជាដំបូងត្រូវប្រើប្រាស់សំរាប់សងវិញទឹកប្រាក់ភាគហ៊ុនដែលមិនទាន់បានសង ។ ចំណែកដែលសល់លើសពីនោះ នឹងត្រូវបែងចែកជូនម្ចាស់ហ៊ុនទាំងឡាយទៅតាមសមាមាត្រនៃភាគហ៊ុនដែលម្នាក់ៗមាន ។

## ៩-៣ : មរណភាព – ការហាមឃាត់ – ធនក្ស័យនៃម្ចាស់ហ៊ុនម្នាក់

មរណៈភាព អសមត្ថភាព ការហាមឃាត់ ធនក្ស័យ ឬភាពហិនហោចរបស់ម្ចាស់ហ៊ុនណាមួយដែលជារូបវន្តបុគ្គល ព្រមទាំងការកែទំរង់ឡើងវិញ ឬការជំរះបញ្ជីតាមផ្លូវតុលាការរបស់ម្ចាស់ហ៊ុនមួយ ដែលជានីតិបុគ្គល មិនបណ្តាលអោយក្រុមហ៊ុនរំលាយឡើយ ។ ក៏ប៉ុន្តែ បើព្រឹត្តិការណ៍ណាមួយក្នុងចំណោមព្រឹត្តិការណ៍ខាងលើបានកើតមានឡើងចំពោះអភិបាល អភិបាលនេះត្រូវបានបញ្ឈប់អំពីតំណែងជាអភិបាលភ្លាម ។

## ៩-៤ : ការផ្លាស់ប្តូរទម្រង់ទ្រាយក្រុមហ៊ុន

ការផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុនទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត អាចធ្វើបានដោយសេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុន តំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។ ការផ្លាស់ប្តូរនេះ អាចអនុវត្តបានតែនៅក្រោយពេលដែលក្រុមហ៊ុនសំរេចបានតុល្យការនៃការិយបរិច្ឆេទ ២ ឆ្នាំ រួចមកហើយ ។

ប្រសិនបើនៅក្នុងតុល្យការខាងក្រោយដើមទុនជាក់ស្តែងបានកើនរហូតដល់ ចំនួនលើសពី ១០០,០០០,០០០ រៀល (មួយរយលានរៀល) ក្រុមហ៊ុនអាចផ្លាស់ប្តូរទ្រង់ទ្រាយទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបាន ដោយសេចក្តីសំរេចរបស់មហាសន្និបាតម្ចាស់ហ៊ុនតំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ដែលវត្តមានក្នុងអង្គប្រជុំ ។

រាល់សេចក្តីសំរេចផ្លាស់ប្តូរទ្រង់ទ្រាយក្រុមហ៊ុន ត្រូវតែមានធ្វើជាមុននូវរបាយការណ៍លើស្ថានភាពរបស់ក្រុមហ៊ុនទោះបីជាក្រុមហ៊ុនមិនទាន់មានសវនករនៅឡើយក៏ដោយ ។

នៅក្រោយរយៈពេល២ឆ្នាំ បើចំនួនម្ចាស់ហ៊ុនកើនលើសពី ៣០ រូប ក្រុមហ៊ុនក៏អាចផ្លាស់ប្តូរទ្រង់ទ្រាយទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតបានដែរ ។

## ៩-៥ : វិវាទ

រាល់បណ្តឹងជំទាស់ ឬវិវាទ ដែលអាចកើតឡើងរវាងម្ចាស់ហ៊ុននិងម្ចាស់ហ៊ុន ឬរវាងម្ចាស់ហ៊ុនជាមួយនឹងអភិបាល និងជាមួយក្រុមហ៊ុន នៅក្នុងថេរវេលាក្រុមហ៊ុន ឬនៅក្នុងរយៈពេលជំរះបញ្ជី ត្រូវធ្វើការដោះស្រាយដោយការសំរុះសំរួលគ្នាក្នុងក្រុមហ៊ុន ។ ក្នុងករណីមិនអាចសំរុះសំរួលគ្នាបានទេ នឹងត្រូវដាក់ជូនទៅស្ថាប័នផ្សះផ្សាវិវាទពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការទី ១០

## អភិបាល - អំណាចរបស់ប្រធានក្រុមប្រឹក្សាភិបាល - ការតែងតាំងក្រុមប្រឹក្សាភិបាល

### ១០-១ : អភិបាល

ក្រុមហ៊ុនត្រូវបានចាត់ចែង និងគ្រប់គ្រងដោយអភិបាលម្នាក់ ឬច្រើននាក់ ជារូបវន្តបុគ្គល ដែលជ្រើសតាំងដោយម្ចាស់ហ៊ុនទាំងអស់ ។ ក្រុមប្រឹក្សាភិបាល ត្រូវរួមប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់ ៣ ខែ ។

អាណត្តិរបស់អភិបាលអាចមានរយៈពេលមិនកំណត់ ។

អភិបាលអាចត្រូវបានជ្រើសតាំងឡើងវិញ ក្នុងករណីចាំបាច់ និងសមស្រប ។

អភិបាលត្រូវបានជ្រើសតាំងតាមសេចក្តីសំរេចនៃម្ចាស់ហ៊ុនទាំងឡាយ ដែលតំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុនដែលវត្តមានក្នុងអង្គប្រជុំ ។

អភិបាលអាចលាលែងពីតំណែងខ្លួនបាន ក៏ប៉ុន្តែត្រូវតែជូនដំណឹងយ៉ាងតិច៣ខែមុន ដោយលិខិតអនុសិដ្ឋមានបញ្ជាក់ការបានទទួលផ្ញើជូនម្ចាស់ហ៊ុនគ្រប់រូប ។

អភិបាលអាចត្រូវបានដកហូតតំណែងបាន ដោយសេចក្តីសំរេចនៃម្ចាស់ហ៊ុនទាំងឡាយ ដែលតំណាងអោយសំលេងភាគច្រើនលើសពី ៥១ % នៃអំណាចបោះឆ្នោតរបស់ម្ចាស់ហ៊ុន ដែលវត្តមានក្នុងអង្គប្រជុំ ។

អភិបាលអាចទទួលក្នុងលក្ខណៈជារង្វាន់នៃមុខតំណែងនូវប្រាក់បៀវត្ស ដែលកំណត់ជូនដោយសេចក្តីសំរេចនៃម្ចាស់ហ៊ុនទាំងឡាយ ។

នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល សេចក្តីសំរេចរបស់អង្គប្រជុំ ត្រូវបានអនុលោមទៅតាមសំលេងភាគច្រើននៃចំនួនអភិបាលទាំងឡាយដែលមានវត្តមានក្នុងអង្គប្រជុំ ។ កូរ៉ុមរបស់ក្រុមប្រឹក្សាភិបាលគឺវត្តមានដោយផ្ទាល់នៃចំនួនភាគ ច្រើនរបស់អភិបាលនៅពេលប្រជុំ ។ អភិបាលអាចធ្វើជាអាណត្តិគាហកអោយអភិបាលតែមួយរូប នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយមានការអនុញ្ញាតជាលាយល័ក្ខអក្សរ ។

ប្រធានក្រុមប្រឹក្សាភិបាល ឬក្នុងករណីចាំបាច់ ១/៣ នៃចំនួនអភិបាលមានសិទ្ធិអាចកោះប្រជុំមហាសន្និបាតរបស់ក្រុមប្រឹក្សាភិបាល ដោយធ្វើលិខិតអញ្ជើញផ្ញើជូនទៅអភិបាលទាំងអស់យ៉ាងយូរបំផុត ២០ ថ្ងៃមុនប្រជុំ ។

លិខិតអញ្ជើញចំពោះអភិបាលក្នុងប្រទេសកម្ពុជា ត្រូវផ្ញើតាមប្រៃសណីយ៍ ឬអ្នកនាំសាររបស់ក្រុមហ៊ុន ឬតាមហ្វាក់ ។

លិខិតអញ្ជើញចំពោះអភិបាលក្រៅប្រទេសនឹងផ្ញើភ្លាមៗ តាមយន្តហោះ ឬតាមទូរសារ (ហ្វាក់) ឬតាមទូរលេខ ។ លិខិតអញ្ជើញនោះ នឹងបញ្ជាក់ពិសេសដោយឡែកអំពីកន្លែង កាលបរិច្ឆេទ និងពេលម៉ោងរបស់កិច្ចប្រជុំនោះ និងរបៀបវារៈដែលត្រូវចរចា ។

រាល់អភិបាលត្រូវតែកល់ទុកនៅឯទីស្នាក់ការក្រុមហ៊ុន នូវអាស័យដ្ឋានជាក់លាក់បច្ចុប្បន្នរបស់ខ្លួន ។ បើពុំដូច្នោះទេ អភិបាលនោះមិនអាចប្តឹងតវ៉ាបានឡើយ ប្រសិនបើខ្លួនមិនបានទទួលសេចក្តីជូនដំណឹងពីកិច្ចប្រជុំណាមួយ ។

## ១០-២ : អំណាចរបស់ប្រធានក្រុមប្រឹក្សាភិបាល

នៅក្នុងទំនាក់ទំនងជាមួយតតិយជន ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានប្រគល់អំណាចជូនយ៉ាងទូលំទូលាយ ដើម្បីធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុននៅគ្រប់កាលៈទេសៈ ។

ប្រធានក្រុមប្រឹក្សាភិបាល មានអំណាចគ្រប់គ្រាន់ជាតំណាងអោយក្រុមហ៊ុន និងធ្វើសកម្មភាពចុះហត្ថលេខាលើរាល់កិច្ចការដែលស្ថិតក្នុងរង្វង់ក្របខ័ណ្ឌនៃកម្មវត្ថុរបស់ក្រុមហ៊ុន ហើយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះតតិយជន ។ ការប្រើប្រាស់អំណាចក្នុងប្រការណាមួយដែលផ្ទុយពីកិច្ចការដែលរៀបរាប់រួចមកហើយនេះ ត្រូវចាត់ទុកជាមោឃៈនូវហត្ថលេខារបស់អភិបាល ហើយការប្រព្រឹត្តល្មើសនេះ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះបន្ទុយទាំងឡាយ ដែលមានកើតឡើងដោយសារកំហុសទាំងនេះ និងអាចត្រូវបានដកហូតពីមុខតំណែងចេញពីប្រធានក្រុមប្រឹក្សាភិបាល ។

ការចុះកិច្ចសន្យារបស់ប្រធានក្រុមប្រឹក្សាភិបាលជាមួយតតិយជន លើកិច្ចការទាំងឡាយដែលស្ថិតនៅក្រៅកម្មវត្ថុអាជីវកម្ម ក៏បណ្តាលអោយក្រុមហ៊ុនជាប់កិច្ចសន្យានោះជាមួយតតិយជនដែរ ។ ក្នុងករណីនេះ ក្រុមហ៊ុនក៏អាចប្រកែកមិនទទួលខុសត្រូវរបស់ខ្លួនបានដែរ ដោយភស្តុតាងបញ្ជាក់ថា តតិយជននោះបានដឹងដោយច្បាស់លាស់ថា កិច្ចការដែលខ្លួនបានចុះកិច្ចសន្យានោះហួសពីកម្មវត្ថុអាជីវកម្ម ឬមួយភស្តុតាងបញ្ជាក់ថា តតិយជននោះមិនអាចដោះសារថាខ្លួនមិនបានដឹង ដោយកាលៈទេសៈ ។ ក្រុមហ៊ុនមិនអាចយកការចុះផ្សាយសំរង់លក្ខន្តិកៈក្នុងសារពត៌មានមកធ្វើជាភស្តុតាងគ្រប់គ្រាន់ សំរាប់ជាសំអាង ដើម្បីរួចផុតពីការទទួលខុសត្រូវលើកិច្ចសន្យាដូចបានពោលខាងលើនេះបានទេ ។ ដូច្នេះ នៅពេលកើតវិវាទបែបនេះ ត្រូវតែផ្តល់នូវឯកសារសំអាងនានាដូចជា លិខិតសំអាងជាលាយល័ក្ខអក្សរ វត្ថុតាងផ្សេងៗ ។ ល។

នៅក្នុងទំនាក់ទំនងជាមួយម្ចាស់ហ៊ុនទាំងអស់ ប្រធានក្រុមប្រឹក្សាភិបាលអាចធ្វើរាល់កិច្ចការចាត់ចែងគ្រប់យ៉ាង ដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន ។ ក៏ប៉ុន្តែ កិច្ចការខ្លះដូចមានបញ្ជាក់ខាងក្រោមនេះ ត្រូវតែមានការអនុញ្ញាតដោយសេចក្តីសំរេចជាឯកច្ឆ័ន្ទនៃម្ចាស់ហ៊ុនទាំងឡាយ គឺការទិញ ការលក់ ការដោះដូរអចលនទ្រព្យ ឬមូលនិធិពាណិជ្ជកម្ម ការចុះកិច្ចសន្យាខ្ចីបុលក្នុងនាមក្រុមហ៊ុន ការខ្ចីឥណទានពីធនាគារ ការធ្វើអ៊ីប៉ូតែកលើអសង្ហារឹមភ័ណ្ឌរបស់ក្រុមហ៊ុន ឬការបញ្ចាំមូលនិធិពាណិជ្ជកម្ម ឬការចូលរួមសហការក្នុងការបង្កើតក្រុមហ៊ុននានា ការកែប្រែលក្ខន្តិកៈ ។

ប្រធានក្រុមប្រឹក្សាភិបាលអាចតែងតាំងអាណត្តិគាហកម្នាក់ ឬច្រើននាក់អោយទទួលចាត់ចែងនូវកម្មវត្ថុណាមួយ ឬកម្មវត្ថុមួយចំនួន ដោយមានការកំណត់ជាក់លាក់ជាជំនួសខ្លួន និងក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ ។

១០-៣ ៖ ការតែងតាំងក្រុមប្រឹក្សាភិបាល

ត្រូវបានតែងតាំងជាអភិបាលនៃក្រុមហ៊ុនសំរាប់អាណត្តិមានរយៈពេលមិនកំណត់ឆ្នាំចំពោះ ៖

១- លោក យល់ព្រមទទួលមុខងារជាប្រធានក្រុមប្រឹក្សាភិបាល

ទីលំនៅ ៖ លេខ ២៣ ផ្លូវលេខ ៤៤៦ សង្កាត់ទួលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ

២- លោកស្រី យល់ព្រមទទួលមុខងារជាអភិបាល

ទីលំនៅ ៖ លេខ ២៣ ផ្លូវលេខ ៤៤៦ សង្កាត់ទួលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ

១- លោក

២- លោកស្រី

ប្រកាសថាយល់ព្រមទទួលមុខងារជាអភិបាលដែលបានប្រគល់ជូននិងធានាថាមិនដែលមានជាប់ទោសកំហុសណាមួយ ដែលហាមឃាត់ដល់ការតែងតាំងនេះឡើយ ។

រាល់អភិបាលដែលបានតែងតាំងនេះសន្យាថានឹងលះបង់រាល់ពេលវេលាចាំបាច់សំរាប់ធ្វើកិច្ចការរបស់ក្រុមហ៊ុន ស្មោះត្រង់ជាមួយក្រុមហ៊ុន និងធ្វើការងារដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន ។

## ប្រការទី ១១

## នីតិបុគ្គលិកលក្ខណៈ - ការចុះបញ្ជីពាណិជ្ជកម្ម - ការចុះផ្សាយ - សោហ៊ុយ

១១-១ ៖ ក្រុមហ៊ុនមាននីតិបុគ្គលិកលក្ខណៈពេញលេញ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីពាណិជ្ជកម្ម ។

ដើម្បីទទួលបានការចុះបញ្ជីពាណិជ្ជកម្មនេះ ស្ថាបនិក ឬអភិបាល ឬអាណត្តិគាហកដែលមានសមត្ថភាពតាមផ្លូវច្បាប់ ត្រូវចុះឈ្មោះនិងតំកល់ទុកលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មតាមការបញ្ញត្តិនៃច្បាប់ ។

១១-២ ៖ រាល់សិទ្ធិពេញលេញ ត្រូវបានប្រគល់ជូនស្ថាបនិក ឬអភិបាល ឬអាណត្តិគាហកដែលមានសមត្ថភាពតាមផ្លូវច្បាប់ ដើម្បីបំពេញទំរង់ការនៃការផ្សព្វផ្សាយដែលច្បាប់បានបញ្ញត្តិ និងជាពិសេសដើម្បីចុះហត្ថលេខាលើសេចក្តីប្រកាសចុះផ្សាយក្នុងសារពត៌មាន ។

១១-៣ ៖ រាល់សោហ៊ុយចំណាយ ពន្ធអាករផ្សេងៗ និងកំរៃនានាដែលកើតមានមុនពេលក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម ត្រូវជាបន្ទុករបស់ម្ចាស់ហ៊ុនទាំងអស់គ្នា ទៅតាមសមាមាត្រនៃភាគហ៊ុនរបស់ខ្លួន ។ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះ រាល់សោហ៊ុយចំណាយទាំងអស់នេះនឹងត្រូវទទួលបន្ទុកដោយក្រុមហ៊ុន ដែលនឹងធ្វើការរំលស់នៅមុនពេលបែងចែកប្រាក់ចំណេញ និងយ៉ាងយូរបំផុតត្រូវរំលស់អោយអស់នៅក្នុងអំឡុងពេល ៥ ឆ្នាំ ។

ធ្វើជា ច្បាប់ដើម នៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១១

បានអាន និង យល់ព្រម
ទទួលមុខងារជាអភិបាល

បានអាន និង យល់ព្រម
ទទួលមុខងារជាប្រធានក្រុមប្រឹក្សាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

Ministry of Commerce

No [illegible] MOC / M 2004

ភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពី
## ការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម ។

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងប្រកាសលេខ ៥១៤ សរវ-ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនប័ត្រផ្សេងៗ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-យោងតាមការចាំបាច់ក្នុងទិសដៅកែទំរង់វិស័យចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួង

## សំរេច

**ប្រការ ១ :** រាល់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលបានបង្កើតឡើងនិងធ្វើពាណិជ្ជកិច្ច ហើយមិនទាន់បានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មត្រូវមានកាតព្វកិច្ចមកចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២ :** ដើម្បីធានាអះអាង និង ទទួលខុសត្រូវលើរាល់សំណុំលិខិតដែលខ្លួនបានបំពេញ ឬ ដែលខ្លួនត្រូវបំពេញ និង ផ្តល់មកតំកល់ទុកនៅនាយកដ្ឋាននីតិកម្មក្រសួងពាណិជ្ជកម្ម អភិបាលម្នាក់ ឬ ម្ចាស់ហ៊ុនម្នាក់ ត្រូវមកចុះហត្ថលេខាដោយផ្ទាល់ដៃ នៅចំពោះមុខមន្ត្រីនាយកដ្ឋាននីតិកម្ម



Ministry of Commerce # 20 A & B Preah Norodom Boulevard. Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396

បញ្ជាក់ថា រាល់សំណុំ លិខិតទាំងឡាយនេះ ពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ព្រមទាំងបង់សោហ៊ុយចំណាយដោយផ្ទាល់ដៃនៅលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣** : សោហ៊ុយចំណាយលើបែបបទ សុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានដូចខាងក្រោម :

| | |
|---|---|
| -អាករលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | : 70 USD ( ចិតសិបដុល្លារអាមេរិក ) |
| -ទម្រង់បែបបទសុំចុះបញ្ជីពាណិជ្ជកម្ម | : 30 USD ( សាមសិបដុល្លារអាមេរិក ) |
| -ឆែកឈ្មោះ | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -ផ្តល់អត្តលេខចុះបញ្ជី | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -សភាពាណិជ្ជកម្ម | : 20 USD ( ម្ភៃដុល្លារអាមេរិក ) |
| -ព្រឹត្តិប័ត្រពាណិជ្ជកម្ម | : 10 USD ( ដប់ដុល្លារអាមេរិក ) |
| -ធ្វើត្រា | : 12 USD ( ដប់ពីរដុល្លារអាមេរិក ) |
| -រាជកិច្ច | : 5 USD ( ប្រាំដុល្លារអាមេរិក ) |
| -មន្ទីរពាណិជ្ជកម្មក្រុងភ្នំពេញ | : 20 USD ( ម្ភៃដុល្លារអាមេរិក ) |

បូកសរុបសោហ៊ុយចំណាយលើបែបបទចុះបញ្ជី: 177 USD ( មួយរយចិតសិបប្រាំពីរដុល្លារអាមេរិក )

**ប្រការ ៤** : នាយកដ្ឋាននីតិកម្ម មានកាតព្វកិច្ចផ្តល់គំរូលក្ខន្តិកៈក្រុមហ៊ុនឱ្យអ្នកចុះបញ្ជី ។ ក្នុងករណីអ្នកចុះបញ្ជី ពឹងពាក់មេធាវី ឬក្រុមហ៊ុនច្បាប់ណាមួយជួយបំពេញ លក្ខន្តិកៈឱ្យខ្លួន សោហ៊ុយសេវានេះគឺស្ថិតនៅក្រៅវង្វង់អំណាចរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម ។ ក្រសួងពាណិជ្ជកម្មមិនទទួលខុសត្រូវលើសេវានោះទេ ។

**ប្រការ ៥** : នាយកដ្ឋាននីតិកម្ម ត្រូវមានវិធានការសមស្រប ដើម្បីសហការជាមួយអភិបាល ឬ ម្ចាស់ហ៊ុន ដែលមកសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ដើម្បីជួយណែនាំ និង បង្កលក្ខណៈងាយស្រួលដល់ការចុះបញ្ជីពាណិជ្ជកម្មអោយបានឆាប់រហ័ស និង ទាន់ពេលវេលា ។

**ប្រការ ៦** : អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋាននីតិកម្ម និង មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់តាមខ្លឹមសារនៃប្រកាសនេះ ។

**ប្រការ ៧** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៤តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម_ប្រសិទ្ធ**

ចំលងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង
-ទីស្តីការគណៈរដ្ឋមន្ត្រី ( ជូនជ្រាបជារបាយការណ៍ )
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
-ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ( ដើម្បីជួយផ្សព្វផ្សាយ )
-អភិបាលខេត្ត-ក្រុង ( ដើម្បីជួយផ្សព្វផ្សាយ )
-ឯកសារ-កាលប្បវត្តិ
-រាជកិច្ច ⁄

Prakas on commercial rigistration inspection/LAD/Sokun/SH

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimite: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones

**Limited Partnership Agreement**

LIMITED PARTNERSHIP AGREEMENT
OF
^ABC LAND ASSOCIATES LIMITED PARTNERSHIP

THIS LIMITED PARTNERSHIP AGREEMENT (this **"Partnership Agreement"**) is made this ^ day of ^, 19^ by and among ^ABC Associates, an Illinois general partnership (the **"General Partner"**), and the other persons (the **"Initial Limited Partners"**) who are identified on and have executed the signature pages to this Partnership Agreement.

RECITAL

The General Partner and the Initial Limited Partners wish to enter into and form a limited partnership (the **"Partnership"**) under the Illinois Revised Uniform Limited Partnership Act (the **"Illinois RULPA"**) to acquire a certain parcel of land located at ^, ^, ^ County, Illinois (the **"Property"**), to construct thereon a parking lot or other suitable facility, and to hold and lease or operate the Property and such facility for income-producing purposes and possible future redevelopment or sale, all in accordance with the terms of this Partnership Agreement.

NOW THEREFORE, in consideration of the premises and the mutual promises and covenants herein contained, it is agreed that:

1. *Formation.*

The parties hereto hereby enter into and form a limited partnership (the **"Partnership"**) under the Illinois RULPA. The rights and obligations of the Partners (defined in Section 19) shall be as stated in the Illinois RULPA except as otherwise provided herein.

2. *Name.*

The name of the Partnership shall be "^ABC Land Associates Limited Partnership."

3. *Principal Office.*

The principal office of the Partnership shall be located at ^, ^, Illinois ^ or such other location as the General Partner may determine. The Partnership may have such additional offices as the General Partner may in its discretion deem necessary or advisable.

4. *Purpose.*

The principal business of the Partnership is to undertake and perform the activities described in the Recital to this Partnership Agreement and to engage in any and all activities that may be related or incidental thereto. The Partnership shall not engage in any other business or activity.

5. *Filing of Original Certificate.*

As promptly as practicable after the date of this Partnership Agreement the General Partner shall file an original certificate of limited partnership of the Partnership in the office of the Secretary of State of Illinois in accordance with Section 201 of the Illinois RULPA.

Downloaded from http://www.tidyforms.com

6. *Term.*

The Partnership shall commence on the date of the filing referred to in Section 5 and shall continue in full force and effect until ^, 19^, unless sooner terminated pursuant to the provisions of this Partnership Agreement.

7. *Partners; Contributions; Etc.*

(a) *Initial Partners.*

The name, business address and Capital Contribution (defined in Section 19) of the General Partner and each Initial Limited Partner is set forth on Exhibit A to this Partnership Agreement.

(b) *Initial Capital Contributions.*

Concurrently with the execution and delivery of this Partnership Agreement the General Partner and each Initial Limited Partner has contributed such Partner's Capital Contribution in full, in cash, to the capital of the Partnership.

(c) *Authority to Admit Additional Limited Partners.*

The General Partner is authorized to admit Additional Limited Partners to the Partnership in accordance with the terms of this Partnership Agreement. The Capital Contributions of all Additional Limited Partners shall be made in cash.

(d) *Ownership by the General Partner of a Limited Partnership Interest.*

The General Partner shall also be (and shall be treated as) a Limited Partner to the extent, if any, that it shall acquire a Partnership Interest of a Limited Partner under this Partnership Agreement.

(e) *No Interest on Capital.*

No Partner shall be entitled to interest on any Capital Contribution or on such Partner's Capital Account (defined in Section 19), notwithstanding any disproportion that may from time to time exist therein as among the Partners.

(f) *No Additional Capital Contributions Required.*

No Partner shall be required to make any additional Capital Contribution to the Partnership.

8. *Duties and Powers of the General Partner; Management of the Partnership Business.*

(a) *General and Specific Powers.*

The General Partner shall have all of the rights and powers of a general partner as provided in the Illinois RULPA and as otherwise provided by law and shall have sole and exclusive management and control of the business and affairs of the Partnership. In



Downloaded from http://www.tidyforms.com

furtherance and not in limitation of the foregoing the General Partner is granted and shall have the right and power to perform, in the name and on behalf of the Partnership, all acts which in its judgment are necessary or desirable to carry out the Partnership's business including without limitation:

(i) to purchase or otherwise acquire, own, lease, manage and operate real estate or other property or any interest therein and to invest and reinvest any funds of the Partnership in such property;

(ii) to improve and develop real estate; to construct, alter, demolish, repair or replace buildings, structures, or other improvements on real estate including real estate in the vicinity of the Property for the purpose of enhancing the value of the Property; to enter into partnerships, joint ventures or other arrangements with any Person (including any Affiliate of the General Partner) for such purposes; to settle boundary lines and grant and reserve easements, covenants, rights-of-way and other rights or privileges with respect to real estate; and to partition and to join with co-owners and others in dealing with real estate in any manner;

(iii) to employ agents, employees, independent contractors, brokers, attorneys and accountants, any or all of whom may be Affiliates of the General Partner, to assist in or take responsibility for the management of the Partnership's business and, in each such instance, to pay such Persons reasonable compensation therefor;

(iv) to borrow money from any Partner, lending institution or other Person (including any Affiliate of the General Partner) and, in connection therewith, to issue notes, or any other evidence of indebtedness and as security therefor to mortgage or otherwise encumber any or all of the Partnership Property (defined in Section 19); to enter into financing arrangements on terms that grant the lenders equity rights in, or rights to share in the revenue or income of, Partnership Property (and no Partner, bank, lending institution or other lender to which application is made for a loan by the General Partners shall be required to inquire as to the purposes for which such loan is sought, and as between this Partnership and such Partner, bank, lending institution or other lender it shall be conclusively presumed that the proceeds of such loan are to be and will be used for purposes authorized under this Partnership Agreement); to obtain replacement financing or refinancing of any indebtedness or security therefor related to any Partnership Property, or to repay or prepay the same in whole or in part (and whether or not a prepayment penalty may be incurred), to increase, modify, consolidate or extend any mortgage or other encumbrance on any Partnership Property, and to enter into financing arrangements on terms that grant the lender equity rights in, or rights to share in the revenue or income of, Partnership Property;

(v) to commence or defend litigation with respect to the Partnership or any Partnership Property; to compromise, settle, arbitrate, or otherwise adjust claims in favor of or against the Partnership; and to insure Partnership Property and actions and undertakings of the Partnership and the General Partners against any and all risks relating to the business of the Partnership;

(vi) to sell, with or without notice, at public or private sale, and to exchange, trade, transfer, assign, convey, lease for any term (including a term extending beyond the term of the Partnership), appraise or have appraised, apportion, divide in kind, or grant options for any and all Partnership Property on and, in so doing, to execute, acknowledge, seal and deliver all necessary documents or instruments;



Downloaded from http://www.tidyforms.com

(vii) to make such elections under federal or state tax laws as to the treatment of items of income, gain, loss, deduction and credit;

(viii) to make investments in government obligations, bank certificates of deposit, short-term debt securities, and short-term commercial paper pending investment or reinvestment of funds of the Partnership or to provide funds from which to meet contingencies; and

(ix) to do all such other acts and things and engage in all such proceedings, and to execute, acknowledge, seal and deliver all documents or instruments, as the General Partners may deem necessary or desirable to carry out the business of the Partnership and to carry out the purposes of the Partnership, all at such price and other terms as the General Partner deems proper.

(b) *Expenditure of Time.*

The General Partner shall devote such time to the business of the Partnership as it, in its sole discretion, shall deem to be necessary to supervise the Partnership business and affairs in an efficient manner.

(c) *Agreed Liability Limitation; Indemnification.*

Neither the General Partner nor any Affiliate of the General Partner shall be liable, responsible or accountable in damages or otherwise to the Partnership or any Limited Partner for any act taken or omission to act on behalf of the Partnership or in the furtherance of the interests of the Partnership unless such act or omission was performed or omitted fraudulently or with gross negligence or in bad faith. The Partnership shall indemnify and hold harmless the General Partner and each of its Affiliates from and against any loss, expense, damage or injury suffered or sustained by such Person by reason of any acts, omissions or alleged acts or omissions arising out of his or its activities on behalf of the Partnership or in furtherance of the interests of the Partnership, including, but not limited to, any judgment, award, settlement, reasonable attorneys' fees and other costs and expenses incurred in connection with the defense of any actual or threatened action, proceeding or claim; provided that the acts, omissions, or alleged acts or omissions upon which such actual or threatened action, proceeding, or claim is based were not performed fraudulently, with gross negligence, or in bad faith. The termination of any action, suit, or proceeding by judgment, order, settlement, or upon a plea of nolo contendere or its equivalent shall not of itself create a presumption that the Person acted fraudulently or in bad faith.

(d) *Limited Partners to Have No Authority.*

No Limited Partner (except the General Partner, if it owns a Partnership Interest as a Limited Partner, acting solely in its capacity as the General Partner) shall participate in or have any control over the business of the Partnership or have any authority or right to act on behalf of or bind the Partnership.

(e) *Actions by or on Behalf of the General Partner.*

The President or any Vice President of any corporate partner of the General Partner may act for and in the name of the General Partner in the exercise by the General Partner of any of its rights and powers hereunder. In dealing with the General Partner (or President or any Vice President of any corporate general partner thereof) acting on behalf of the



Downloaded from http://www.tidyforms.com

Partnership, no Person shall be required to inquire into the authority of the General Partner (or such individual) to bind the Partnership. Persons dealing with the Partnership are entitled to rely conclusively upon the power and authority of the General Partner (and the President and any Vice President of any corporate general partner thereof) as set forth in this Agreement.

(f) *Transactions of the Partnership with or Involving Partners.*

(i) Any Partner (and any Affiliate of any Partner) and any other Person or firm in which a Partner is interested may be employed by the General Partner on behalf of the Partnership and may otherwise deal with the Partnership, whether as a buyer, seller, lessor, lessee, manager, mortgage or other broker, agent, furnisher of services, lender, or otherwise, and

(ii) the validity of any transaction, agreement or payment involving both the Partnership and a Partner (or an Affiliate of a Partner or another Person or firm in which a Partner is interested) shall not be affected by reason of the relationship between the Partnership or the General Partner and such Partner, Affiliate thereof or other Person. All transactions, agreements or payments involving the Partnership and any Partner, Affiliate thereof or other person described in this paragraph shall be on terms which are reasonable and no less favorable to the Partnership than those available to the Partnership in similar dealings with unaffiliated third parties.

